ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី ១៨ លេខ ៤៩ ក្រីមាសទី ០៣ ឆ្នាំ ២០១៨

រាជកិច្ច

ផ្សាយចេញពី

ទីស្តីការគណៈរដ្ឋមន្ត្រី

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច សារាចរ ប្រកាស

ក

មាតិកា

I.ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

១.ព្រះរាជក្រម

២១-០៦-២០១៨ -ព្រះរាជក្រម នស/រកម/០៦១៨/០០៧ ស្តីពី ការប្រកាសឱ្យប្រើ ច្បាប់ ស្តីពី ការអនុម័ត យល់ព្រមលើកិច្ចព្រមព្រៀង ស្តីពី ការបង្កើតអង្គការសហប្រតិបត្តិការព្រៃឈើអាស៊ី ៥៧៨៥

២.ព្រះរាជក្រឹត្យ

២៥-០៥-២០១៨ -ព្រះរាជក្រឹត្យ នស/រកត/០៥១៨/៥៨៥ ស្តីពី ឯកសណ្ឋានក្នុងសវនាការជំនុំជម្រះ ឬកិច្ចប្រជុំ ពេញអង្គរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ៥៨១៣

១៥-០៦-២០១៨ -ព្រះរាជក្រឹត្យ នស/រកត/០៦១៨/៦៣៦ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ឧត្តមសេនីយ៍ត្រី ដល់នាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ១៨ រូប ៥៨២៣

១៥-០៦-២០១៨ -ព្រះរាជក្រឹត្យ នស/រកត/០៦១៨/៦៣៧ ស្តីពី ការផ្ទេរក្របខ័ណ្ឌលោក **ឡុង ពិជ** នៃ ក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មកឋានន្តរស័ក្តិ ឧត្តមសេនីយ៍ត្រី នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា ក្រសួងមហាផ្ទៃ ៥៨២៥

១៥-០៦-២០១៨ -ព្រះរាជក្រឹត្យ នស/រកត/០៦១៨/៦៣៨ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ ព្រះសង្ឃ ចំនួន ០២ អង្គ ៥៨២៦

១៥-០៦-២០១៨ -ព្រះរាជក្រឹត្យ នស/រកត/០៦១៨/៦៣៩ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ចំពោះ លោក KIM DO HYUNG ៥៨២៧

១៥-០៦-២០១៨ -ព្រះរាជក្រឹត្យ នស/រកត/០៦១៨/៦៤០ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្តម អស់លោក និងលោកស្រី ចំនួន ២៣ រូប ៥៨២៨

១៥-០៦-២០១៨ -ព្រះរាជក្រឹត្យ នស/រកត/០៦១៨/៦៤១ ស្តីពី ការតែងតាំង លោក **ស៊ុន រ៉ី** និងលោក **លិ គឹមហ្ស៊ីរ** ជា ឧកញ៉ា ៥៨២៩

២១-០៦-២០១៨ -ព្រះរាជក្រឹត្យ នស/រកត/០៦១៨/៦៤២ ស្តីពី ការផ្តល់ឋានៈជាសាស្ត្រាចារ្យមហាបរិញ្ញា ដល់បណ្ឌិត និងវេជ្ជបណ្ឌិតនៅវិទ្យាស្ថានជាតិសុខភាពសាធារណៈ ០៤ រូប ៥៨៣០

២១-០៦-២០១៨ -ព្រះរាជក្រឹត្យ នស/រកត/០៦១៨/៦៤៣ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្តម ឧកញ៉ា លោកជំទាវ អស់លោក លោកស្រី កញ្ញា ឧបាសក ឧបាសិកា និងព្រះសង្ឆ ចំនួន ៧៣ រូប/អង្គ ៥៨៣១

II.ក្រុមប្រឹក្សាធម្មនុញ្ញ

២៦-០៦-២០១៨ -សេចក្តីសម្រេចលេខ ១៩៥/០០៣/២០១៨ កបធ.ច ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៨ លើសំណុំរឿងលេខ ៣៥៣/០០៤/២០១៨ ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៨ ៥៨៣៣

III.រាជរដ្ឋាភិបាល

១.អនុក្រឹត្យ

១៣-០៦-២០១៨ -អនុក្រឹត្យលេខ ៨០ អនក្រ.បក ស្តីពី ការដាក់ឱ្យប្រើប្រាស់ផែនការរៀបចំដែនដីខេត្តបាត់ដំបង ៥៨៣៧

១៩-០៦-២០១៨ -អនុក្រឹត្យលេខ ៥៧៨ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ ៥៨៦២

១៩-០៦-២០១៨ -អនុក្រឹត្យលេខ ៥៧៩ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិ នាយទាហាន ៥៨៦៤

១៩-០៦-២០១៨ -អនុក្រឹត្យលេខ ៥៨០ អនក្រ.តត ស្តីពី ការតែងតាំង និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៥៨៨១

២.សេចក្តីសម្រេច

១៩-០៦-២០១៨ -សេចក្តីសម្រេចលេខ ៣៦ សសរ ស្តីពី ការបង្កើតគណៈកម្មការត្រួតពិនិត្យ និងវាយតម្លៃស្ថានភាពហិរញ្ញវត្ថុ និងទុនវិនិយោគ របស់ក្រុមហ៊ុនសម្ប្ញទានព្រលានយន្តហោះ (SCA) ៥៨៨៣

៣.សារាចរ

២០-០៦-២០១៨ -សារាចរលេខ ០៤ សរ ស្តីពី ការពង្រឹងបន្ថែមលើការងារគ្រប់គ្រងវិស័យសកម្មភាពមីន ៥៨៨៦

IV.ការងារបណ្តាក្រសួង

១.ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

២៨-០២-២០១៨ -ប្រកាសអន្តរក្រសួងលេខ ២០៥ សហវ.ប្រក ស្តីពី ការបង្កើតរជ្ជទេយ្យបុរេប្រទាន សម្រាប់ឆ្នាំ ២០១៨ របស់សាលាភូមិន្ទរដ្ឋបាល ៥៨៨៨

២៨-០៣-២០១៨ -ប្រកាសអន្តរក្រសួងលេខ ៣៣៩ សហវ.ប្រក ស្តីពី ការបង្កើតរជ្ជទេយ្យបុរេប្រទាន សម្រាប់ឆ្នាំ ២០១៨ ប្រចាំនៅទីភ្នាក់ងារបញ្ជាក់ចំណាយសេវាសុខាភិបាល នៃក្រសួងសុខាភិបាល ៥៨៩២

២.ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

២២-០១-២០១៨ -ប្រកាសលេខ ០៦៣ ព.ណ.ប.ល.ប្រក ស្តីពី ការកែសម្រួល និងបំពេញបន្ថែមការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំក្រសួងពាណិជ្ជកម្ម ៥៨៩៨

ព្រះរាជក្រម

នស/រកម/០៦១៨/ ០០៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ងួហោតាស អង្គុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពី ការបង្កើតអង្គការសហប្រតិបត្តិការព្រៃឈើអាស៊ីដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨ នាសម័យប្រជុំរដ្ឋសភាលើកទី១០ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៨ នាសម័យប្រជុំពេញអង្គលើកទី១ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

ច្បាប់
ស្តីពី
ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពី ការបង្កើតអង្គការសហប្រតិបត្តិការព្រៃឈើអាស៊ី

មាត្រា១.-

អនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពី ការបង្កើតអង្គការសហប្រតិបត្តិការព្រៃឈើអាស៊ីដែលព្រះរាជាណាចក្រកម្ពុជាបានចុះហត្ថលេខា នៅរដ្ឋធានីសេអ៊ូល នៃសាធារណរដ្ឋកូរ៉ា នាថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៧ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

មាត្រា២.-

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ ។

មាត្រា៣.-

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

ថ្ងៃត្រាវាស្ស៊ាង ៥កើត ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៨

ព្រះហស្តលេខា និងព្រះរាជលញ្ឆការ
នរោត្តម សីហមុនី

នស.១៥០៦.២៤

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមទ្រាយព្រះហស្តលេខា
នាយករដ្ឋមន្ត្រី
ហត្ថលេខា
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
ហត្ថលេខា
វេង សាខុន

លេខ:៦៦០ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
ថ្ងៃសុក្រ ១០កើត ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ,ថ្ងៃទី ២២ ខែមិថុនា ឆ្នាំ២០១៨
អគ្គលេខាធិការដ្ឋានរដ្ឋាភិបាល

សយ សុខា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:...០៥...ស/ប

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ក្រដូច ឆ្នាំ២០១៧

សិទ្ធិប្រទាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

រាជរដ្ឋាភិបាល

ប្រទានសិទ្ធិជូន**ឯកឧត្តម ខេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីការបង្កើតអង្គការសហប្រតិបត្តិការព្រៃឈើអាស៊ី (AFoCo)។

ដើម្បីជាសក្ខីភាព នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដោយមានសិទ្ធិពេញលេញតាមអំណាចច្បាប់ បានចុះហត្ថលេខាខាងក្រោម លើសិទ្ធិប្រទាននេះ។

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា
Kingdom of Cambodia

រាជរដ្ឋាភិបាល
Royal Government

ជាតិ សាសនា ព្រះមហាក្សត្រ
Nation Religion King

ក្រ ០៩.ស/ប១

Phnom Penh, February 07 2017

DELEGATION OF FULL POWERS

- Considering the constitution of the Kingdom of Cambodia,
- Considering the Royal Decree NS/RKT/0913/903 dated 24 September 2013 on the Nomination of the Royal Government of Cambodia,
- Considering the Royal Degree NS/RKT/0416/368 dated 04 April 2016 on the Reshuffle of the Royal Government of Cambodia,
- Considering the Royal Kram 02/NS/94 dated 20 July 1994 promulgating the Law on the Organization and Functioning of the Council of Ministers,
- Considering the Royal Kram NS/RKM/0196/13 dated 24 January 1996 promulgating the Law on the Establishment of the Ministry of Agriculture, Forestry and Fisheries.
- Pursuant to the Proposal of the Minister of Agriculture, Forestry and Fisheries.

THE ROYAL GOVERNMENT

Delegates herewith Full Powers to **H.E. VENG SAKHON**, Minister of the Ministry of Agriculture, Forestry and Fisheries to sign the Agreement on the Establishment of the Asian Forest Cooperation Organization (AFoCo).

In witness whereof, the undersigned, the Prime Minister of the Kingdom of Cambodia, with Full Powers duly entrusted to him, has signed the Delegation of Full Powers.

Prime Minister

Samdech Akka Moha Sena Padei Techo HUN SEN

កិច្ចព្រមព្រៀងស្តីពី
ការបង្កើតអង្គការសហប្រតិបត្តិការព្រៃឈើអាស៊ី
(AFoCO : Asian Forest Cooperation Organization)

បុព្វបទ

រំលឹកឡើងវិញនូវសេចក្តីសម្រេចពាក់ព័ន្ធនឹងវិស័យព្រៃឈើដែលអនុម័តដោយសន្និសីទសហប្រជាជាតិស្តីពីបរិស្ថាន និងការអភិវឌ្ឍឆ្នាំ១៩៩២ កិច្ចប្រជុំកំពូលពិភពលោកស្តីពីការអភិវឌ្ឍប្រកបដោយចីរភាពឆ្នាំ២០០២ និងសន្និសីទសហប្រជាជាតិស្តីពីការអភិវឌ្ឍប្រកបដោយចីរភាពឆ្នាំ២០១២(Rio+20) អនុសញ្ញាសហប្រជាជាតិស្តីពីការប្រយុទ្ធប្រឆាំងវាលរហោឋានថ្ងៃទី១៤ ខែតុលា ឆ្នាំ១៩៩៤ អនុសញ្ញារ៉ាំសាស្តីពីតំបន់ដីសើមថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ១៩៧១ អនុសញ្ញាស្តីពីជីវៈចម្រុះ និងអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុថ្ងៃទី៤ ខែមិថុនា ឆ្នាំ១៩៩២។

រំលឹកឡើងវិញផងដែរនូវសំណើធ្វើសកម្មភាពនៃក្រុមការងារអន្តររដ្ឋាភិបាលស្តីពីព្រៃឈើនិងវេទិកាអន្តររដ្ឋាភិបាលស្តីពីព្រៃឈើពាក់ព័ន្ធនឹងសេចក្តីសម្រេចចិត្តនៃវេទិកាសហប្រជាជាតិស្តីពីព្រៃឈើនិងឧបករណ៍មិនមែនជាចំណងផ្លូវច្បាប់ស្តីពីព្រៃឈើគ្រប់ប្រភេទ។

ស្វាគមន៍ចំពោះគោលដៅអភិវឌ្ឍប្រកបដោយចីរភាព ក្រោមការណែនាំនៃសន្និសីទសហប្រជាជាតិស្តីពីការអភិវឌ្ឍប្រកបដោយចីរភាពឆ្នាំ២០១២(Rio+20) ដែលត្រូវបានធ្វើសមាហរណកម្មជាមួយរបៀបវារៈនៃការអភិវឌ្ឍរបស់សហប្រជាជាតិក្រោយឆ្នាំ២០១៥។

ដោយពិនិត្យមើលឃើញអំពីតម្រូវការជាបន្ទាន់ស្តីពីការធ្វើកិច្ចសហប្រតិបត្តិការវិស័យព្រៃឈើរវាងភាគីពាក់ព័ន្ធនៃតំបន់អាស៊ីក្នុងគោលបំណងដើម្បីពង្រីកផ្ទៃដីព្រៃឈើ សិក្សាស៊ីជម្រៅលើវិស័យព្រៃឈើ ការស្តារព្រៃឈើឡើងវិញ និងការពង្រឹងសមត្ថភាពភាគីពាក់ព័ន្ធក្នុងការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុពិភពលោក។

ដោយទទួលស្គាល់ថា ភាគីពាក់ព័ន្ធទាំងអស់មានតួនាទីសំខាន់ក្នុងការស្តារដីព្រៃរេចរឹលឡើងវិញ ការពង្រឹង ការគ្រប់គ្រងព្រៃឈើឲ្យមាននិរន្តរភាព ការប្រយុទ្ធប្រឆាំងវាលរហោឋានឬភាពរេចរឹលនៃគុណភាពដីនិងវឌ្ឍនភាពក្នុងការអនុវត្តកម្មវិធីព្រៃឈើជាតិនានាឲ្យមានប្រសិទ្ធភាព។

ទទួលស្គាល់នូវសក្តានុពលនៃគំនិតផ្តួចផ្តើមក្នុងការអភិវឌ្ឍបៃតង សមិទ្ធផលពីអតីត និងសក្តានុពលនាពេលអនាគតក្នុងការដាំ និងស្តារព្រៃឈើឡើងវិញវឌ្ឍនភាពដែលសម្រេចបានក្នុងការអភិវឌ្ឍ និងគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព និងសក្តានុពលក្នុងការធ្វើឲ្យប្រសើរឡើងនូវអភិបាលកិច្ចព្រៃឈើក្នុងតំបន់អាស៊ី។

ផ្អែកលើសំណើរបស់សាធារណរដ្ឋកូរ៉េស្តីពីការបង្កើតអង្គការសហប្រតិបត្តិការព្រៃឈើអាស៊ី (AFoCO) នាឱកាសនៃកិច្ចប្រជុំកំពូលអាស៊ាននិងសាធារណរដ្ឋកូរ៉េកាលពីថ្ងៃទី១ និងទី២ ខែមិថុនា ឆ្នាំ២០០៩ នៅកោះជេជូនៃសាធារណរដ្ឋកូរ៉េ។

ផ្អែកលើលទ្ធផលនៃកិច្ចប្រជុំពិភាក្សាជាបន្តបន្ទាប់រវាងបណ្តាប្រទេសជាសមាជិកអាស៊ាន និងសាធារណរដ្ឋកូរ៉េស្តីពីការបង្កើតអង្គការសហប្រតិបត្តិការព្រៃឈើអាស៊ី (AFoCO) ក្រោមកិច្ចព្រមព្រៀងសហប្រតិបត្តិការព្រៃឈើ (AFoCo) ដែលចូលជាធរមានកាលពីថ្ងៃទី៥ ខែសីហា ឆ្នាំ២០១២។

ស្វាគមន៍នូវសេចក្តីសម្រេចរបស់កិច្ចប្រជុំលើកទី៣នៃក្រុមប្រឹក្សាភិបាលកិច្ចព្រមព្រៀង AFoCo ដែលបានអញ្ជើញបណ្តាប្រទេសសមាជិកអាស៊ាន ប៊ូតង់ កាហ្សាកស្ថាន ម៉ុងហ្គោលលី ទីម័រខាងកើត និងសាធារណរដ្ឋកូរ៉េឲ្យចូលរួមពិភាក្សា រៀបចំកិច្ចព្រមព្រៀងស្តីពីការបង្កើតអង្គការសហប្រតិបត្តិការព្រៃឈើអាស៊ី (AFoCO)។

ភាគីសមាជិកទាំងអស់បានសម្រេចបង្កើតកិច្ចព្រមព្រៀងដែលមានចែងដូចខាងក្រោមនេះ៖

មាត្រា១ ៖ និយមន័យ

ក~"**កិច្ចព្រមព្រៀង**" មានន័យថាជាកិច្ចព្រមព្រៀងស្តីពីការបង្កើតអង្គការសហប្រតិបត្តិការព្រៃឈើអាស៊ី (AFoCO)

ខ~"**អង្គការ**" មានន័យថាជាអង្គការសហប្រតិបត្តិការព្រៃឈើអាស៊ី (AFoCO) បង្កើតឡើងក្រោមកិច្ចព្រមព្រៀងនេះ

គ~"**សភា**" មានន័យថាជាក្រុមប្រឹក្សាខ្ពស់បំផុតរបស់អង្គការសហប្រតិបត្តិការព្រៃឈើអាស៊ីដែលមានសិទ្ធិធ្វើសេចក្តីសម្រេច និងមានតំណាងដែលចាត់តាំងមកពីប្រទេសសមាជិកនៃកិច្ចព្រមព្រៀងនេះ

ឃ~"**នាយកប្រតិបត្តិ**" មានន័យថាជាប្រធានរដ្ឋបាលរបស់អង្គការសហប្រតិបត្តិការព្រៃឈើអាស៊ី(AFoCO) ដែលជ្រើសតាំងដោយសភា

ង~"**លេខាធិការដ្ឋាន**" មានន័យថាជាអង្គភាពផ្តល់នូវការគាំទ្រផ្នែករដ្ឋបាលរបស់អង្គការសហប្រតិបត្តិការព្រៃឈើអាស៊ី(AFoCO) និងអនុវត្តការងារផ្សេងៗទៀតតាមការណែនាំរបស់សភា

ច~"**ប្រទេសហត្ថលេខី**" មានន័យថាជាប្រទេសដែលបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ និងមិនទាន់បានដាក់តម្កល់លិខិតតូបករណ៍ផ្តល់សច្ចាប័ន ការទទួលយក ឬការយល់ព្រមនៅឡើយ

ឆ~"**ភាគីសមាជិក**" មានន័យថាជាប្រទេសហត្ថលេខីដែលបានដាក់តម្កល់លិខិតតូបករណ៍ផ្តល់សច្ចាប័ន ការទទួលយក ឬការយល់ព្រមលើកិច្ចព្រមព្រៀងនេះ

ជ~"**អ្នកសង្កេតការណ៍**" មានន័យថាជាប្រទេសឬអង្គភាពដែលទទួលបានសិទ្ធិពីសភាក្នុងការចូលរួមសង្កេតការណ៍

ឈ~"**តំណាង**" មានន័យថាជាមន្ត្រីជំនាញវិស័យព្រៃឈើមានបទពិសោធដែលត្រូវបានចាត់តាំងដោយភាគីសមាជិកឲ្យចូលជាតំណាងក្នុងសភានេះ

ញ~"**ប្រទេសម្ចាស់ផ្ទះ**" មានន័យថាជាប្រទេសដែលមានទីស្នាក់ការកណ្តាលរបស់អង្គការសហប្រតិបត្តិការព្រៃឈើអាស៊ី(AFoCO) នេះតាំងនៅ

ដ~"**ចំណាយប្រតិបត្តិការ**" មានន័យថាជាចំណាយសម្រាប់ប្រតិបត្តិការរបស់សភា លេខាធិការដ្ឋាន និងបណ្តាអង្គភាពក្រោមឱវាទរបស់អង្គការសហប្រតិបត្តិការព្រៃឈើអាស៊ី(AFoCO)។

មាត្រា២ ៖ ការបង្កើតអង្គការ AFoCO

១- អង្គការ AFoCO ត្រូវបានបង្កើតឡើងក្រោមរូបភាពជាអង្គការអន្តររដ្ឋាភិបាលអនុលោមតាមបទបញ្ញត្តិដែលមានចែងក្នុងកិច្ចព្រមព្រៀងនេះ

២- ទីស្នាក់ការកណ្តាលរបស់អង្គការ AFoCO និងលេខាធិការដ្ឋានមានទីតាំងស្ថិតនៅក្នុងសាធារណរដ្ឋកូរ៉េ ។ កិច្ចព្រមព្រៀងស្តីពីទីស្នាក់ការកណ្តាលនឹងត្រូវរៀបចំឡើងរវាងរដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េនិង អង្គការ AFoCO។

មាត្រា៣ ៖ គោលបំណង

១- អង្គការ AFoCO ត្រូវបានបង្កើតឡើងដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការវិស័យព្រៃឈើក្នុងតំបន់តាមរយៈ ការបម្លែងគោលនយោបាយនិងបច្ចេកវិទ្យាឲ្យទៅជាសកម្មភាពជាក់ស្តែងក្រោមបរិបទនៃការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពដើម្បីដោះស្រាយផលប៉ះពាល់អំពីការប្រែប្រួលអាកាសធាតុ

២- អង្គការ AFoCO នឹងជំរុញការអនុវត្តកម្មវិធីសហប្រតិបត្តិការលើវិស័យព្រៃឈើនៅអាស៊ីដូចខាងក្រោម៖

ក- ការគ្រប់គ្រងព្រៃឈើដោយប្រកបនិរន្តរភាព ការអភិរក្សជីវៈចម្រុះ ការថែរក្សា និងការបង្កើនសេវាកម្មប្រព័ន្ធអេកូឡូស៊ី ក៏ដូចជាការដាំព្រៃឈើឡើងវិញ និងការស្តារព្រៃឈើ

ខ- សកម្មភាពកាត់បន្ថយនិងបន្ស៊ាំបម្រែបម្រួលអាកាសធាតុ និងគាំទ្រកិច្ចផ្តួចផ្តើមគំនិតកម្មវិធីរេដបូក (REDD+) ដែលជាយន្តការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីការបាត់បង់ និងរេចរឹលព្រៃឈើ ហើយបង្កើនតួនាទីការអភិរក្សព្រៃឈើការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពនិងការបង្កើនកាបូនស្តុក ព្រៃឈើនៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍ

គ- ការកាត់បន្ថយការបាត់បង់ព្រៃឈើ ការរេចរឹលនៃព្រៃឈើ ការបាត់បង់គុណភាពដី និងការប្រយុទ្ធប្រឆាំងវាលរហោឋាន ព្រមទាំងការទប់ស្កាត់ផលប៉ះពាល់គ្រោះមហន្តរាយដែលបណ្តាលមកពីការបាត់បង់ព្រៃឈើ

ឃ- ការកសាងសមត្ថភាពដល់អ្នកពាក់ព័ន្ធតាមរយៈការស្រាវជ្រាវ និងការអភិវឌ្ឍ ការចែករំលែកបទពិសោធការផ្ទេរបច្ចេកវិទ្យា ការអប់រំ និងការផ្លាស់ប្តូរកម្មវិធី

ង- ការបង្កើតភាពជាដៃគូរវាងបណ្តាភាគីសមាជិក ជាមួយស្ថាប័នដទៃទៀតក្នុងការអនុវត្តកិច្ចសហប្រតិបត្តិការដោយផ្អែកទៅលើគំនិតផ្តួចផ្តើមនៃកិច្ចព្រមព្រៀងអន្តរជាតិស្តីពីព្រៃឈើនិងអង្គការផ្សេងៗ។

មាត្រា៤ ៖ សិទ្ធិខាងផ្លូវច្បាប់

អង្គការ AFoCO មានសិទ្ធិស្របច្បាប់ក្នុងការបំពេញតួនាទីដើម្បីសម្រេចគោលបំណងរបស់ខ្លួន ជាពិសេសពាក់ព័ន្ធនឹង៖

ក- ការចុះកិច្ចព្រមព្រៀងនិងកិច្ចសន្យានានា

ខ- ការចាត់ចែងចលនទ្រព្យនិងអចលនទ្រព្យ

គ- ការបង្កើត និងការពារស្ថាប័នតាមផ្លូវច្បាប់។

មាត្រា៥ ៖ សមាជិកភាព

១- ប្រទេសហត្ថលេខីនឹងក្លាយទៅជាភាគីសមាជិកក្នុងកិច្ចព្រមព្រៀងនេះក្រោយពីប្រទេសហត្ថលេខីបានតម្កល់លិខិតតូបករណ៍ផ្តល់សច្ចាប័ន ឬការទទួលយក ឬការយល់ព្រមលើកិច្ចព្រមព្រៀង។ ភាគីសមាជិកនៃកិច្ចព្រមព្រៀងនឹងក្លាយជាសមាជិករបស់អង្គការ AFoCO

២- ប្រទេសដែលមិនមែនជាប្រទេសហត្ថលេខីដែលមានបំណងចូលជាសមាជិកនៃអង្គការ AFoCO ត្រូវស្នើសុំការយល់ព្រមពីសភារបស់អង្គការ AFoCO

៣- ការស្នើសុំចូលជាសមាជិកនៃអង្គការ AFoCO គឺបើកចំហចំពោះប្រទេសទាំងឡាយណាដែលមានទីតាំងភូមិសាស្ត្រស្ថិតក្នុងតំបន់អាស៊ី។

មាត្រា៦ ៖ អ្នកសង្កេតការណ៍

១- សិទ្ធិជាអ្នកសង្កេតការណ៍អាចត្រូវផ្តល់ដោយសភាអង្គការ AFoCO ដែលក្នុងនេះអាចផ្តល់ជូនចំពោះ៖

ក- ប្រទេសហត្ថលេខីទាំងឡាយណាដែលមិនទាន់បានតម្កល់លិខិតតូបករណ៍ផ្តល់សច្ចាប័ន ការទទួលយក ឬការយល់ព្រម

ខ- បណ្តាប្រទេសនៅអាស៊ីដែលបានដាក់ពាក្យស្នើសុំចូលជាអ្នកសង្កេតការណ៍

គ- អង្គការអន្តរជាតិឬអង្គការក្រៅរដ្ឋាភិបាលដែលធ្វើការងារពាក់ព័ន្ធនឹងវិស័យព្រៃឈើ

២- រាល់សកម្មភាពការងារពាក់ព័ន្ធនឹងការចូលរួមរបស់អ្នកសង្កេតការណ៍នឹងត្រូវសម្រេចដោយសភាអង្គការ AFoCO ដោយអនុលោមតាមបទប្បញ្ញត្តិផ្ទៃក្នុងរបស់អង្គការ AFoCO។

មាត្រា៧ ៖ អង្គភាព និងអង្គភាពគាំទ្រ

១- អង្គភាពស្នូលរបស់អង្គការ AFoCO រួមមាន សភានិងលេខាធិការដ្ឋាន

២- អង្គភាពគាំទ្រអាចត្រូវបង្កើតឡើងដោយសភាអង្គការ AFoCO អនុលោមតាមមាត្រា៨ នៃកិច្ចព្រមព្រៀងនេះ។

មាត្រា៨ ៖ សភាអង្គការ AFoCO

១- សភារបស់អង្គការ AFoCO ត្រូវមានតំណាងមកពីបណ្តាភាគីសមាជិកទាំងអស់នៃកិច្ចព្រមព្រៀង

២- ភាគីសមាជិកនីមួយៗត្រូវចាត់តាំងតំណាងចំនួនមួយ(១)រូប ដើម្បីចូលរួមជាសមាជិកសភាអង្គការ AFoCO។ សភាអង្គការ AFoCO ត្រូវបោះឆ្នោតផ្ទែកតាមគោលការណ៍ប្តូរវេនសម្រាប់រយៈពេលមួយ(១)ឆ្នាំ ក្នុងការជ្រើសតាំងប្រធាននិងអនុប្រធាន

៣- សភាអង្គការ AFoCO ត្រូវមានកិច្ចប្រជុំប្រចាំឆ្នាំរបស់ខ្លួនចំនួនមួយ(១)ដង និងអាចមានកិច្ចប្រជុំពិសេសតាមការចាំបាច់។ ប្រធានសភាអង្គការ AFoCO អាចនឹងរៀបចំកិច្ចប្រជុំពិសេសអាស្រ័យទៅតាមសំណូមពរភាគ ច្រើនរបស់ភាគីសមាជិក

៤- កិច្ចប្រជុំសភាអង្គការ AFoCO លើកទីមួយត្រូវធ្វើការពិនិត្យនិងអនុម័តលើបទបញ្ជាផ្ទៃក្នុងរបស់អង្គការ AFoCO

៥- កិច្ចប្រជុំសភាអង្គការ AFoCO លើកទីមួយត្រូវធ្វើការបោះឆ្នោតជ្រើសតាំងនាយកប្រតិបត្តិលេខាធិការដ្ឋាន។

៦- សភាអង្គការ AFoCO ត្រូវ៖

ក- អនុម័តនិងធ្វើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងរបស់អង្គការ AFoCO ក្នុងករណីចាំបាច់

ខ- តែងតាំងនាយកប្រតិបត្តិសម្រាប់លេខាធិការដ្ឋាន

គ- អនុម័តយល់ព្រមលើការបង្កើតអង្គភាពគាំទ្រដែលចាំបាច់ដើម្បីសម្រេចគោលបំណងរបស់អង្គការ

ឃ- អនុម័តកម្មវិធីនិងថវិកាសម្រាប់សកម្មភាពការងាររបស់អង្គការ AFoCO

ង- ពិនិត្យរបាយការណ៍របស់នាយកប្រតិបត្តិនិងអង្គភាពគាំទ្រហើយផ្តល់ការណែនាំ

ច- ពង្រឹងទំនាក់ទំនងជាមួយបណ្តាអង្គការពាក់ព័ន្ធដើម្បីចៀសវាងការជាន់សកម្មភាព

ឆ- ពិភាក្សានិងអនុម័តលើសំណើសុំវិសោធនកម្មកិច្ចព្រមព្រៀងដែលស្នើឡើងដោយភាគីសមាជិកមួយឬច្រើនដោយអនុលោមតាមមាត្រា២០នៃកិច្ចព្រមព្រៀងនេះ

ជ-អនុម័តលើពាក្យសុំចូលជាអ្នកសង្កេតការណ៍

ឈ-អនុម័តលើសំណើសុំរបស់ប្រទេសមិនមែនហត្ថលេខីដើម្បីចូលជាសមាជិក

ញ- អនុវត្តមុខងារ ភារកិច្ចផ្សេងទៀតតាមការចាំបាច់ដើម្បីសម្រេចបាននូវគោលបំណងរបស់អង្គការ AFoCO

៧- សភាអង្គការ AFoCO ត្រូវសម្រេចលើសំណើធ្វើវិសោធនកម្មកិច្ចព្រមព្រៀង និងអនុម័តលើសមាជិកភាពថ្មីដោយមូលមតិគ្នា

៨- សភាអង្គការ AFoCO ត្រូវព្យាយាមគ្រប់វិធីដើម្បីសម្រេចបានការមូលមតិគ្នា។ បើសិនករណីមិនមានការមូលមតិគ្នាក្នុងការសម្រេចការងារអ្វីមួយក្រៅពីចំណុចចែងក្នុងកថាខណ្ឌ៧ខាងលើ សភាអង្គការ AFoCO ត្រូវកំណត់យករូបមន្តទន់ភ្លន់ណាមួយដែលអាចធ្វើសេចក្តីសម្រេចចិត្តបាន។

មាត្រា ៩ ៖ លេខាធិការដ្ឋាន

១- លេខាធិការដ្ឋានរបស់អង្គការ AFoCO ត្រូវបង្កើតឡើងនៅពេលកិច្ចព្រមព្រៀងនេះចូលជាធរមាន។ លេខាធិការដ្ឋានអង្គការ AFoCO ដឹកនាំដោយនាយកប្រតិបត្តិមួយរូប។ នាយកប្រតិបត្តិត្រូវគ្រប់គ្រងការងារក្នុងមួយ(១)អាណត្តិដែលមានរយៈពេលពីរ(២)ឆ្នាំ និងអាចបន្តការងារមិនឲ្យលើសពីមួយ(១)អាណត្តិ

២- អនុលោមតាមបទបញ្ជាផ្ទៃក្នុងរបស់អង្គការ AFoCO នាយកប្រតិបត្តិត្រូវជ្រើសតាំងបុគ្គលិកសម្រាប់បម្រើការនៅក្នុងលេខាធិការដ្ឋាន។ នាយកប្រតិបត្តិក៏អាចជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យាសម្រាប់បំពេញការងារតាមពេលវេលាកំណត់ និងតម្រូវការចាំបាច់នៃសកម្មភាពដើម្បីសម្រេចគោលបំណងរបស់អង្គការ AFoCO

៣- អនុលោមតាមការណែនាំរបស់សភាអង្គការ AFoCO នាយកប្រតិបត្តិក្នុងនាមអង្គការ AFoCO ត្រូវចាត់ចែងការងាររដ្ឋបាលនិងរៀបចំកិច្ចសន្យាផ្សេងៗដើម្បីអនុវត្តសកម្មភាពរបស់អង្គការ AFoCO

៤- លេខាធិការដ្ឋានត្រូវ៖

ក-រៀបចំបទបញ្ជាផ្ទៃក្នុងរបស់លេខាធិការដ្ឋានដើម្បីដាក់ស្នើសុំសភាអង្គការ AFoCO ពិនិត្យនិងសម្រេច

ខ-រៀបចំកិច្ចប្រជុំសភាអង្គការ AFoCO និងអង្គភាពគាំទ្រ និងផ្តល់សេវាកម្មតាមការចាំបាច់

គ- គ្រប់គ្រងថវិកា និងអនុវត្តកម្មវិធីដែលអនុម័តដោយសភាអង្គការ AFoCO

ឃ-រាយការណ៍ជាទៀងទាត់ជូនសភាអង្គការ AFoCO ស្តីពីថវិកា និងវឌ្ឍនភាពនៃការអនុវត្តកម្មវិធី

ង-សម្របសម្រួលការងារជាមួយបណ្តាអង្គភាព និងស្ថាប័នពាក់ព័ន្ធ

ច- ចាត់ចែងឲ្យបានត្រឹមត្រូវចំពោះកិច្ចសហប្រតិបត្តិការវិស័យព្រៃឈើ និងចុះកិច្ចព្រមព្រៀងឬកិច្ចសន្យាជាមួយអង្គការថ្នាក់ជាតិ ថ្នាក់តំបន់ឬអង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល មូលនិធិ និងសមាគម ទាំងក្នុងក្របខណ្ឌសាធារណៈនិងឯកជនដែលស្របទៅតាមកម្មវិធី គម្រោង និងផែនការដែលអនុម័តដោយសភាអង្គការ AFoCO

ឆ- សម្របសម្រួលការរៀបចំគម្រោងសំណើ វាយតម្លៃ និងផ្តល់អនុសាសន៍ជូនសភាអង្គការ AFoCO ដើម្បីពិនិត្យនិងសម្រេច

ជ-អនុវត្តភារកិច្ចផ្សេងៗទៀតរបស់លេខាធិការដ្ឋាន ដែលសម្រេចដោយសភាអង្គការ AFoCO

៥- សាធារណរដ្ឋកូរ៉េដែលជាប្រទេសម្ចាស់ផ្ទះត្រូវផ្តល់ការគាំទ្រ និងជំនួយចាំបាច់ដល់លេខាធិការដ្ឋានអង្គការ AFoCO ចាប់តាំងពីកិច្ចព្រមព្រៀងនេះចូលជាធរមានឲ្យដំណើរទៅរលូន និងមានប្រសិទ្ធភាពដោយគោរពទៅតាមច្បាប់និងបទបញ្ញត្តិ និងទៅតាមសមត្ថភាពថវិការបស់សាធារណរដ្ឋកូរ៉េ។

មាត្រា១០ ៖ ភាសាផ្លូវការ

អង្គការ AFoCO ប្រើប្រាស់ភាសាអង់គ្លេសជាភាសាផ្លូវការ។

មាត្រា១១ ៖ សញ្ញាសំគាល់អង្គការ AFoCO

អង្គការ AFoCO ត្រូវមានទង់សំគាល់និងនិមិត្តសញ្ញារបស់ខ្លួនដែលត្រូវបានអនុម័តពីសភាអង្គការ AFoCO។

មាត្រា១២ ៖ ថវិកានិងហិរញ្ញវត្ថុ

១- ត្រូវមានថវិកាចាំបាច់ដើម្បីសម្រេចបាននូវគោលបំណងរបស់អង្គការ AFoCO ក្នុងនោះរួមមាន ប្រភពមកពីភាគទានកាតព្វកិច្ចនិងភាគទានស្ម័គ្រចិត្ត

២- ភាគទានកាតព្វកិច្ចមានទម្រង់ជាភាគទានផ្សេងៗ ឬជាទម្រង់ភាគទានសាច់ប្រាក់។ សាធារណរដ្ឋកូរ៉េត្រូវចូលរួមភាគទានប៉ែតសិបភាគរយ(៨០%)នៃចំណាយប្រតិបត្តិការប្រចាំឆ្នាំ រីឯភាគីសមាជិកនីមួយៗត្រូវចូលរួមភាគទានមួយភាគរយ(១%)នៃចំណាយប្រតិបត្តិការប្រចាំឆ្នាំឬក្នុងចំនួនកំណត់ដែលមិនតិចជាងបីម៉ឺន(៣០.០០០) ដុល្លារសហរដ្ឋអាមេរិក។ ចំពោះថវិកាដែលនៅខ្វះនឹងត្រូវបំពេញបន្ថែមពីប្រភពផ្សេង។ បរិមាណថវិកាភាគទានកាតព្វកិច្ចពីភាគីសមាជិកនីមួយៗអាចនឹងត្រូវត្រួតពិនិត្យនិងពិភាក្សាក្នុងកំលុងពេលណាមួយដោយសភាអង្គការ AFoCO

៣- ភាគទានផ្សេងៗសំដៅលើភាគទានដែលមិនមែនជាសាច់ប្រាក់។ តម្លៃជាទឹកប្រាក់នៃភាគទាននេះអាចកំណត់បានតាមរយៈការចំណាយលើការចូលរួមកិច្ចប្រជុំផ្លូវការឬព្រឹត្តិការណ៍ផ្សេងៗ ការចំណាយរៀបចំកិច្ចប្រជុំផ្លូវការឬព្រឹត្តិការណ៍ផ្សេងៗរបស់ប្រទេសម្ចាស់ផ្ទះ និងសកម្មភាពផ្សេងៗដែលអនុម័តដោយសភាអង្គការ AFoCO

៤- ភាគីសមាជិកនីមួយៗក៏អាចផ្តល់ភាគទានស្ម័គ្រចិត្តបន្ថែមទៅអង្គការ AFoCO ផងដែរ

៥- សភាអង្គការ AFoCO ត្រូវអនុម័តច្បាប់ហិរញ្ញវត្ថុនិងបទបញ្ញត្តិសម្រាប់គ្រប់គ្រងភាគទានកាតព្វកិច្ចរបស់ភាគីសមាជិក

៦-រាល់ភាគទានទាំងអស់ត្រូវត្រួតពិនិត្យផ្ទៀងផ្ទាត់ប្រចាំឆ្នាំដោយក្រុមហ៊ុនសវនកម្មឯករាជ្យ។ របាយការណ៍សវនកម្មហិរញ្ញវត្ថុត្រូវធ្វើជូនគ្រប់ភាគីសមាជិកទាំងអស់ជាបន្ទាន់តាមដែលអាចធ្វើទៅបាន ប៉ុន្តែមិនឲ្យលើសរយៈពេលប្រាំមួយ(៦)ខែបន្ទាប់ពីការបិទបញ្ចប់ហិរញ្ញវត្ថុប្រចាំឆ្នាំ។

មាត្រា១៣ ៖ បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិរបស់អង្គការ AFoCO

១- អង្គការ AFoCO មានបុព្វសិទ្ធិនិងអភ័យឯកសិទ្ធិសម្រាប់បំពេញមុខងារភារកិច្ចរបស់ខ្លួនដូចដែលមានចែងក្នុងកិច្ចព្រមព្រៀងស្តីពីការកណ្តាលរវាងអង្គការ AFoCO និងប្រទេសម្ចាស់ផ្ទះ។

២- អង្គការ AFoCO អាចធ្វើការសម្រេចចុះកិច្ចព្រមព្រៀងជាមួយភាគីសមាជិកផ្សេងក្រៅពីប្រទេសម្ចាស់ផ្ទះដើម្បីធានាបាននូវបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិសម្រាប់កិច្ចប្រតិបត្តិការនៅក្នុងដែនដីភាគីសមាជិកទាំងនោះ។

មាត្រា១៤ ៖ កិច្ចការពារកម្មសិទ្ធិបញ្ញា

១- កម្មសិទ្ធិបញ្ញាដែលពាក់ព័ន្ធការងារស្រាវជ្រាវនិងអភិវឌ្ឍបច្ចេកវិទ្យា ឬការអភិវឌ្ឍផលិតផល ឬសេវាកម្ម ទាំងឡាយណាដែលបានមកពី៖

ក- ការអនុវត្តរួមគ្នាដោយបណ្តាភាគីសមាជិក ឬលទ្ធផលនៃការងារស្រាវជ្រាវដែលទទួលបានពីកិច្ចប្រឹងប្រែងរួមគ្នាគឺជាកម្មសិទ្ធិរួមរបស់ភាគីសមាជិកទាំងនោះដោយផ្អែកលើលក្ខខណ្ឌដែលបានព្រមព្រៀងគ្នាជាមុន តាមករណីនីមួយៗ

ខ- ការអនុវត្តរបស់ភាគីសមាជិកតែម្នាក់ឯងឬលទ្ធផលនៃការងារស្រាវជ្រាវដែលសម្រេចបានពីកិច្ចប្រឹងប្រែងតែម្នាក់ឯងគឺជាកម្មសិទ្ធិរបស់ភាគីសមាជិកនោះ

២- ក្នុងករណីដែលគ្មានការអនុញ្ញាតជាមុនពីសភាអង្គការ AFoCO ចំពោះការប្រើប្រាស់ឈ្មោះ ស្លាកសញ្ញា ឬនិមិត្តសញ្ញាជាផ្លូវការរបស់អង្គការ AFoCO សម្រាប់ការបោះពុម្ពផ្សាយ និងការចងក្រងឯកសារផ្សេងៗ ដែលមិនពាក់ព័ន្ធនឹងកិច្ចការរបស់អង្គការ AFoCO ត្រូវបានហាមឃាត់។

មាត្រា១៥ ៖ ការដោះស្រាយទំនាស់

រាល់ភាពខុសគ្នា ឬទំនាស់ដែលកើតឡើងពីការបកស្រាយ ការអនុវត្ត ឬការប្រើប្រាស់កិច្ចព្រមព្រៀងនេះត្រូវធ្វើការដោះស្រាយដោយអធ្យាស្រ័យគ្នាតាមរយៈការពិគ្រោះឬកិច្ចចរចាការទូតរវាងភាគីសមាជិកពាក់ព័ន្ធ។

មាត្រា១៦ ៖ ការផ្តល់សច្ចាប័ន ការទទួលស្គាល់ និងការយល់ព្រម

កិច្ចព្រមព្រៀងនេះត្រូវមានការផ្តល់សច្ចាប័ន ឬការទទួលស្គាល់ ឬការយល់ព្រមពីប្រទេសហត្ថលេខី។

មាត្រា១៧ ៖ ការចូលរួមរបស់ប្រទេសផ្សេងៗ

ដូចមានចែងក្នុងមាត្រា២ មាត្រា៣ និងមាត្រា៥ កិច្ចព្រមព្រៀងនេះបើកចំហសម្រាប់ការចូលរួមរបស់ប្រទេសមិនមែនជាប្រទេសហត្ថលេខី។

មាត្រា១៨ ៖ ទីកន្លែងតម្កល់ឯកសារ

រាល់ឯកសារផ្តល់សច្ចាប័ន ឬការទទួលស្គាល់ ឬការយល់ព្រម ឬការចូលរួមកិច្ចព្រមព្រៀងនេះ ត្រូវតម្កល់នៅរដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ។ ឯកសារទាំងនេះត្រូវថតចម្លងដោយធ្វើសេចក្តីបញ្ជាក់ភ្លាមទៅប្រទេសភាគីសមាជិកនីមួយៗនៃកិច្ចព្រមព្រៀងនេះ។ ការតម្កល់ឯកសារនេះជាភារកិច្ចរបស់នាយកប្រតិបត្តិនៃលេខាធិការដ្ឋានអង្គការ AFoCO។

មាត្រា១៩ ៖ ការចូលជាធរមាន

១- កិច្ចព្រមព្រៀងនេះនឹងចូលជាធរមានសាមសិប(៣០)ថ្ងៃបន្ទាប់ពីថ្ងៃតម្កល់លិខិតតូបករណ៍នៃការផ្តល់សច្ចាប័ន ឬការទទួលស្គាល់ ឬការយល់ព្រមពីប្រទេសហត្ថលេខីទី៥ដែលរួមទាំងសាធារណរដ្ឋកូរ៉េ

២- ចំពោះប្រទេសផ្សេងទៀតដែលបានផ្តល់សច្ចាប័ន ឬការទទួលស្គាល់ ឬការយល់ព្រម ឬការចូលរួមជាសមាជិកក្រោយថ្ងៃកិច្ចព្រមព្រៀងនេះចូលជាធរមាន កិច្ចព្រមព្រៀងនេះនឹងចូលជាធរមានសម្រាប់ប្រទេសទាំងនេះ សាមសិប(៣០)ថ្ងៃបន្ទាប់ពីថ្ងៃតម្កល់លិខិតតូបករណ៍ផ្តល់សច្ចាប័នរបស់ខ្លួន។

មាត្រា២០ ៖ ការធ្វើវិសោធនកម្ម

១-ភាគីសមាជិកអាចស្នើសុំធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងនេះដោយជូនដំណឹងជាលាយលក្ខណ៍អក្សរទៅលេខាធិការដ្ឋានអង្គការ AFoCO។ លេខាធិការដ្ឋានត្រូវជូនដំណឹងទៅគ្រប់ភាគីសមាជិកទាំងអស់អំពីសំណើសុំធ្វើវិសោធនកម្មនេះយ៉ាងតិចហុកសិប(៦០)ថ្ងៃមុនការដាក់ពិភាក្សានៅក្នុងសភាអង្គការ AFoCO។ វិសោធនកម្មលើកិច្ចព្រមព្រៀងនេះត្រូវធ្វើការអនុម័តដោយអនុលោមទៅតាមសេចក្តីដូចមានចែងក្នុងកថាខណ្ឌ៧ មាត្រា៨នៃកិច្ចព្រមព្រៀងនេះ

២- វិសោធនកម្មកិច្ចព្រមព្រៀងនេះត្រូវចូលជាធរមានសាមសិប(៣០)ថ្ងៃបន្ទាប់ពីការដាក់តម្កល់ឯកសារផ្តល់សច្ចាប័ន ឬការទទួលស្គាល់ ឬការយល់ព្រមពីភាគីសមាជិកទី៥។ ចំពោះភាគីសមាជិកទាំងឡាយណាដែលផ្តល់សច្ចាប័ន ឬការទទួលស្គាល់ ឬការយល់ព្រមលើការធ្វើវិសោធនកម្មនេះក្រោយថ្ងៃដែលវិសោធនកម្មទាំងនេះចូលជាធរមាន វិសោធនកម្មកិច្ចព្រមព្រៀងនេះនឹងចូលជាធរមានសម្រាប់សមាជិកទាំងនោះ សាមសិប(៣០)ថ្ងៃក្រោយពីការដាក់តម្កល់ឯកសាររបស់ខ្លួន។

មាត្រា២១ ៖ ការចាកចេញពីកិច្ចព្រមព្រៀង

១-ភាគីសមាជិកអាចស្នើសុំចាកចេញពីកិច្ចព្រមព្រៀងនេះដោយផ្តល់ដំណឹងជាលាយលក្ខណ៍អក្សរជូនទៅលេខាធិការដ្ឋានអង្គការ AFoCO។ លេខាធិការដ្ឋានអង្គការ AFoCO ត្រូវជូនដំណឹងជាបន្ទាន់ទៅភាគីសមាជិកទាំងអស់អំពីសំណើសុំចាកចេញពីកិច្ចព្រមព្រៀងនេះ។ ការចាកចេញពីកិច្ចព្រមព្រៀងនេះនឹងមានប្រសិទ្ធភាពក្រោយ ហុកសិប(៦០)ថ្ងៃបន្ទាប់ពីការជូនដំណឹងរបស់លេខាធិការដ្ឋានអង្គការ AFoCO

២- ថ្វីបើមានការកំណត់ថ្ងៃចូលជាធរមាននៃការចាកចេញពីកិច្ចព្រមព្រៀងនេះក៏ដោយភាគីសមាជិកដែលស្នើសុំនោះត្រូវធ្វើការទូទាត់ប្រាក់បំណុលដែលនៅជំពាក់អង្គការ AFoCO ឲ្យបានរួចរាល់ចប់សព្វគ្រប់មុនថ្ងៃចូលជាធរមាននៃការចាកចេញពីកិច្ចព្រមព្រៀងនេះ។

មាត្រា២២ ៖ ការបញ្ចប់កិច្ចព្រមព្រៀង

១-កិច្ចព្រមព្រៀងនេះអាចនឹងត្រូវបញ្ចប់លុះត្រាតែមានការសម្រេចជាឯកច្ឆន្ទដោយសភាអង្គការ AFoCO

២-ការបញ្ចប់កិច្ចព្រមព្រៀងនៅក្នុងកថាខណ្ឌទី១ខាងលើនេះត្រូវចូលជាធរមានក្នុងរយៈពេល១២ខែបន្ទាប់ពីការសម្រេចចិត្តបញ្ចប់កិច្ចព្រមព្រៀង។ បើមិនដូច្នេះទេលើកលែងតែមានការសម្រេចផ្សេងទៀតជាឯកច្ឆន្ទរបស់សភាអង្គការ AFoCO

៣- ការបញ្ចប់កិច្ចព្រមព្រៀងនេះនឹងមិនប៉ះពាល់ដល់ការអនុវត្តគម្រោង ឬកម្មវិធី និងសកម្មភាពកំពុងដំណើរការដែលព្រមព្រៀងគ្នាមុនថ្ងៃបញ្ចប់កិច្ចព្រមព្រៀងនេះឡើយ លើកលែងតែមានការសម្រេចផ្សេងទៀតជាឯកច្ឆន្ទរបស់សភាអង្គការ AFoCO។

ដើម្បីជាសក្ខីភាព តំណាងរដ្ឋាភិបាលនៃប្រទេសនីមួយៗបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងដូចខាងក្រោម។ កិច្ចព្រមព្រៀងនេះត្រូវបានរៀបចំជាភាសាអង់គ្លេស។

តំណាងរដ្ឋាភិបាលនៃរាជាណាចក្រប៊ូតង់ (ហត្ថលេខាថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦)
តំណាងរដ្ឋាភិបាលនៃប្រទេសព្រុយណេ (ហត្ថលេខាថ្ងៃទី៨ ខែឧសភា ឆ្នាំ២០១៧)
តំណាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា (ហត្ថលេខាថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៧)

តំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋឥណ្ឌូណេស៊ី (ហត្ថលេខាថ្ងៃទី២ ខែសីហា ឆ្នាំ២០១៦)
តំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋកាហ្សាក់ស្ថាន (ហត្ថលេខាថ្ងៃទី ខែ ឆ្នាំ)
តំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ (ហត្ថលេខាថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៥)
តំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋ ប្រជាធិបតេយ្យ ប្រជាមានិតឡាវ (ហត្ថលេខាថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៨)
តំណាងរដ្ឋាភិបាលនៃប្រទេសម៉ុងហ្គោលី (ហត្ថលេខាថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៧)
តំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋសហព័ន្ធមីយ៉ាន់ម៉ា (ហត្ថលេខាថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៧)
តំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋហ្វីលីពីន (ហត្ថលេខាថ្ងៃទី ខែ ឆ្នាំ)
តំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋសិង្គបុរី (ហត្ថលេខាថ្ងៃទី ខែ ឆ្នាំ)
តំណាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ (ហត្ថលេខាថ្ងៃទី ខែ ឆ្នាំ)
តំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាធិបតេយ្យទីម័រខាងកើត (ហត្ថលេខាថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៦)
តំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម (ហត្ថលេខាថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៦)

AGREEMENT ON THE ESTABLISHMENT OF THE ASIAN FOREST COOPERATION ORGANIZATION (AFoCO)

Preamble

The Parties to this Agreement,

RECALLING the forest-related decisions adopted at the United Nations Conference on Environment and Development in 1992, the World Summit on Sustainable Development in 2002, and the United Nations Conference on Sustainable Development in 2012 (Rio+20), as well as the provisions of the United Nations Convention to Combat Desertification in States Experiencing Serious Drought and/or Desertification/Land Degradation, opened for signature on 14 October 1994, the Ramsar Convention on Wetlands of International Importance Especially as Waterfowl Habitat which was opened for signature on 2 February 1971, the Convention on Biological Diversity and the United Nations Framework Convention on Climate Change which was opened for signature on 4 June 1992;

ALSO RECALLING the proposals for action of the Intergovernmental Panel on Forests and the Intergovernmental Forum on Forests and the Resolutions and Decisions of the United Nations Forum on Forests as well as the Non-legally Binding Instrument on All Types of Forests;

WELCOMING the Sustainable Development Goals, as guided by the United Nations Conference on Sustainable Development in 2012 (Rio+20), to be integrated into the United Nations post-2015 development agenda;

CONSIDERING the urgent need for closer cooperation on forests among the Parties in Asia to contribute to the expansion of forestlands, the advanced study of forests, forestry and forest rehabilitation as well as to strengthen the capacities of the Parties in coping with global climate change issues;

RECOGNIZING that all Parties play significant roles in restoring and rehabilitating degraded lands, promoting sustainable forest management and combating desertification/land degradation, and the progress in that respect depends on the effective implementation of national forestry action programs;

ACKNOWLEDGING the great potential of the Green Growth initiatives, the past achievements and future potential of reforestation and forest rehabilitation, the progress made in the development of sustainable forest management practices and the potential for the improvement of forest governance in Asia;

FURTHER RECALLING the proposal by the Republic of Korea to establish the Asian Forest Cooperation Organization at the ASEAN-ROK Commemorative Summit on 1-2 June 2009, held on Jeju Island, Republic of Korea;

ALSO ACKNOWLEDGING the achievements and outcomes of the dialogue for the establishment of the Asian Forest Cooperation Organization carried out under the Agreement between the Governments of the Member States of the Association of the Southeast Asian Nations and the Republic of Korea on Forest Cooperation (hereinafter referred to as the "AFoCo Agreement"), which entered into force on 5 August 2012; and

ALSO WELCOMING the decision of the Third Session of the Governing Council of the AFoCo Agreement to invite the ASEAN Member States, Bhutan, Kazakhstan, Mongolia, Timor-Leste, and the Republic of Korea to the dialogue for the establishment of the Asian Forest Cooperation Organization,

HAVE AGREED on the following:

Article 1
Definition of Terms

For the purposes of this Agreement:

a) "Agreement" means the Agreement on the Establishment of the Asian Forest Cooperation Organization (AFoCO);
b) "Organization" means the Asian Forest Cooperation Organization (hereinafter referred to as the "AFoCO") established under this Agreement;
c) "Assembly" means the highest decision-making organ of the Organization comprising representatives appointed by the Parties to this Agreement;
d) "Executive Director" means the chief administrative officer of the Organization who is appointed by the Assembly;
e) "Secretariat" means the body which shall provide administrative support to the Organization as well as carry out the activities guided by the Assembly;
f) "Signatory Country" means a country which has signed this Agreement, and yet to deposit the instrument of ratification, acceptance, or approval of it;
g) "Party" means a Signatory Country, which has deposited an instrument of ratification, acceptance, or approval and for which this Agreement has entered into force, or a country acceded to this Agreement;

h) "Observer" means a country or an organization which has been granted the Observer status by the Assembly;
i) "Representative" means a senior forestry official nominated by a Party to the Agreement to represent the Party in the Assembly;
j) "Host Country" means the country where the headquarters of the Organization is located; and
k) "Operational Expenditure" means the costs for the functioning of the Assembly, Secretariat and subsidiary bodies of the Organization.

Article 2
Establishment

1. The Organization is hereby established as an intergovernmental organization in accordance with the provisions of this Agreement.

2. The Headquarters of the Organization, including the Secretariat, shall be located in the Republic of Korea. A separate "Headquarters Agreement" shall be concluded between the Government of the Republic of Korea and the Organization.

Article 3
Objectives

1. The Organization shall be established to strengthen regional forest cooperation by transforming proven technology and policies into concrete actions in the context of sustainable forest management to address the impact of climate change.

2. The Organization shall promote and undertake action-oriented forest cooperation programs in Asia on:
a) sustainable forest management, biodiversity conservation, maintenance and enhancement of ecosystem services, as well as reforestation and forest rehabilitation;
b) climate change mitigation and adaptation activities and supporting the initiatives under REDD+(Reducing Emissions from Deforestation and Forest Degradation, and the role of forest conservation, sustainable management of forests and enhancement of forest carbon stocks in developing countries);
c) reduction of deforestation, forest degradation, desertification and land degradation, and mitigation of the impacts of forest-related disasters;

d) capacity building of stakeholders through research and development, sharing of experiences and the transfer of technology, as well as education and exchange programs; and

e) partnerships between the Parties and with other entities to carry out cooperative activities by building upon the current initiatives of other forest-related international agreements and organizations.

Article 4
Legal Capacity

The Organization shall have legal personality and shall have the capacity, as may be necessary for the exercise of its functions and the fulfillment of its purposes, in particular:

a) to enter into agreements and contracts;

b) to acquire and dispose of movable and immovable property; and

c) to institute, and defend in, legal proceedings.

Article 5
Membership

1. The Signatory Countries shall become Parties to this Agreement after they have deposited an instrument of ratification, acceptance, or approval. The Parties to this Agreement shall be the members of the Organization.

2. A non-Signatory Country intending to become a new member of the Organization shall, prior to its accession to this Agreement, seek an approval of its membership by the Assembly.

3. The membership in the Organization is open to a country which is geographically located in Asia.

Article 6
Observers

1. Observer status may be granted by the Assembly to:

a) Signatory Countries which have not deposited instruments of ratification, acceptance or approval;
b) Other Asian countries which have submitted an application to be an Observer; and
c) International organizations and non-governmental organizations acting in the field of forestry.

2. Matters related to the participation of Observers to the activities of the Organization may be decided by the Assembly in accordance with the internal regulations of the Organization.

Article 7
Organs and Subsidiary Bodies

1. The principal organs of the Organization shall be the Assembly and a Secretariat.

2. Subsidiary bodies may be established upon approval by the Assembly in accordance with Article 8 of this Agreement.

Article 8
The Assembly

1. The Assembly shall be comprised of the Representatives of all Parties.

2. Each Party shall appoint one (1) Representative to the Assembly. The Assembly shall elect its President and Vice-President on the rotating basis for a period of one year term.

3. The Assembly shall have an annual meeting and, if necessary, special sessions. A special session shall be convened by the President at the request of a simple majority of the Parties.

4. The Assembly shall, at its first meeting, adopt the internal regulations of the Organization.

5. The Assembly shall, at its first meeting, elect and appoint the Executive Director of the Secretariat.

6. The Assembly shall:

a) adopt and, if necessary, amend the internal regulations of the Organization;
b) appoint the Executive Director of the Secretariat;
c) approve the establishment of subsidiary bodies that are necessary for the achievement of the objectives of the Organization;
d) approve the program and budget for the activities of the Organization;
e) review reports submitted by the Executive Director and the subsidiary bodies of the Organization and provide guidance to them;
f) promote and strengthen relationships with other relevant organizations while avoiding duplication of efforts;
g) deliberate and adopt amendments to the Agreement proposed by any Party/Parties in accordance with Article 20 of this Agreement;
h) approve applications for observer status;
i) approve the membership of a non-Signatory Country; and
j) exercise such other functions as necessary for the achievement of the objectives of the Organization.

7. The Assembly shall decide on the proposed amendments to the Agreement and approve the membership of new Parties by consensus.

8. The Assembly shall make every effort to reach decisions by consensus. If a decision cannot be reached by consensus for matters other than those mentioned in Paragraph 7, a flexible formula shall be determined by the Assembly to reach a decision.

Article 9
The Secretariat

1. Upon entry into force of the Agreement, the Secretariat shall be formed. The Secretariat shall be headed by an Executive Director. The Executive Director shall hold the office for a term of two (2) years, and renewable for not more than one (1) term.

2. Subject to internal regulations of the Organization, the Executive Director shall appoint the staff members of the Secretariat. Non-staff personnel shall also be

appointed by the Executive Director, on specific terms and assigned duties that are necessary towards achieving the objectives of the Organization.

3. Subject to guidance by the Assembly, the Executive Director shall enter into administrative and contractual arrangements on behalf of the Organization for the implementation of the activities of the Organization.

4. The Secretariat shall:

a) prepare and propose, the internal regulations of the Secretariat for consideration by the Assembly;
b) make arrangements for sessions of the Assembly and other subsidiary bodies of the Organization and provide the necessary services;
c) manage the budget and implement the programs approved by the Assembly;
d) report to the Assembly on the budget and progress of the implementation of the programs on a regular basis;
e) coordinate its activities with other relevant bodies and entities;
f) make appropriate arrangements for forest-related cooperation and enter into agreements or contracts with relevant national, regional or international organizations, non-governmental organizations, foundations and associations, both public and private which are in line with the programs, projects, and work plans approved by the Assembly;
g) facilitate preparation, evaluation and recommendation of proposals which are to be considered by the Assembly; and
h) perform other secretariat functions as may be decided by the Assembly.

5. The Republic of Korea, as the Host Country, shall provide secretariat support and the necessary assistance for the period between the dates of the entry into force of this Agreement and the establishment of the Secretariat to ensure the smooth and effective operationalization of the Organization, in accordance with its domestic laws and regulations and within its budgetary capacities.

Article 10

Official Language

The official language of the Organization shall be English.

Article 11
Organization Symbol

The Organization shall have a flag and an emblem to be decided upon by the Assembly.

Article 12
Budget and Finance

1. The funds necessary to achieve the objectives of the Organization shall consist of mandatory and voluntary contributions.

2. Mandatory contributions shall be provided in the form of in-kind contributions and/or cash. The Republic of Korea shall contribute eighty percent (80%) of the annual Operational Expenditures, whereas the other Parties shall each contribute one percent (1%) of the annual Operational Expenditures or a fixed amount of not less than thirty thousand US dollars (USD 30,000). The remaining contributions shall be provided by other sources. The amount of mandatory contributions by each Party may be subject to periodic review by the Assembly.

3. In-kind contributions refer to non-monetary contributions, the value of which can be attributed to the costs of attending official meetings or events, hosting official meetings or events and other activities as may be determined and approved by the Assembly.

4. Parties may make additional voluntary contributions to the Organization.

5. The Assembly shall adopt the financial rules and regulations, including rules governing the mandatory contributions of the Parties, which shall specify the conditions for the management of the funds.

6. The funds shall be subject to an independent external audit on an annual basis. The audited financial statements shall be made available to Parties as soon as possible after the end of each financial year, but not later than six (6) months after that date.

Article 13

Privileges and Immunities of the Organization

1. The Organization shall enjoy such privileges and immunities for the proper functioning of the Organization, as agreed in the Headquarters Agreement between the Organization and the Host Country.

2. The Organization may conclude agreements with concerned Parties other than the Host Country in order to secure appropriate privileges and immunities in the territories of those Parties.

Article 14
Protection of Intellectual Property Rights

1. The intellectual property rights in respect of any research and technological development, or products or services development:
   a) carried out jointly by the Parties, or research results obtained through the joint activity effort of the Parties, shall be jointly owned by such Parties in accordance with terms mutually agreed upon on a case to case basis; and
   b) implemented solely and separately by a Party, or the research results obtained through the sole and separate effort of an individual Party, shall be owned by the Party concerned.

2. The use of the name, logo and/or official emblem of the Organization on any publication, document and/or paper not related to the Organization is prohibited without the prior approval of the Assembly.

Article 15
Settlement of Disputes

Any difference or dispute concerning the interpretation, implementation and/or application of this Agreement shall be settled amicably through mutual consultation and/or negotiation between the Parties concerned through diplomatic channels.

Article 16
Ratification, Acceptance and Approval

This Agreement shall be subject to ratification, acceptance or approval by the Signatory Countries.

Article 17
Accession

Subject to Paragraph 2 and 3 of Article 5, this Agreement shall be open for accession by any non-Signatory Country.

Article 18
Depositary

Instruments of ratification, acceptance or approval of, or accession to this Agreement shall be deposited with Government of the Republic of Korea, which shall promptly furnish a certified copy thereof, to each Party to this Agreement. The function of Depositary shall be delegated to the Executive Director of the Secretariat after he/she has been elected and appointed.

Article 19
Entry into Force

1. This Agreement shall enter into force on the thirtieth (30th) day after the date of deposit of the fifth (5th) instrument of ratification, acceptance or approval including that of the Republic of Korea.

2. For any country that ratifies, accepts, approves or accedes to this Agreement after the date of its entry into force, the Agreement shall take effect on the thirtieth (30th) day after the date of deposit of its respective instrument.

Article 20
Amendments

1. Any Party may propose amendments to this Agreement by notifying the Secretariat in writing. Proposed amendments shall be communicated by the Secretariat to all Parties at least sixty (60) days prior to their deliberation by the

Assembly. Amendments to the Agreement shall be adopted in accordance with Paragraph 7 of Article 8 of this Agreement.

2. Amendments shall enter into force on the thirtieth (30th) day after the date of deposit of the fifth (5th) instrument of ratification, acceptance or approval of the amendments. For other Parties which ratify, accept, or approve the amendments after they have entered into force, the amendments shall come into effect on the thirtieth (30th) day after the date of deposit of their respective instrument.

Article 21
Withdrawal

1. Any Party may withdraw from this Agreement by giving a written notification to the Secretariat which shall immediately communicate the notification to all Parties. Such withdrawal shall take effect sixty (60) days after the date of the receipt of such notification by the Secretariat.

2. Notwithstanding the effective date of withdrawal, the withdrawing Party shall complete the payment of any previously assessed financial dues it owes to the Organization before the effective date of withdrawal.

Article 22
Termination

1. This Agreement may be terminated through a unanimous decision by the Assembly.

2. The termination of this Agreement under Paragraph 1 shall take effect after twelve (12) months following the decision for termination, unless otherwise decided unanimously by the Assembly.

3. The termination of this Agreement shall not affect the implementation of any ongoing projects or programs and activities, which have been agreed upon before the date of termination of the Agreement, and not fully executed at the time of termination of this Agreement, unless otherwise agreed unanimously by the Assembly.

IN WITNESS WHEREOF, the undersigned, duly authorized thereto by their respective Governments, have signed this Agreement.

Done in the English language.

For the Government of the Kingdom of Bhutan

Date of Signature : 2016/09/13

For the Government of Brunei Darussalam

Date of Signature : 2017/05/08

For the Government of the Kingdom of Cambodia

Date of Signature : 16/02/2017

For the Government of the Republic of Indonesia

Date of Signature : AUGUST, 2nd, 2016

For the Government of the Republic of Kazakhstan

_____ Date of Signature : _____

For the Government of the Republic of Korea

_____ Date of Signature : December 10, 2015

For the Government of the Lao People's Democratic Republic

_____ Date of Signature : 13/8/018.

For the Government of Mongolia

_____ Date of Signature : August 21, 2017

For the Government of the Republic of the Union of Myanmar

_____ Date of Signature : July 31/17

For the Government of the Republic of the Philippines

_____ Date of Signature : _____

For the Government of the Republic of Singapore

_____ Date of Signature : _____

For the Government of the Kingdom of Thailand

_____ Date of Signature : _____

For the Government of the Democratic Republic of Timor-Leste

_____ Date of Signature : 20/06/16

For the Government of the Socialist Republic of Viet Nam

_____ Date of Signature : 17/10/2016

ព្រះរាជក្រឹត្យ

នស/រកត/០៥១៨/៤៨៩

ស្តីពី

ឯកសណ្ឋានក្លិចសវនាការជំនុំជម្រះ ឬកិច្ចប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាធម្មនុញ្ញ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

សហានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ

ខេមរាជនា សម្ភហោរាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា

ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣១៨/០០៥ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្ម មាត្រា២៦ មាត្រា២៧ថ្មី មាត្រា២៨ មាត្រា៣១ និងមាត្រា៣២ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦១៦/៦១៦ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៦ ស្តីពីការតែងតាំងប្រធានក្រុមប្រឹក្សាធម្មនុញ្ញសម្រាប់អាណត្តិ៣ឆ្នាំលើកទី៧ (ឆ្នាំ២០១៦ ដល់ឆ្នាំ ២០១៩)
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ ឯកឧត្តម អ៊ីម ឈុនលឹម ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

ក្រសួងបន្ទាយ

ជំពូកទី១
បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

ព្រះរាជក្រឹត្យនេះ មានគោលបំណងបង្កើត និងកំណត់ឱ្យប្រើប្រាស់នូវឯកសណ្ឋានក្នុងសវនាការជំនុំជម្រះ ឬកិច្ចប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ដែលរួមមាន ឯកសណ្ឋានរបស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ឯកសណ្ឋានរបស់សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ និងឯកសណ្ឋានរបស់គណៈលេខាធិការនៃសវនាការជំនុំជម្រះ ឬកិច្ចប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាធម្មនុញ្ញ។

ជំពូកទី២
ឯកសណ្ឋានរបស់ក្រុមប្រឹក្សាធម្មនុញ្ញ និងឯកសណ្ឋានរបស់គណៈលេខាធិការ ក្នុងសវនាការជំនុំជម្រះ ឬកិច្ចប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាធម្មនុញ្ញ

មាត្រា ២.-

ឯកសណ្ឋានរបស់ក្រុមប្រឹក្សាធម្មនុញ្ញក្នុងសវនាការជំនុំជម្រះ ឬកិច្ចប្រជុំពេញអង្គ គឺអាវផ្ទាយគ្របពីលើអាវកុតពណ៌ខ្មៅ ឡេវមាសត្រាព្រះរាជសង្ហា ខោជើងវែងពណ៌ខ្មៅ ស្បែកជើងឃ្លុប កន្ទីពណ៌ខ្មៅ សម្រាប់ប្រធាន ឬសមាជិកក្រុមប្រឹក្សាធម្មនុញ្ញជាបុរស និងអាវកុតពណ៌ខ្មៅ ឡេវមាសត្រាព្រះរាជសង្ហា សំពត់សំឡូយពណ៌ខ្មៅ ស្បែកជើងអេស្តាប៉ុងពណ៌ខ្មៅ សម្រាប់ប្រធាន ឬសមាជិកក្រុមប្រឹក្សាធម្មនុញ្ញជានារី។

ក- អាវផ្ទាយរបស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

- មានដៃវែង ពណ៌ក្រហមក្រមៅចាស់ គ្មានឡេវ សម្រុងចុះត្រឹមស្មុងជើង មានក្បាច់ភ្ជីទេសពណ៌មាសក្នុងទម្រង់ជាចង្វាយប្រទាក់ មានក្បាច់ទម្រង់ផ្កាឈូកនៅចំកណ្តាល។ ក្បាច់ភ្ជីទេសនេះ ព័ទ្ធលើដើមកសំយុងចុះតាមដើមទ្រូងផ្នែកខាងមុខ រហូតដល់ចុងជាយអាវ និងព័ទ្ធជាយអាវផ្នែកខាងក្រោយកំភួនជើងរួមបានមួយជុំជាយអាវផាយ។ ក្បាច់ភ្ជីទេសនៅជាយអាវផាយនេះ មានអមសងខាងដោយខ្សែសយ[illegible]ពណ៌មាស[illegible] នៅកណ្តាលខ្សែទឹកមាស។ នៅលើផ្នែកអាវទាំងមូល មានរំលេចនូវផ្កាឈូកពណ៌មាសតូចៗ[illegible]ប្រហែលគ្នា ត្រៀបគ្នាដោយរៀបរយល្អ

- នៅក្នុងវង់ក្បាច់ភ្ជីទេសជាយអាវផ្ចាយត្រង់ដើមទ្រូងខាងឆ្វេង មានរំលេចនូវផ្កាឈូកជាមួយគម្ពីរ ដែលជាកេតនភណ្ឌនៅព្រះហស្តខាងឆ្វេងទាំងពីររបស់ព្រះព្រហ្ម។ ចំណែកនៅក្នុងវង់ក្បាច់ភ្ជីទេសជាយអាវផ្ចាយត្រង់ដើមទ្រូងខាងស្តាំ មានរំលេចនូវពួចទ៉ីកនិងផ្កាំ ដែលជាកេតនភណ្ឌនៅព្រះហស្តខាងស្តាំទាំងពីររបស់ព្រះព្រហ្ម

- នៅដើមដៃទាំងពីរនៃអាវផ្ចាយ និងនៅចុងដៃអាវទាំងពីរនៃអាវផ្ចាយ មានព័ទ្ធក្បាច់ភ្ជីទេសមួយជុំ ដែលមានទម្រង់ និងក្បាច់រចនាដូចគ្នានឹងក្បាច់ភ្ជីទេស ដែលប្រើជាផ្ចាយអាវផ្ចាយដែរ។

រូបគំនូរអាវផ្ចាយរបស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ មានគំរូដូចក្នុងឧបសម្ព័ន្ធទី១ នៃព្រះរាជក្រឹត្យនេះ។

២- អាវផ្ចាយរបស់សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ

អាវផ្ចាយរបស់សមាជិកក្រុមប្រឹក្សាធម្មនុញ្ញក្នុងសវនាការជំនុំជម្រះ ឬកិច្ចប្រជុំពេញអង្គ មានសណ្ឋានទ្រង់ទ្រាយដូចគ្នានឹងអាវផ្ចាយរបស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញដែរ ប្លែកតែនៅលើផ្ទៃអាវទាំងមូលមិនមានរំលេចនូវផ្កាឈូកតូចៗពណ៌មាស (ផ្ការាបណ្តែត)។

រូបគំនូរអាវផ្ចាយរបស់សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ មានគំរូដូចក្នុងឧបសម្ព័ន្ធទី២ នៃព្រះរាជក្រឹត្យនេះ។

រូបគំនូរផ្កាឈូកពណ៌មាសលើផ្ទៃអាវផ្ចាយរបស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ និងគំនូរកេតនភណ្ឌព្រះព្រហ្ម ដែលរចនានៅលើក្បាច់ភ្ជីទេសជាយអាវផ្ចាយផ្នែកដើមទ្រូងទាំងពីរ ជាឯកសណ្ឋានរបស់ក្រុមប្រឹក្សាធម្មនុញ្ញ មានគំរូដូចក្នុងឧបសម្ព័ន្ធទី៣ នៃព្រះរាជក្រឹត្យនេះ។

មាត្រា ៣.-

ក្រុមប្រឹក្សាធម្មនុញ្ញ អាចប្រើផងដែរនូវកន្លាស់និមិត្តសញ្ញាសម្គាល់ក្រុមប្រឹក្សាធម្មនុញ្ញ ជាមួយអាវផ្ចាយនេះ។ ការប្រើកន្លាស់និមិត្តសញ្ញាសម្គាល់ក្រុមប្រឹក្សាធម្មនុញ្ញ គឺប្រើនៅលើអាវផ្ចាយផ្នែកទ្រូងខាងឆ្វេង។

មាត្រា ៤.-

ឯកសណ្ឋានរបស់គណៈលេខាធិការនៃសវនាការជំនុំជម្រះ ឬកិច្ចប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាធម្មនុញ្ញ គឺអាវផ្ចាយ ក្រៅពីលើអាវកុតពណ៌ដូចពណ៌សំបកផ្លែមង្ឃុត ឡេវមាសត្រាព្រះរាជសង្ហា ខោជើងវែងពណ៌ដូចពណ៌អាវ ស្បែកជើងឃ្លុប កន្ទីពណ៌ខ្មៅ សម្រាប់លេខាធិការ ឬជំនួយការលេខាធិការ

ជាបុរស និងអាវកុតពណ៌ដូចពណ៌សំបកផ្លែមង្ឃុត ឡេវមាសក្រាព្រះរាជសង្ហា សំពត់សំឡៃពណ៌ដូចពណ៌អាវ ស្បែកជើងអេស្តាប៉ុងពណ៌ខ្មៅ សម្រាប់លេខាធិការ ឬជំនួយការលេខាធិការ ជានារី។

ក-អាវផាយរបស់លេខាធិការ

- មានដៃវែង ពណ៌ដូចពណ៌កាកអំពៅ គ្មានឡេវ សម្រុងចុះត្រឹមស្មងជើង មានក្បាច់ភ្ជីទេសពណ៌មាស ក្នុងទម្រង់ជាសន្លឹកឈើតម្រៀបលើគ្នា ជាជួរបញ្ជិតមានទងចុះក្រោម។ ក្បាច់ភ្ជីទេសនេះ ព័ទ្ធលើដើមក សំយុងចុះតាមដើមទ្រូងផ្នែកខាងមុខរហូតដល់ចុងជាយអាវ និងព័ទ្ធជាយអាវផ្នែកខាងក្រោយ កំភួនជើងគម្រប់បានមួយជុំជាយអាវផាយ។ ក្បាច់ភ្ជីទេសនៅជាយអាវផាយនេះ មានអមសងខាងដោយខ្សែសយពណ៌មាស នៅកណ្តាលខ្សែទឹកមាស
- នៅលើក្បាច់ភ្ជីទេសជាយអាវផាយផ្នែកដើមទ្រូងសងខាង មានផ្កាឈូកពណ៌មាសចំនួនពីរ ទម្រង់ដូចផ្កាឈូកបណ្តែត ដែលប្រើលើផ្ទៃអាវផាយរបស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ
- នៅដើមដៃទាំងពីរនៃអាវផាយ និងនៅចុងដៃអាវទាំងពីរនៃអាវផាយ មានក្បាច់ភ្ជីទេសព័ទ្ធមួយជុំ ដែលក្បាច់ភ្ជីទេសនេះ មានទម្រង់ និងក្បាច់រចនាដូចគ្នានឹងក្បាច់ភ្ជីទេសដែលប្រើជាជាយអាវផាយដែរ។

រូបគំនូរអាវផាយរបស់លេខាធិការ មានគំរូដូចក្នុងឧបសម្ព័ន្ធទី៤ នៃព្រះរាជក្រឹត្យនេះ។

ខ-អាវផាយរបស់ជំនួយការលេខាធិការ

អាវផាយរបស់ជំនួយការលេខាធិការ មានសណ្ឋានទ្រង់ទ្រាយដូចនឹងអាវផាយរបស់លេខាធិការដែរ ប្លែកតែនៅលើក្បាច់ភ្ជីទេសជាយអាវផាយផ្នែកទ្រូងសងខាង មិនមានរំលេចផ្កាឈូកពណ៌មាសចំនួនពីរនោះឡើយ។

រូបគំនូរអាវផាយរបស់ជំនួយការលេខាធិការ មានគំរូដូចក្នុងឧបសម្ព័ន្ធទី៥ នៃព្រះរាជក្រឹត្យនេះ។

មាត្រា ៥.-

លេខាធិការ ឬជំនួយការលេខាធិការនៃសវនាការជំនុំជម្រះ ឬកិច្ចប្រជុំពេញអង្គរបស់ក្រុមប្រឹក្សា-ធម្មនុញ្ញ អាចប្រើផងដែរ នូវកន្លាស់និមិត្តសញ្ញាសម្គាល់មន្ត្រីអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ ជាមួយអាវផាយនេះ។ ការប្រើប្រាស់កន្លាស់នេះ គឺប្រើនៅលើអាវផាយផ្នែកទ្រូងខាងឆ្វេង។

ជំពូកទី៣

របបកំណត់ឯកសណ្ឋានរបស់ក្រុមប្រឹក្សាធម្មនុញ្ញ និងឯកសណ្ឋានរបស់គណៈលេខាធិការ ក្នុងសវនាការជំនុំជម្រះ ឬកិច្ចប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាធម្មនុញ្ញ

មាត្រា ៦. -

ត្រូវបានផ្តល់ជូនក្រុមប្រឹក្សាធម្មនុញ្ញ និង គណៈលេខាធិការ នូវឯកសណ្ឋានក្នុងសវនាការជំនុំជម្រះ ឬកិច្ចប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ទៅតាមតម្រូវការជាក់ស្តែង។

ជំពូកទី៤

អាជ្ញាធរ

មាត្រា ៧. -

ឯកសណ្ឋានក្នុងសវនាការជំនុំជម្រះ ឬកិច្ចប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ដូចមានកំណត់នៅក្នុងព្រះរាជក្រឹត្យនេះ ត្រូវយកទៅប្រើប្រាស់ភ្លាម ក្រោយពេលព្រះរាជក្រឹត្យចូលជាធរមាន។

មាត្រា ៨. -

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា តទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆការ
នរោត្តម សីហមុនី

ភាសា.១៧០៤.៤១៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០១៨

លេខ: ៦១១ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
ថ្ងៃពុធ ១រោជ ខែដាច ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៨
អគ្គលេខាធិការនៃរដ្ឋាភិបាល

សយ សុខា

ឧបសម្ព័ន្ធទី១ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៤១៨/៤៨៩
ចុះថ្ងៃទី២៤ ខែ ១០ ឆ្នាំ២០១៨
ស្តីពីឯកសណ្ឋានក្នុងសវនាការជំនុំជម្រះ ឬកិច្ចប្រជុំពេញអង្គ របស់ក្រុមប្រឹក្សាធម្មនុញ្ញ

រូបគំនូរអាវផាយរបស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ



រូបគំនូរពាក្យកត្សាចំរ្ងីទេសជាយអាវផាយ



ឧបសម្ព័ន្ធទី២ នៃព្រះរាជក្រឹត្យលេខ នស/រកត/ ០៥១៨ ០៤០៨
ចុះថ្ងៃទី ២៥ ខែ ១ សីហា ឆ្នាំ២០១៨
ស្តីពីឯកសណ្ឋានក្នុងសវនាការជំនុំជម្រះ ឬកិច្ចប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាធម្មនុញ្ញ

រូបគំនូរអាវផាយរបស់សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ



រូបគំនូរពាក្យកត្បាច់ភ្ជីទេសជាយអាវផាយ

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

ឧបសម្ព័ន្ធទី៣ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥១៨ ១៥៨៥
ចុះថ្ងៃទី២៥ ខែ ០ សីហា ឆ្នាំ២០១៨
ស្តីពីឯកសណ្ឋានក្នុងសវនាការជំនុំជម្រះ ឬកិច្ចប្រជុំពេញអង្គ របស់ក្រុមប្រឹក្សាធម្មនុញ្ញ

រូបគំនូរផ្លាយសួតពណ៌មាស (ផ្ទាបណ្តែត) លើអាវផាយរបស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

រូបគំនូរពេកនតណ្ឌព្រះព្រហ្មដែលប្រើនៅលើបាវចំណាំទ្វីទេសជាយអាវផាយ

ខាងស្តាំ



ខាងឆ្វេង

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

ឧបសម្ព័ន្ធទី៤ នៃព្រះរាជក្រឹត្យលេខ នស/រកត/ ០៨១៨ /៤៨៩

ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៨

ស្តីពីឯកសណ្ឋានក្នុងសវនាការជំនុំជម្រះ ឬកិច្ចប្រជុំពេញអង្គ របស់ក្រុមប្រឹក្សាធម្មនុញ្ញ

រូបគំនូរអាវផាយរបស់លេខាធិការ



រូបគំនូរពាក្យកត្សាច់ភ្ជីទេសជាយអាវផាយ

ឧបសម្ព័ន្ធទី៥ នៃព្រះរាជក្រឹត្យលេខ នស/រកត/ ០៥១៨ /៥៨៩
ចុះថ្ងៃទី ២៥ ខែ ១ ឆ្នាំ ២០១៨
ស្តីពីឯកសណ្ឋានក្នុងសវនាការជំនុំជម្រះ ឬកិច្ចប្រជុំពេញអង្គ របស់ក្រុមប្រឹក្សាធម្មនុញ្ញ

រូបគំនូរអាវផាយរបស់ចំនួយការលេខាធិការ



រូបគំនូរពាក្យ៣ភ្ជាប់ភ្ជីទេសជាយអាវផាយ

ព្រះរាជក្រឹត្យ

នស/រកត/០៦១៨/៦០៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានតូមិជាតិសាសនា រក្ខតខត្តិយា ខេមរៈរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ងហោតាស អម្ពុជ្ជឯករាជរដ្ឋបូរណសន្តិ សុតមន្ត្ណា សិរីវិបុណ្ណ
ខេមរាស្រីពិរាស្ត្ត ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ ៖ តម្លើងឋានន្តរស័ក្តិ **ឧត្តមសេនីយ៍ត្រី** ជល់នាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ១៨រូប ៖

១-	វរសេនីយ៍ឯក **ហយ ម៉ុនឫទ្ធ**	អត្តលេខ	០៦១៥១
២-	វរសេនីយ៍ឯក **ចន្ទ សំបូរ**	អត្តលេខ	០៧១២៧
៣-	វរសេនីយ៍ឯក **ឆ្យុត ចន្ថា**	អត្តលេខ	០៧៥៩៣
៤-	វរសេនីយ៍ឯក **ឆង់ រ៉ូ**	អត្តលេខ	០៨៣២១
៥-	វរសេនីយ៍ឯក **ប្រាក់ សុផាត**	អត្តលេខ	៥៤៨៧២
៦-	វរសេនីយ៍ឯក **សារី បុត្រសត្យា**	អត្តលេខ	៥៥៦០២
៧-	វរសេនីយ៍ឯក **ហៀម ដារ៉ាត់**	អត្តលេខ	៥៦៣៤១
៨-	វរសេនីយ៍ឯក **ព្រហ្ម ចាន់ថា**	អត្តលេខ	៥៦៦៤៧
៩-	វរសេនីយ៍ឯក **រស់ ណារិទ្ធ**	អត្តលេខ	៦០២៥២

ROYAUME DU CAMBODGE MINISTERE DU PALAIS ROYAL

១០-	វរសេនីយ៍ឯក **ហ៊ីង ពិសិដ្ឋ**	អត្តលេខ	៧២១៧២
១១-	វរសេនីយ៍ឯក **គោគ ឥណ្ណារ៉ា**	អត្តលេខ	៦១៧៨៤
១២-	វរសេនីយ៍ឯក **សេង ចន្ថា**	អត្តលេខ	៦៥៣០៨
១៣-	វរសេនីយ៍ឯក **ទួន សុខហ្ជីង**	អត្តលេខ	៦៦២៦៨
១៤-	វរសេនីយ៍ឯក **ឡៀង ឆង់**	អត្តលេខ	៦៧០៥៨
១៥-	វរសេនីយ៍ឯក **ហេង ឥណ្ណា**	អត្តលេខ	៦៩២២២
១៦-	វរសេនីយ៍ឯក **ឯម កុសល**	អត្តលេខ	៦៤៣០៧
១៧-	វរសេនីយ៍ឯក **សុខ សុតា**	អត្តលេខ	៧៥៤៧៤
១៨-	វរសេនីយ៍ឯក **ស្រ៊ី សុឥណ្ណ**	អត្តលេខ	៦៧៩៥៤ ។

មាត្រា ២ ៖ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួល បន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆការ
នរោត្តម សីហមុនី

ភារ.ស.១៤០៦.៦៤២

លេខ: ៦៥៨ ស.ណ

ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ២០១៨

សំណៅផ្ទេរមានតម្លៃជាការចែកផ្សាយ
ថ្ងៃពុធ ៨កើត ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៨
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

យើង

នស/រកត/០៦១៨/៦២៧

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋារាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ងួហោតាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ផ្ទេរក្របខ័ណ្ឌលោក **ឆ្លង ពិជ** ពីឋានន្តរសក្តិអនុមន្ត្រីថ្នាក់លេខ១ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មកឋានន្តរសក្តិ **ឧត្តមសេនីយ៍ត្រី** អត្តលេខ ៨៣៣៨៣ នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា ក្រសួងមហាផ្ទៃ ។

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆការ
នរោត្តម សីហមុនី

ជាវ.ស.១៥០៦.៦ជ.ញ

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៨

លេខ: ៦២៤ ស.ណ
សំណេរនេះមានតម្លៃជាការចែកផ្សាយ
ថ្ងៃពុធ ១រោជ ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៨
អគ្គលេខាធិការរាជរដ្ឋាភិបាល

ផេង សុខា

ព្រះរាជក្រឹត្យ

ន.ស/រកត/០៦១៨/ ៦២៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

ប្រោសព្រះរាជទាន

ទូ

គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍

ចំពោះ

១-ព្រះរតនចារី ហ្សឿ ទច្ឆ

២-ព្រះវិន័យមង្គល កែវ សម្បត្តិ

ជាសក្ខី. ១៥០៦.៦២២

ព្រះហស្តលេខា និងព្រះរាជលញ្ឆកម
នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ២០១៨

លេខ: ៦៥៥ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
ថ្ងៃពុធ ៨កើត ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៨
រដ្ឋលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

ន.ស/រកត/០៦១៨/៦៣៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ងួហោតាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា)

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស **មុនីសារភ័ណ្ឌ** ថ្នាក់ **មហាសេនា**

ចំពោះ

លោក KIM DO HYUNG

ព្រះហស្តលេខា និងព្រះរាជលញ្ឆកម
នរោត្តម សីហមុនី

ធាវ.ស.១៨០៦.៦៤៥

លេខ: ៦៥៦ ស.ណ

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១៨

សំណៅដើមមានតម្លៃជាការចែកផ្សាយ
ថ្ងៃពុធ ៨កើត ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៨
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

ឈប/រកត/០៦១៨/៤២០

ឈប

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខកខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរមហាក្សត្រ
ខេមរាជនា សម្ងួហោតាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា)

ប្រោសព្រះរាជទាន

ទូច

ក- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍

១-ឯកឧត្តម អោម ចន្ថា	៤-លោក ឡេ ប៊ុនពេជ្រ
២-លោក ឈឿន ម្រៃយ៉ុង	៥-លោក លី សុវណ្ណារិទ្ធ
៣-លោក ហោ ញ្ជ៊ីម	៦-លោក ម៉ៃ ភេទលី

ខ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា

១-លោក រដ្ឋ សុខា	៣-លោក សេង គី
២-លោក ឈឹន សុរិយា	

គ- គ្រឿងឥស្សរិយយស មុនីសារាវ៉ណ្ណ ថ្នាក់ មហាសេនា

១-លោក អ៊ែម សុខា	៤-លោកស្រី ឃឹង សុវតនី
២-លោកស្រី ទូច ទី	៥-លោក ម៉ាន់ ជ៉ារ៉ាន់
៣-លោក ហាយ សំណាង	៦-លោក ថោង ចន្ធរិទ្ធី

ឃ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ត

១-លោក ភែង ភារ៉ារ៉ូ	៣-លោក ទូ យ៉ាត
២-លោក ភេតុ ឥណ្ណសិន	

ង- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា

១-លោក ទិ ម៉ា	៤-លោក ផ្លាង ទៀង
២-លោក ម៉ន ឥណ្ណា	៥-លោក ហាស សំណាង ។
៣-លោក ទ្រឿង សាខយ	

ព្រះហស្តលេខា និងព្រះរាជលញ្ឆកម
នរោត្តម សីហមុនី

ជារាស.១៩០៦ ២៤៦

លេខ:៦៥១ ស.ណ
សំណេរដែលមានតម្លៃជាការចែកផ្សាយ
ថ្ងៃពុធ ៨រោច ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៨
អគ្គលេខាធិការរដ្ឋាភិបាល

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៨

សយ សុខា

ព្រះរាជក្រឹត្យ

 នស/រកត/០៦១៨/៦៤១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានតួមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ងួហោតាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា)

ត្រាស់បង្គាប់

តែងតាំង:

១- លោក **ស៊ុន ទី**
២- លោក **លិ គឹមហ៊ីរ**

ជា

ឧកញ៉ា

ចាងណ.១៤០៦.៦៤៧

ព្រះហស្តលេខា និងព្រះរាជលញ្ឆការ
នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៨

លេខ: ៦៥៧ ស.ណ

សំណៅដើមមានតម្លៃជាការចែកផ្សាយ
ថ្ងៃពុធ ១រោច ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៨
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

ន.ស/រកត/០៦១៨/៦៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០១១៣/០៩២ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៣ ស្តីពីការផ្តល់ឋានៈសាស្ត្រាចារ្យ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៦៣ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ផ្តល់ឋានៈជាសាស្ត្រាចារ្យមហាបរិញ្ញា ដល់បណ្ឌិត និងវេជ្ជបណ្ឌិតនៅវិទ្យាស្ថានជាតិសុខភាពសាធារណៈ ០៤រូប :

១- លោក	**ឈា ឆវណ្ណ**	បណ្ឌិតផ្នែកសុខភាពសាធារណៈ
២- លោក	**ហេង សុភាព**	បណ្ឌិតផ្នែកសុខភាពសាធារណៈ
៣- លោក	**ឆ្យឹក ឌីសូឆ្យី**	បណ្ឌិតផ្នែកសុខភាពសាធារណៈ
៤- លោកស្រី	**ប្រាក់ ពិសិដ្ឋរេត្យី**	វេជ្ជបណ្ឌិតផ្នែកសុខភាពសាធារណៈ

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆការ
នរោត្តម សីហមុនី

ចាប់ស.១៩០៦.៦៥១

លេខ:៦៥៩ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
ថ្ងៃសុក្រ ១០រោច ខែមឃមាសាស ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៨
រាជធានីភ្នំពេញ ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៨
អគ្គលេខាធិការដ្ឋានរដ្ឋាភិបាល

សយ សុខា

នស/រកត/០៦១៨/៦២៣

ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានតួមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ងហោតាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា)

ប្រោសព្រះរាជទាន

នូវ

ក-គ្រឿងឥស្សរិយយស **ជាគូបការ**

១-ឯកឧត្តម **ហាស សាវ៉ន**	២-ឧកញ៉ា **ហាង់ បូវិសាល**
៣- ឧកញ៉ា **ស៊ី ចាន់រដ្ឋា**	

ខ-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍:**

១-ឯកឧត្តមឧិសថការី **ផ្ទ ទិតព**	២-លោក **ជា ជោគ**
៣-លោក **ហោ ជា**	៤-លោក **ផិត ប្រុយារិទ្ធ**
៥-លោក **ម៉ុត គឹមស្រួរ**	៦-លោក **ជាង ឌីណា**
៧-លោក **ជាង ហុកសៃ**	៨-លោក **ត្រាង់ ប៊ុនណុន**
៩-លោក **ឈឹម គឹមហុង**	១០-លោក **ឆ្យូយ សុផល**
១១-លោក **ម៉ៅ សុខុន**	១២-លោក **កែម រ៉ា**
១៣-កញ្ញា **ហុក ទិព្ធកេសា**	១៤-លោក **លី សេងហួត**
១៥-លោក **ហុក ទិព្ធរុក្ខា**	១៦-លោក **យូ គឹមលី**
១៧-លោកជំទាវ **សាំង រ៉ូតូរីតា**	១៨-លោក **ឆុយ សុតាង**

គ-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា:**

១-លោក **គឹម ឈុនរៀង**	២-លោក **សុង ឃាង**
៣-លោក **លី ម៉ី**	៤-លោក **ជាង់ សុផានិត**
៥-លោក **ពេជ្រ ផារិទ្ធ**	៦-លោកស្រី **ហ៊ីង និមល**
៧-លោកស្រី **ឈឹម សុធា**	៨-លោកស្រី **សុខ ឥណ្ណារី**
៩-លោក **ទូន សំណាង**	១០-លោក **រៀង សុខសីហា**
១១-លោក **ជា ឈុនហុង**	១២-លោក **រៀង ប៊ុនតា**
១៣-លោកវេជ្ជបណ្ឌិតឯកទេស **អាន សាយ**	១៤-លោក **ពៅ ប៊ុនធឿន**
១៥-លោក **ម៉ែន ឥណ្ណី**	១៦-លោក **ឌុម ជ័យឥន្ទ្រនៈ**
១៧-លោក **កែវ ប៉ង់តា**	១៨-លោក **សុខ សុភក្តិ**
១៩-លោក **ជា ម៉ង់ហួត**	២០-លោក **ឆម សំណាង**
២១-លោក **អ៊ុង ឥសណាញ**	២២-លោក **កែ ឈុំបញ្ញា**
២៣-លោក **ជុំ សូលីឥណ្ណ**	២៤-លោក **យ៉ែត អុលកិត្យា**
២៥-លោក **ហេង ឌិចិត្រ**	២៦-លោក **សុឥណ្ណ សម្ប្ញរណ៌**
២៧-លោក **ហាស សុឥណ្ណារិទ្ធ**	

ROYAUME DU CAMBODGE MINISTERE DU PALAIS ROYAL

យ-គ្រឿងឥស្សរិយយស **មុនីសារាគ័ណ្ឌ** ថ្នាក់ **មហាសេនា:**

១-ព្រះតេជគុណ **ផួន ណ្ណា**	២-ឧបាសក **ឈឹន ម៉ៅ**

ង-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ចិបឌិណ:**

១-លោកជំទាវវេជ្ជបណ្ឌិត **ស៊ិន សារ៉ាន**	២-ឯកឧត្តមវេជ្ជបណ្ឌិត **ឆេង អ៊ុន**
៣-លោក **ស៊ន់ សេរីមុទ្ធី**	៤-លោក **សុខ ចាន់**
៥-លោក **កែវ ឃូរី**	៦-លោក **កែ គុណា**
៧-លោក **លីន ផា**	៨-លោក **យ៉ុង គុន**
៩-លោកស្រី **ខៀវ សុផាន់ណា**	១០-កញ្ញា **ជួន សុផារ៉ី**
១១-លោក **ប៉ាល់ ផាដេត**	១២-លោក **អ៊ុង សុភាព**

ច-គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **ចិបឌិណ:**

១-ព្រះគ្រូ **ភាព វណ្ណារ៉ា**	២-លោកស្រី **ស៊ៀ ឌីយ៉ា**

ឆ-គ្រឿងឥស្សរិយយស **មុនីសារាគ័ណ្ឌ** ថ្នាក់ **ចិបឌិណ:**

១-ព្រះតេជគុណ **ស៊ិនយ៉ុង ពិចិត្រ**	២-ឯកឧត្តម **ប៉ា ម៉េងហុក**
៣-ឯកឧត្តម **អ៊ុក ភារ:**	៤-លោក **ស៊ន់ សារ៉ិន**
៥-ឧបាសិកា **ស៊ាង ស៊ីម**	៦-ឧបាសិកា **ឈុន យុន**
៧-លោកស្រី **យិន ម៉ារ៉ី**	៨-លោក **ជា ឌាយ**
៩-លោក **សួង សាម៉ាត**	១០-លោក **ផាត់ សុវណ្ណារិទ្ធ**

ជាសម.១៨០៦.១៥២

ព្រះហស្តលេខា និងព្រះរាជលញ្ឆការ
នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ២១ ខែមិថុនា ឆ្នាំ២០១៨

លេខ:៦៦៣ ស.ណ

សំណេរដែលមានតម្លៃជាការចែកផ្សាយ
ថ្ងៃសុក្រ ១០កើត ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៨
រដ្ឋលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ

សំណុំរឿង

លេខ : ៣៥៣/០០៤/២០១៨

ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៨

សេចក្តីសម្រេច

លេខ : ១៩៥/០០៣/២០១៨ កបធ.ច

ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៨

ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សា-ធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៨/០០៥ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ មាត្រា ២៧ ថ្មី មាត្រា ២៨ មាត្រា ៣១ និងមាត្រា ៣២ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញលិខិតលេខ ២៣៩ រស ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៨ របស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៨ នាសម័យប្រជុំលើកទី១០ នីតិកាលទី៥ ហើយព្រឹទ្ធសភាបានពិនិត្យនិងឱ្យយោបល់

អាគារស ទីស្នាក់ការមន្ត្រី មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ
ទូរស័ព្ទ/ទូរសារ : (៨៥៥) ២៣ ៧២៦ ០៣១ ២៣ ៧២០ ៩១៣, E-mail: sgccc@online.com.kh / info@ccc.gov.kh, Website :http://www.ccc.gov.kh , ប្រអប់សំបុត្រ ២៤៨៣ ភ្នំពេញ

ឯកភាពទាំងស្រុងលើទម្រង់ និងគតិច្បាប់ ដោយឥតកែប្រែ និងចាត់ទុកជាការប្រញាប់ ក្នុងសម័យប្រជុំលើកទី១ នីតិកាលទី៤ នាថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៨ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលលិខិតខាងលើនេះ នៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៨ វេលាម៉ោង ១៦ និង៤៥នាទី

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

- យល់ឃើញថា រដ្ឋសភា និងព្រឹទ្ធសភាបានអនុវត្តត្រឹមត្រូវតាមបែបបទដែលមានចែងក្នុងមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញ ក្នុងការពិនិត្យនិងអនុម័តច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា
- យល់ឃើញថា សំណើរបស់សម្តេចអគ្គមហាពញ្ញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្របនឹងមាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា ១៦ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញភាពនៃច្បាប់នេះ មកពិនិត្យបាន
- យល់ឃើញថា ទម្រង់នៃការតាក់តែង និង ការអនុម័តច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា ស្របនឹងរដ្ឋធម្មនុញ្ញ
- យល់ឃើញថាជំពូកទី១ ស្តីពីបទប្បញ្ញត្តិទូទៅមាន ៣ មាត្រា គឺពីមាត្រា ១ ដល់ មាត្រា ៣ ចែងពី គោលបំណង គោលដៅ និងវិសាលភាពនៃច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា។

  បទប្បញ្ញត្តិក្នុងមាត្រាទាំង ៣ នៃជំពូកទី១នេះ ស្របនឹងស្មារតីនៃមាត្រា ៣១ មាត្រា ៣៦ មាត្រា ៤៥ មាត្រា ៥២ មាត្រា ៥៦ មាត្រា ៦១ និងមាត្រា ៦៣ នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថាជំពូកទី២ ស្តីពីប្រាក់ឈ្នួលអប្បបរមា មាន ៦ មាត្រា គឺពីមាត្រា ៤ ដល់ មាត្រា ៩ ចែងពី ប្រាក់ឈ្នួលអប្បបរមា គឺជាប្រាក់ឈ្នួលកម្រិតទាបបំផុតនិងត្រូវបានកំណត់ដោយប្រកាសរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារ ធាតុផ្សំសម្រាប់យកមកពិចារណាក្នុងការកំណត់ប្រាក់ឈ្នួលអប្បបរមា ការព្រមព្រៀងរវាងភាគីពាក់ព័ន្ធ។

  បទប្បញ្ញត្តិក្នុងមាត្រាទាំង ៦ នៃជំពូកទី២នេះ ស្របនឹងស្មារតីនៃមាត្រា ៣១ មាត្រា ៣៦ មាត្រា ៤៥ មាត្រា ៥២ មាត្រា ៥៦ មាត្រា ៦១ និងមាត្រា ៦៣ នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថាជំពូកទី៣ ស្តីពីការពិភាក្សាកំណត់ប្រាក់ឈ្នួលអប្បបរមា មាន ៥ មាត្រា គឺពីមាត្រា ១០ ដល់ មាត្រា ១៤ ចែងពី គោលការណ៍នៃការពិភាក្សាកំណត់ប្រាក់ឈ្នួល

អប្បបរមា កាលវិភាគនៃការពិភាក្សាកំណត់ប្រាក់ឈ្នួលអប្បបរមា ការចូលរួមពិភាក្សា និងគោលការណ៍សម្រេចរបស់ភាគី សុពលភាពនៃការអនុវត្តប្រាក់ឈ្នួលអប្បបរមាថ្មី។

បទប្បញ្ញត្តិក្នុងមាត្រាទាំង ៥ នៃជំពូកទី៣ នេះស្របនឹងស្មារតីនៃមាត្រា ៣១ មាត្រា ៣៦ មាត្រា ៤៥ មាត្រា ៥២ មាត្រា ៥៦ មាត្រា ៦១ និងមាត្រា ៦៣ នៃរដ្ឋធម្មនុញ្ញ

- យល់ឃើញថាជំពូកទី៤ ស្តីពីក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមា មាន ៧ មាត្រា គឺពីមាត្រា ១៥ ដល់ មាត្រា ២១ ចែងពី ការបង្កើតក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមានៅអមក្រសួងទទួលបន្ទុកវិស័យការងារ ភារកិច្ចរបស់ក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមា ចំនួនសមាជិកពេញសិទ្ធិ និងសមាជិកបម្រុងដែលមកពីត្រីភាគី សមាសភាព ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមាត្រូវកំណត់ដោយអនុក្រឹត្យ សមាជិកពេញសិទ្ធិ និងសមាជិកបម្រុងត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារ ការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមាត្រូវកំណត់ដោយអនុក្រឹត្យ។

បទប្បញ្ញត្តិក្នុងមាត្រាទាំង ៧ នៃជំពូកទី៤នេះ ស្របនឹងស្មារតីនៃមាត្រា ៣១ មាត្រា ៣៦ មាត្រា ៤៥ មាត្រា ៥២ មាត្រា ៥៦ មាត្រា ៦១ និងមាត្រា ៦៣ នៃរដ្ឋធម្មនុញ្ញ

- យល់ឃើញថាជំពូកទី៥ ស្តីពីវិធានការរដ្ឋបាល និងទោសប្បញ្ញត្តិមាន ៧ មាត្រា គឺពីមាត្រា ២២ ដល់ មាត្រា ២៨ ចែងពី ទណ្ឌកម្ម បែបបទនិងនីតិវិធីក្នុងការដាក់ទណ្ឌកម្ម ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារ និងការអនុវត្ត បទប្បញ្ញត្តិនៃជំពូកទី៥ (វិធានការរដ្ឋបាលនិងទោសប្បញ្ញត្តិ) នៃច្បាប់នេះមិនរារាំងការអនុវត្តច្បាប់ស្តីពីសហជីព ច្បាប់ស្តីពីការងារ ឬច្បាប់ព្រហ្មទណ្ឌផ្សេងទៀត ក្នុងករណីដែលអំពើបំពានលើបទប្បញ្ញត្តិដែលមានចែងក្នុងច្បាប់នេះជាបទល្មើសដែលបានបញ្ញត្តក្នុងច្បាប់ទាំងនោះ។

បទប្បញ្ញត្តិក្នុងមាត្រាទាំង ៧ នៃជំពូកទី៤នេះ ស្របនឹងមាត្រា ៥២ វាក្យខ័ណ្ឌទី២ នៃរដ្ឋធម្មនុញ្ញ

- យល់ឃើញថាជំពូកទី៦ ស្តីពីអវសានប្បញ្ញត្តិ មាន ២ មាត្រា គឺ មាត្រា ២៩ និងមាត្រា ៣០ ចែងពី ការទុកជានិរាករណ៍ មាត្រា ១០៤ មាត្រា ១០៥ មាត្រា ១០៦ មាត្រា ១០៧ មាត្រា ១០៨ មាត្រា ១០៩ នៃច្បាប់ស្តីពីការងារដែលប្រកាសឱ្យប្រើ

ដោយព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ និងបទប្បញ្ញត្តិណាដែលផ្ទុយនឹងច្បាប់នេះ។ ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់។

បទប្បញ្ញត្តិក្នុងមាត្រាទាំង ២ នៃជំពូកទី៦នេះ ស្របនឹងមាត្រា ៩៣ ថ្មី នៃរដ្ឋធម្មនុញ្ញ

- យល់ឃើញថា គ្រប់បទប្បញ្ញត្តិទាំងអស់នៃច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា ពុំមានបទប្បញ្ញត្តិណាមួយមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

សម្រេច

មាត្រា ១. ច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៨ នាសម័យប្រជុំរដ្ឋសភាលើកទី១០ នីតិកាលទី៥ ហើយព្រឹទ្ធសភាបានពិនិត្យ និងឱ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់ និងគតិច្បាប់ ដោយឥតកែប្រែ និងចាត់ទុកជាការប្រញាប់ ក្នុងសម័យប្រជុំលើកទី១ នីតិកាលទី៤ នាថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៨ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ។

មាត្រា ២. សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៨ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនិងត្រូវចុះផ្សាយក្នុងរាជកិច្ច។

ថ្ងៃអង្គារ ១៤កើត ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៨

នាមក្រុមប្រឹក្សាធម្មនុញ្ញ
ប្រធាន

អ៊ីម ឈុនលឹម

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៨០...សនក្រ.ប.ក

អនុក្រឹត្យ

ស្តីពី

ការដាក់ឱ្យប្រើប្រាស់ផែនការរៀបចំដែនដីខេត្តឃាត់ដំបង

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ នស/ ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០៦៩៩/ ០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០៨០១/ ១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០៥០៨/ ០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០២១០/០០៣ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអស្សាមិករណ៍
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤៦៣ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣១៤/៣៧៣ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលមាត្រា ២ និងមាត្រា ៥ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤៦៣ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ
- បានឃើញអនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន
- បានឃើញអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា ៣០ មាត្រា ៣៤ មាត្រា ៣៨ មាត្រា ៥០ មាត្រា ៦៦ មាត្រា ៧៤ និងមាត្រា ៨២ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ និងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ

សម្រេច

មាត្រា ១.-

ត្រូវបានដាក់ឱ្យប្រើប្រាស់ផែនការរៀបចំដែនដីខេត្តបាត់ដំបង ដែលមានចក្ខុវិស័យដល់ឆ្នាំ ២០៣០ ដូចមានឧបសម្ព័ន្ធភ្ជាប់ជាមួយអនុក្រឹត្យនេះ។

មាត្រា ២.-

ផែនការរៀបចំដែនដីខេត្តបាត់ដំបងអាចធ្វើការកែសម្រួលក្នុងរយៈពេល ៥ (ប្រាំ)ឆ្នាំម្តង តាមករណីចាំបាច់នៃការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម។ ការកែសម្រួលផែនការរៀបចំដែនដីខេត្តបាត់ដំបងមុនពេលកំណត់ អាចប្រព្រឹត្តទៅបានក្នុងករណីដែលមានតម្រូវការចាំបាច់សម្រាប់បម្រើផលប្រយោជន៍សាធារណៈ ឬផលប្រយោជន៍ជាតិ។

ការកែសម្រួលផែនការរៀបចំដែនដីខេត្តបាត់ដំបង ត្រូវអនុវត្តតាមនីតិវិធីនិងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

មាត្រា ៣.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

មាត្រា ៤.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ ប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ១ រោچ ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ២០១៨

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ដើម្បីចុះហត្ថលេខា
នេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់
និងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ

ជា សុផារ៉ា

កន្លែងទទួល៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ផ្នែកមាត្រា ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ការដាក់ឱ្យអនុវត្តផែនការរៀបចំដែនដីខេត្តឃាត់ដំបង ចក្ខុវិស័យឆ្នាំ២០៣០

ដោយអនុក្រឹត្យលេខ.៨០.អនក្រ.បក.ចុះថ្ងៃ.ពុធ.១.ខែតុលា.ឆ្នាំ២០១៨ សំរឹទ្ធិស័ក ព.ស. ២៥៦២

ត្រូវនឹងថ្ងៃទី..១៧... ខែ..តុលា... ឆ្នាំ២០១៨

ផែនការរៀបចំដែនដីខេត្តឃាត់ដំបង

ចក្ខុវិស័យឆ្នាំ២០៣០

មាតិកា

ទំព័រ

១- សេចក្តីផ្តើម ១

២- ចក្ខុវិស័យ ២

២.១- ក្របខណ្ឌសេដ្ឋកិច្ច សង្គម ២

២.២- ចក្ខុវិស័យ ២

៣- គោលបំណងនិងគោលដៅ ៣

៣.១- គោលបំណង ៣

៣.២- គោលដៅ ៣

៤- យុទ្ធសាស្ត្រតម្រង់ទិសអភិវឌ្ឍន៍ ៤

៤.១- អ៊ីក្សជាយុទ្ធសាស្ត្រនៃការអភិវឌ្ឍក្នុងក្របខណ្ឌតំបន់និងអន្តរជាតិ ៤

៤.២- អ៊ីក្សជាយុទ្ធសាស្ត្រនៃការអភិវឌ្ឍក្នុងក្របខណ្ឌជាតិ ៤

៤.៣- យុទ្ធសាស្ត្រអភិវឌ្ឍន៍ក្នុងក្របខណ្ឌខេត្ត ៤

៤.៣.១- ការអភិវឌ្ឍនគរូបនីយកម្មនិងលំនៅឋាន ៤

៤.៣.២- ការអភិវឌ្ឍប្រព័ន្ធដឹកជញ្ជូន ៥

៤.៣.៣- ការគ្រប់គ្រងទីជម្រាល ៦

៤.៣.៤- ការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រនិងកសិកម្ម ៧

៤.៣.៥- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធបច្ចេកទេសនិងឧស្សាហកម្ម ៨

៤.៣.៦- ការអភិវឌ្ឍទេសចរណ៍ ៩

៥- ផែនការសកម្មភាព ៩

៥.១- គម្រោងអាទិភាពក្នុងក្របខណ្ឌតំបន់និងអន្តរជាតិ ៩

៥.២- គម្រោងអាទិភាពក្នុងក្របខណ្ឌជាតិ ១០

៥.៣- គម្រោងអាទិភាពក្នុងក្របខណ្ឌខេត្ត ១០

៥.៣.១- ការអភិវឌ្ឍនគរូបនីយកម្មនិងលំនៅឋាន ១០

៥.៣.២- ការអភិវឌ្ឍប្រព័ន្ធដឹកជញ្ជូន ១១

៥.៣.៣- ការគ្រប់គ្រងទីជម្រាលប្រកបដោយចីរភាព ១២

៥.៣.៤- ការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រនិងកសិកម្ម ១៣

៥.៣.៥- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធបច្ចេកទេសនិងឧស្សាហកម្ម ១៣

៥.៣.៦- ការអភិវឌ្ឍទេសចរណ៍ ១៤

៥.៤- ការផ្សព្វផ្សាយ ១៥

៦- ធនធានហិរញ្ញវត្ថុ ១៥

៧- ការត្រួតពិនិត្យនិងវាយតម្លៃ ១៥

៧.១- យន្តការ ១៥

៧.២- ក្របខណ្ឌច្បាប់ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្ត ១៦

៧.៣- គោលការណ៍ នីតិវិធី និងភារកិច្ច ១៦

៨- សេចក្តីសន្និដ្ឋាន ១៧

សន្ទានុក្រម ១៨

ឯកសារខ្ទបសម្ព័ន្ធ ១៩

១- សេចក្តីផ្តើម

ស្ថិតក្នុងបរិការណ៍សុខសន្តិភាព ឯកភាពទឹកដី ឯកភាពជាតិ ស្ថិរភាពនយោបាយរឹងមាំ ការប្រកាន់ខ្ជាប់ឥតងាកវេនូវគោលការណ៍លទ្ធិប្រជាធិបតេយ្យ នីតិរដ្ឋ និងការគោរពសិទ្ធិមនុស្ស នៅក្រោមជំបូលរដ្ឋធម្មនុញ្ញនិងច្បាប់ រាជរដ្ឋាភិបាលបានធានាជាប់ជាប្រចាំនូវប្រក្រតីភាពនៃដំណើរទៅមុខនៃការអភិវឌ្ឍសង្គម សេដ្ឋកិច្ចកម្ពុជា។ រាជរដ្ឋាភិបាលបានបន្តជំរុញការកែទម្រង់ស្ថាប័នឱ្យមានសន្ទុះថ្មី មុតស្រួចនិងកាន់តែស៊ីជម្រៅលើគ្រប់ផ្នែក និងគ្រប់វិស័យ ក្នុងគោលដៅបង្កើន និងកែលម្អការផ្តល់គុណភាពសេវាសាធារណៈ ប្រកបដោយគុណភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព។

ផ្អែកតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានដាក់ចេញនូវគោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា សំដៅធានាថា ដែនដីនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ត្រូវបានគ្រប់គ្រង ប្រើប្រាស់ ការពារ និងអភិវឌ្ឍ តាមរយៈការធ្វើសមាហរណកម្មនូវផែនការយុទ្ធសាស្ត្ររៀបចំដែនដី និងការធ្វើឱ្យរលូននូវវិធាននិងឧបករណ៍ចាំបាច់នានាតាមវិស័យប្រកបដោយភាពសុខដុមរមនានៅតាមតំបន់ភូមិសាស្ត្រនីមួយៗ។

ស្ថិរភាពនិងវឌ្ឍនភាពសង្គម សេដ្ឋកិច្ចកម្ពុជា ជាកាលានុវត្តភាពជំរុញឱ្យមាននូវនិន្នាការកើនឡើងយ៉ាងឆាប់រហ័សនៃចំនួនប្រជាជន ការប្រើប្រាស់ដីធ្លី លំនៅឋាន នគរូបនីយកម្ម និងតម្រូវការក្នុងការបង្កើតទីក្រុងតូចធំគ្រប់កម្រិត ដែលមាននូវបណ្តាញហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់ ដូចជាសេវាកម្មនិងបច្ចេកទេសថាមពលនិងអគ្គិសនី សុខភាពនិងទឹកស្អាត អេកូឡូស៊ីនិងធនធានធម្មជាតិ ការគ្រប់គ្រងកាកសំណល់រឹងរាវ ការគ្រប់គ្រងគ្រោះមហន្តរាយ។ល។ ដើម្បីឆ្លើយតបទៅនឹងការវិវត្តទាំងនេះ ចាំបាច់ត្រូវមានការគិតគូរនិងកសាងឡើងនូវផែនការរៀបចំដែនដីនិងនគរូបនីយកម្ម ប្លង់គោលប្រើប្រាស់ដី និងប្លង់លម្អិតនគរូបនីយកម្ម ប្រកបដោយប្រសិទ្ធភាព សម្រាប់ធ្វើការគ្រប់គ្រងនិងការតម្រង់ទិសការអភិវឌ្ឍលើគ្រប់វិស័យឱ្យមានដំ**ណើរ**ប្រកបដោយចីរភាព និងធានាបាននូវការគ្រប់គ្រងដីកសិកម្ម ព្រៃឈើ ប្រព័ន្ធអេកូឡូស៊ី ការការពារ**បរិស្ថាន**និងធនធានធម្មជាតិ។

ផែនការរៀបចំដែនដីខេត្តបាត់ដំបង ត្រូវបានរៀបចំនិងកសាងឡើងនៅឆ្នាំ២០០៥ ស្របតាម**តម្រូ**វការការវិវត្តជាក់ស្តែងនៃស្ថានភាពសង្គម សេដ្ឋកិច្ច និងបរិស្ថាន ដោយផ្អែកលើកត្តាទីតាំងភូមិសាស្ត្រជាតំបន់ស្នូលភាគពាយ័ព្យនៃប្រទេសកម្ពុជា កត្តាធនធានធម្មជាតិនិងបរិស្ថាន កត្តាប្រវត្តិសាស្ត្រនិងបេតិកភណ្ឌវប្បធម៌ និងស្របតាមក្របខណ្ឌយុទ្ធសាស្ត្រ គោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

សំខាន់ៗមានជាអាទិ៍ យុទ្ធសាស្ត្រចតុកោណ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ សេចក្ដីថ្លែងការណ៍របស់រាជរដ្ឋាភិបាលស្ដីពីគោលនយោបាយដីធ្លី គោលនយោបាយជាតិស្ដីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ភូមិបាល ច្បាប់ស្ដីពីការរៀបចំទីកដី នគរូបនីយកម្ម និងសំណង់ ច្បាប់ស្ដីពីកិច្ចការពារបរិស្ថាន និងធនធានធម្មជាតិ ច្បាប់ស្ដីពីព្រៃឈើ ច្បាប់ស្ដីពីជលផល ច្បាប់ស្ដីពីផ្លូវថ្នល់ ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អនុក្រឹត្យស្ដីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងអនុក្រឹត្យស្ដីពីនគរូបនីយកម្មរាជធានី ក្រុង និងទីប្រជុំជន។ល។

២- ចក្ខុវិស័យ

២.១- ក្របខណ្ឌសេដ្ឋកិច្ច សង្គម

ផែនការរៀបចំដែនដីខេត្តបាត់ដំបង ត្រូវបានរៀបចំឡើងដោយបានសិក្សាប្រមូលនិងវិភាគទិន្នន័យរូបវន្ត ទិន្នន័យសេដ្ឋកិច្ច ទិន្នន័យសង្គម ទិន្នន័យបរិស្ថាន ទិន្នន័យប្រជាសាស្ត្រ និងការស្រង់មតិ សមស្របតាមអនុក្រឹត្យស្ដីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន គោលនយោបាយជាតិស្ដីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា និងគោលនយោបាយដីធ្លី "សៀវភៅ ស ដីធ្លី"។

ដើម្បីកំណត់ចក្ខុវិស័យនៃផែនការរៀបចំដែនដីខេត្តបាត់ដំបងដល់ឆ្នាំ២០៣០ ក្របខណ្ឌសេដ្ឋកិច្ច សង្គម ត្រូវបានសិក្សាវិភាគតាមបែបវិទ្យាសាស្ត្រ ដោយផ្អែកតាមរបាយការណ៍ជាតិស្ដីពីលទ្ធផលចុងក្រោយនៃជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ២០០៨ របស់វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ។ តាមរយៈការសិក្សាខាងលើនេះ ខេត្តបាត់ដំបងដែលមានផ្ទៃដី ១១ ៧៤៨ គីឡូម៉ែត្រក្រឡា ចំនួនប្រជាជននៅឆ្នាំ២០០៨ មានចំនួន ១ ០២៥ ១៧៤ នាក់ នៅឆ្នាំ២០១៨ មានចំនួន ១ ២៨៣ ២២៣ នាក់ ហើយនៅឆ្នាំ២០៣០ នឹងកើនដល់ ១ ៥១៩ ១៨៥ នាក់។ ចំពោះការបែងចែកកម្លាំងពលកម្មតាមវិស័យសេដ្ឋកិច្ចសម្រាប់ខេត្តបាត់ដំបង គឺនៅឆ្នាំ២០០៨ ប្រជាជនដែលធ្វើការក្នុងវិស័យកសិកម្មមានចំនួន ៦៧០ ០៧៣ នាក់ (៧៦,៦៧%) ក្នុងវិស័យឧស្សាហកម្មមានចំនួន ៤៣ ៥២៤ នាក់ (៤,៩៨%) និងក្នុងវិស័យសេវាកម្ម មានចំនួន ១៦០ ៣៧៣ នាក់ (១៨,៣៥%) ហើយនៅឆ្នាំ២០៣០ ប្រជាជនដែលធ្វើការក្នុងវិស័យកសិកម្ម នឹងមានការកើនឡើងដល់ចំនួន ៨០៦ ២៦៣ នាក់ (៦០%) ក្នុងវិស័យឧស្សាហកម្មកើនឡើងដល់ចំនួន ៨០ ៦២៦ នាក់ (៦ %) និងក្នុងវិស័យសេវាកម្មកើនដល់ចំនួន ៤៥៦ ៨៨៣ នាក់ (៣៤%)។

២.២- ចក្ខុវិស័យ

ផែនការរៀបចំដែនដីខេត្តបាត់ដំបងចក្ខុវិស័យឆ្នាំ២០៣០ គឺសំដៅរៀបចំ និងអភិវឌ្ឍ *"ខេត្ត បាត់ដំបងជាតំបន់ស្នូលសេដ្ឋកិច្ចភាគពាយ័ព្យនៃប្រទេសកម្ពុជា"* តាមរយៈការជំរុញរៀបចំនិងអភិវឌ្ឍជាៈ

– តំបន់ស្នូលនគរូបនីយកម្ម អភិបាលកិច្ចល្អ និងការអភិវឌ្ឍធនធានមនុស្សកាន់តែប្រសើរឡើង

- តំបន់ផលិតផលកសិកម្មប្រកបដោយគុណភាពខ្ពស់
- មជ្ឈមណ្ឌលពាណិជ្ជកម្មនិងឧស្សាហកម្មកែច្នៃផលិតផលកសិកម្មប្រកបដោយការប្រកួតប្រជែង
- តំបន់ទេសចរណ៍ធម្មជាតិ វប្បធម៌ និងប្រវត្តិសាស្ត្រ
- តំបន់សមាហរណកម្មចម្រុះរវាងវិស័យសេដ្ឋកិច្ច សង្គម វប្បធម៌ និងធនធានធម្មជាតិ។

៣- គោលបំណងនិងគោលដៅ

៣.១- គោលបំណង

ផែនការរៀបចំដែនដីខេត្តបាត់ដំបង មានគោលបំណងធានា៖

- ការគ្រប់គ្រងនិងតម្រង់ទិសការអភិវឌ្ឍនិងអភិរក្សលើផ្នែកក្រុងវន្តសង្គម សេដ្ឋកិច្ច និងបរិស្ថាន
- តួនាទីជាស្នូលនៃអ័ក្សអភិវឌ្ឍស្ថិតក្នុងក្របខណ្ឌជាតិ ក្របខណ្ឌតំបន់ និងក្របខ**ណ្ឌអន្តរជាតិ** ដូចជាអាស៊ាន និងមហាអនុតំបន់ទន្លេមេគង្គ
- ការគ្រប់គ្រង បែងចែក និងប្រើប្រាស់ដីប្រកបដោយប្រសិទ្ធភាពនិងចីរភាព **សម្រាប់ការអភិវឌ្ឍ** និងអភិរក្សលើគ្រប់វិស័យប្រកបដោយតុល្យភាពនិងសមាហរណកម្មចម្រុះ
- បង្កើនផលិតផលកសិកម្មនិងឧស្សាហកម្មកែច្នៃកសិផលទាំងបរិមាណនិងគុណភាព សម្រាប់បំពេញតម្រូវការក្នុងប្រទេសនិងការនាំចេញ
- ពង្រឹងនិងពង្រីកសកម្មភាពសេដ្ឋកិច្ច ពាណិជ្ជកម្ម និងទំនាក់ទំនងវប្បធម៌ក្នុងតំបន់ស្នូលជាយុទ្ធសាស្ត្រជួរមុខ នៅតាមបណ្តោយព្រំដែន។

៣.២- គោលដៅ

ផែនការរៀបចំដែនដីខេត្តបាត់ដំបង មានគោលដៅកំណត់៖

- តំបន់នគរូបនីយកម្មកម្រិតខ្ពស់ កម្រិតមធ្យម និងកម្រិតទាប ឱ្យកាន់តែប្រសើរឡើងសម្រាប់ការរស់នៅ ឱកាសការងារ ការធ្វើពាណិជ្ជកម្ម និងការ**អភិវឌ្ឍ**ទេសចរណ៍
- តំបន់កសិកម្មមានបរិមាណនិងគុណភាពខ្ពស់ ជាពិសេសដំណាំស្រូវ និងដំណាំចម្ការ
- តំបន់ឧស្សាហកម្មកែច្នៃកសិផល ដោយចុះបញ្ជីផ្លាកសម្គាល់ភូមិសាស្ត្រទំនិញ "**ផលិតផល**ខេត្តបាត់ដំបង" ប្រកបដោយគុណភាពប្រកួតប្រជែង
- តំបន់ទេសចរណ៍ប្រវត្តិសាស្ត្រ វប្បធម៌ និងធនធានធម្មជាតិ**ប្រកបដោយចីរភាព** មានចំនួន ៣៩ទីតាំង។

៤- យុទ្ធសាស្ត្រតម្រង់ទិសអភិវឌ្ឍន៍

៤.១- អ៊ីក្សជាយុទ្ធសាស្ត្រនៃការអភិវឌ្ឍក្នុងក្របខណ្ឌតំបន់និងអន្តរជាតិ

ខេត្តបាត់ដំបងមានអ៊ីក្សជាយុទ្ធសាស្ត្រនៃការអភិវឌ្ឍក្នុងក្របខណ្ឌតំបន់និងអន្តរជាតិសំខាន់ៗ ចំនួនពីរគឺ៖

ក). ក្របខណ្ឌនៃកិច្ចព្រមព្រៀងស្តីពីផែនការធ្វើសហប្រតិបត្តិការសេដ្ឋកិច្ចកម្ពុជា-ថៃ សម្រាប់រយៈពេលខ្លី មធ្យម និងវែង លើវិស័យពាណិជ្ជកម្ម ការវិនិយោគ ផលិតផលកែច្នៃ ទេសចរណ៍ និងសេវាកម្មផ្សេងៗ។

ខ). យុទ្ធសាស្ត្រអភិវឌ្ឍន៍ផែនដីដែលខេត្តបាត់ដំបងជើរតួនាទីជា "មជ្ឈមណ្ឌលកំណើនអនុតំបន់"នៃអ៊ីក្សអភិវឌ្ឍន៍សេដ្ឋកិច្ចខាងត្បូង "បាងកក-ភ្នំពេញ-ហូជីមិញ" នៃមហាអនុតំបន់ទន្លេមេគង្គ ដែលមានបណ្តាញផ្លូវអាស៊ានឆ្លងកាត់។

៤.២- អ៊ីក្សជាយុទ្ធសាស្ត្រនៃការអភិវឌ្ឍក្នុងក្របខណ្ឌជាតិ

ក្នុងក្របខណ្ឌជាតិ ខេត្តបាត់ដំបងមានទីតាំងភូមិសាស្ត្រប្រកបដោយភាពអំណោយផល និងជាតំបន់ស្នូលភាគពាយ័ព្យនៃប្រទេស ដែលមានអ៊ីក្សភ្ជាប់តំបន់សំខាន់ៗជុំវិញ រួមមាន៖

ក). អ៊ីក្ស "ភ្នំពេញ-បាត់ដំបង-ប៉ោយប៉ែត" តាមបណ្តោយផ្លូវជាតិលេខ៥ គឺជាអ៊ីក្សដឹកជញ្ជូនដ៏សំខាន់នូវបណ្ណាភស្តុភារ ផលិតផលកសិកម្ម និងឧស្សាហកម្មកែច្នៃកសិផលទៅកាន់តំបន់កណ្តាលនៃប្រទេស និងបណ្តាខេត្តដទៃទៀត។

ខ). អ៊ីក្សនៃតំបន់ជាប់បឹងទន្លេសាប មានខេត្តបាត់ដំបង ខេត្តពោធិ៍សាត់ ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ធំ ខេត្តសៀមរាប និងខេត្តបន្ទាយមានជ័យ គឺជាតំបន់ដែលមានសក្តានុពលធំធេងលើផ្នែកកសិកម្ម ជលផល ព្រៃលិចទឹក និងទេសចរណ៍បែបធម្មជាតិ។

គ). អ៊ីក្សនៃតំបន់ឆ្នេរតភ្ជាប់ពីប្រទេសថៃ ឆ្លងកាត់តាមខេត្តកោះកុង ខេត្តព្រះសីហនុ ខេត្តកំពត និងខេត្តកែប ឆ្ពោះទៅប្រទេសវៀតណាម គឺជាតំបន់ដែលមានសក្តានុពលសេដ្ឋកិច្ច ឧស្សាហកម្ម ភស្តុភារ និងទេសចរណ៍កម្រិតអន្តរជាតិ។

ឃ). អ៊ីក្សនៃតំបន់ស្នូលជាយុទ្ធសាស្ត្រជួរមុខនៅតាមបណ្តោយព្រំដែនដីគោកកម្ពុជា-ថៃ រួមមាន ខេត្តពោធិ៍សាត់ ខេត្តប៉ៃលិន ខេត្តបន្ទាយមានជ័យ ខេត្តសៀមរាប ខេត្តព្រះវិហារ និង ខេត្តឧត្តរមានជ័យ គឺជាតំបន់ដែលមានសក្តានុពលអភិវឌ្ឍន៍សេដ្ឋកិច្ចជាមួយប្រទេសថៃ។

៤.៣- យុទ្ធសាស្ត្រអភិវឌ្ឍន៍ក្នុងក្របខណ្ឌខេត្ត

៤.៣.១-ការអភិវឌ្ឍនគរូបនីយកម្មនិងលំនៅឋាន

ក). ការកំណត់រចនាសម្ព័ន្ធស្នូលអភិវឌ្ឍន៍នគរូបនីយកម្ម

កំណត់និងបែងចែកតំបន់ស្នូលអភិវឌ្ឍនិងអ័ក្សនៃការអភិវឌ្ឍជាបីកម្រិត តាមលក្ខណៈ និងមុខងារនគរូបនីយកម្ម ដូចខាងក្រោម៖

- តំបន់នគរូបនីយកម្មកម្រិតខ្ពស់ គឺក្រុងបាត់ដំបងជា "មជ្ឈមណ្ឌលមេ"
- តំបន់នគរូបនីយកម្មកម្រិតមធ្យម គឺទីប្រជុំជនស្រុកចំនួន៦ ជា "មជ្ឈមណ្ឌលរង" រួមមានទីប្រជុំជនស្រុកមោងឫស្សី ស្រុករតនមណ្ឌល ស្រុកថ្មគោល ស្រុកបវេល ស្រុកកំរៀង និងស្រុកសំពៅលូន
- តំបន់នគរូបនីយកម្មកម្រិតទាប គឺទីប្រជុំជនស្រុកចំនួន៧ ជា"អនុមជ្ឈមណ្ឌលរង" រួមមានទីប្រជុំជនស្រុកឯកភ្នំ ស្រុកសង្កែ ស្រុករុក្ខគិរី ស្រុកគាស់ក្រឡ ស្រុកបាណន់ ស្រុកសំឡូត និងស្រុកភ្នំព្រឹក។

ខ). ការអភិវឌ្ឍលំនៅឋាន

ការសាងសង់លំនៅឋានថ្មីដើម្បីឆ្លើយតបទៅនឹងកំណើនប្រជាជន និងតម្រូវការនៃការអភិវឌ្ឍ ត្រូវធ្វើឡើងក្នុងតំបន់មួយចំនួន ដូចខាងក្រោម៖

- តំបន់លំនៅឋានក្នុងក្រុងនិងទីប្រជុំជន
- តំបន់សេដ្ឋកិច្ចពិសេស តំបន់អភិវឌ្ឍន៍សមាហរណកម្មចម្រុះ និងតំបន់ស្នូលជាយុទ្ធសាស្ត្រជួរមុខនៅតាមបណ្តោយព្រំដែន
- តំបន់លំនៅឋានថ្មីក្នុងកម្មវិធីសម្បទានដីសង្គមកិច្ច។

៤.៣.២- ការអភិវឌ្ឍប្រព័ន្ធដឹកជញ្ជូន

ប្រព័ន្ធដឹកជញ្ជូនដែលត្រូវធ្វើការអភិវឌ្ឍថ្មី ជួសជុល ឬកែលម្អ ដើម្បីបង្កើនសមត្ថភាពបម្រើដល់សកម្មភាពដឹកជញ្ជូនចេញចូល ឬឆ្លងកាត់ខេត្ត រួមមាន៖

ក). បណ្តាញផ្លូវថ្នល់

- បណ្តាញផ្លូវថ្នល់ សម្រាប់តភ្ជាប់ពីស្នូលអភិវឌ្ឍមួយទៅស្នូលអភិវឌ្ឍមួយទៀត **គឺពីតំ**បន់នគរូបនីយកម្មកម្រិតខ្ពស់ ទៅតំបន់នគរូបនីយកម្មកម្រិតមធ្យម និងទៅតំបន់**នគរូបនីយ**កម្មកម្រិតទាប
- បណ្តាញផ្លូវថ្នល់នៅផ្នែកខាងជើងនិងបណ្តាញផ្លូវថ្នល់នៅផ្នែកខាងត្បូង ដើម្បីធានាការដឹកជញ្ជូនក្នុងខេត្តនិងឆ្លងកាត់ខេត្ត
- បណ្តាញផ្លូវថ្នល់នៅផ្នែកខាងជើង គឺសម្រាប់តភ្ជាប់រវាងស្រុកថ្មគោលនិងស្រុកបវេលដែលជាមជ្ឈមណ្ឌលផ្គត់ផ្គង់ និងបង្កើនសកម្មភាពសេដ្ឋកិច្ចដល់តំបន់នៅតាមព្រំដែនដូចជាស្រុកកំរៀង ស្រុកភ្នំព្រឹក និងស្រុកសំពៅលូន

- បណ្តាញផ្លូវថ្នល់នៅផ្នែកខាងត្បូង គឺសម្រាប់តភ្ជាប់រវាងក្រុងបាត់ដំបង ស្រុករតនមណ្ឌលនិងស្រុកសំឡូត និងរវាងក្រុងបាត់ដំបង ស្រុកមោងឫស្សី និងស្រុកគាស់ក្រឡ ព្រមទាំងសម្រាប់តភ្ជាប់រវាងស្រុកសំឡូតនិងស្រុកគាស់ក្រឡ។

ខ). បណ្តាញផ្លូវអយស្ម័យយាននិងស្ថានីយរថភ្លើង

- បណ្តាញផ្លូវអយស្ម័យយានភ្នំពេញ-ក្រុងបាត់ដំបង-ក្រុងប៉ោយប៉ែត
- ស្ថានីយរថភ្លើងក្រុងបាត់ដំបង។

គ). បណ្តាញផ្លូវទឹកនិងកំពង់ផែ

- តាមផ្លូវទឹកនៃស្ទឹងសង្កែ ដែលជាបណ្តាញផ្លូវទឹកសំខាន់នៅក្នុងខេត្តនិងតភ្ជាប់ទៅបឹងទន្លេសាប
- កំពង់ផែទី១ស្ថិតនៅក្នុងក្រុងបាត់ដំបង ប្រើប្រាស់សម្រាប់អ្នកទេសចរធ្វើដំណើរទៅមកក្នុងខេត្តបាត់ដំបងនិងទៅកាន់ខេត្តសៀមរាប
- កំពង់ផែទី២ស្ថិតនៅទល់មុខផ្សារឃុំព្រៃកនរិន្ទ ស្រុកឯកភ្នំ ប្រើប្រាស់សម្រាប់ការដឹកជញ្ជូនទំនិញផ្សេងៗនិងការចូលចតរបស់កាណូតធំៗនៅរដូវវស្សា។

ឃ). បណ្តាញផ្លូវអាកាស

- អាកាសយានដ្ឋានបច្ចុប្បន្ន មានទីតាំងនៅក្នុងក្រុងបាត់ដំបង តាមបណ្តោយផ្លូវជាតិលេខ ៥ អាចបង្កនូវការរំខាននិងហានិភ័យផ្សេងៗដល់តំបន់ពាណិជ្ជកម្មនិងលំនៅឋានដែលនៅជុំវិញ ដូចនេះទីតាំងថ្មីសម្រាប់សាងសង់ព្រលានយន្តហោះ គួរត្រូវបានកំណត់ដើម្បីត្រៀមលក្ខណៈសម្រាប់ការអភិវឌ្ឍការដឹកជញ្ជូនតាមផ្លូវអាកាសក្នុងពេលអនាគត។

៤.៣.៣- ការគ្រប់គ្រងទីជម្រាល

យុទ្ធសាស្ត្រគ្រប់គ្រងទីជម្រាលឱ្យមានចីរភាព គុណ្យភាព និងនិរន្តរភាពធារាសាស្ត្រ ដើម្បីកាត់បន្ថយការហូរច្រោះ ឬគោកភ ក់នៅបាតខ្សែទឹកធម្មជាតិ ការប៉ះពាល់ដល់បរិមាណនិងគុណភាពទឹក និងធនធានធម្មជាតិ គឺ៖

ក). កំណត់តំបន់ដីព្រៃគ្រប់ប្រភេទ និងធ្វើចំណាត់ថ្នាក់ដីព្រៃ ដូចជាដីព្រៃបម្រុងទុកអចិន្ត្រៃយ៍ តំបន់ការពារ និងដីព្រៃឯកជន។

ខ). កំណត់តំបន់ការពារព្រំប្រទល់ និងដែនប្រតិបត្តិការឱ្យបានច្បាស់លាស់ ដូចជាតំបន់ស្ងួល (ព្រៃកទាល់) តំបន់អភិរក្ស តំបន់ប្រើប្រាស់ប្រកបដោយចីរភាព និងតំបន់សហគមន៍។

គ). តំបន់សហគមន៍ព្រៃឈើ តាមរយៈការចុះកិច្ចព្រមព្រៀងជាមួយសហគមន៍ព្រៃឈើដែលបានកំណត់រួច មានចំនួន៥១ទីតាំង និងការកំណត់តំបន់សហគមន៍ព្រៃឈើថ្មីបន្ថែមទៀតចំនួន៣៣ទីតាំង។

ឃ). តំបន់ជ្រាលទំនាបជាប់បឹងទន្លេសាប តាមរយៈការគ្រប់គ្រងការប្រើប្រាស់ដីក្នុងតំបន់នីមួយៗ និងការគ្រប់គ្រងសហគមន៍នេសាទ ដែលបានកំណត់រួចមានចំនួន១២ទីតាំង តាមរយៈការចុះកិច្ចព្រមព្រៀងជាមួយសហគមន៍ទាំងនោះ។

ង). ទីជម្រាលជាប់ខ្សែទឹកធម្មជាតិ តាមរយៈការគ្រប់គ្រងលើការប្រើប្រាស់ដីកសិកម្មនៅតាមតំបន់ជាប់ផ្លូវទឹកធម្មជាតិ មានបឹងទន្លេសាប ស្ទឹង ព្រែក អូរ បឹង។ល។ ដែលអាចបណ្តាលឱ្យមានការសឹករេចរឹលដី ការហូរច្រោះដីឬបាត់បង់គុណភាពដី និងការគ្រប់គ្រងលើការប្រើប្រាស់ជាតិគីមីពុលឬផលិតផលគ្រោះថ្នាក់ផ្សេងទៀត ដែលអាចប៉ះពាល់ដល់គុណភាពទឹក សុខភាពមនុស្ស និងសត្ត។

៤.៣.៤- ការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រនិងកសិកម្ម

ប្រព័ន្ធធារាសាស្ត្រនិងកសិកម្ម ដែលត្រូវគ្រប់គ្រងនិងអភិវឌ្ឍដើម្បីបង្កើនសមត្ថភាពផលិតប្រកបដោយគុណភាពនិងបរិមាណគ្រប់គ្រាន់នៅគ្រប់តំបន់ និងគ្រប់រដូវកាល គឺ៖

ក). ប្រព័ន្ធប្រឡាយមេសំខាន់ៗចំនួន៦កន្លែង មានប្រព័ន្ធធារាសាស្ត្រស្ទឹងបវេល ប្រព័ន្ធធារាសាស្ត្រស្ទឹងមោងឬស្សី ប្រព័ន្ធធារាសាស្ត្រអាងទឹកកំពីងពួយ ប្រព័ន្ធធារាសាស្ត្រអាងទឹកសាលាតអន ប្រព័ន្ធធារាសាស្ត្រទំនប់កង្គត និងប្រព័ន្ធធារាសាស្ត្រអាងទឹកមានល័ក្ខ ដែលមានសក្តានុពលគ្របដណ្តប់ដល់តំបន់ផលិតកម្មស្រូវនៅទូទាំងខេត្ត។

ខ). ជំរុញការអភិវឌ្ឍកសាងអាងទឹកថ្មីសំខាន់ៗចំនួនពាក់កន្លែង មានអាងទឹកស្ទឹងកុយ អាងទឹកស្ទឹងដូនទ្រី និងអាងទឹកស្ទឹងក្រញ្ជូង។

គ). តំបន់ខ្ពង់រាបនៃខេត្តមានសក្តានុពលសម្រាប់ដំណាំកសិ-ឧស្សាហកម្ម សម្រាប់ការអភិវឌ្ឍរយៈពេលវែង៖ ការការពារប្រព័ន្ធជីវៈចម្រុះរបស់ដី និងការកែលម្អគុណភាពធនធានដីឡើងវិញទាំងផ្នែកគីមីសាស្ត្រ ទាំងផ្នែករូបសាស្ត្រ តាមរយៈការប្រើប្រាស់បច្ចេកទេសវិស្វកម្មទំនើបដើម្បីគ្រប់គ្រងសណ្ឋានដីនិងចរន្តទឹកហូរ។

ឃ). ការកែច្នៃផលិតផលកសិកម្មចម្រុះនៅតាមតំបន់និងការកែលម្អចង្វាក់ផលិតកម្មកសិកម្ម មូលដ្ឋានទាំងបរិមាណ ទាំងគុណភាព និងត្រូវលើកកម្ពស់ការផ្សព្វផ្សាយទីផ្សារ**សម្រាប់**ផលិតផលក្នុងស្រុកដោយចុះបញ្ជីផ្លាកសម្គាល់ភូមិសាស្ត្រទំនិញ "ផលិតផលខេ**ត្តបាត់**ដំបង"។

ង). ស្រុករតនមណ្ឌលនិងស្រុកបាណន់ ដែលជាតំបន់មានស្រទាប់ដីរាក់និងគ្មាន**អំណោយផល**ដល់ការធ្វើកសិកម្ម ត្រូវធ្វើការអភិវឌ្ឍការចិញ្ចឹមសត្វពាហនៈ។

ច). ស្រុកបវេល ស្រុកថ្មគោល ស្រុកមោងឬស្សី និងស្រុកសង្កែ ដែលជាតំបន់មានផលិតផលស្រូវខ្ពស់ ត្រូវធ្វើការអភិវឌ្ឍចិញ្ចឹមសត្វជ្រូក។

ឆ). ស្រុកគាស់ក្រឡ ស្រុកសំឡូត និងស្រុកមោងឫស្សី ដែលជាតំបន់មានអំណោយផលសម្រាប់ការចិញ្ចឹមសត្ត ពិសេសគោ ក្របី។

៤.៣.៥- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធបច្ចេកទេសនិងឧស្សាហកម្ម

២៥៥-វរសេនីយ៍ទោ	**ឆ្លាម ហ្ស៊ីយហុង**	អត្តលេខ ០៦៨៧៨០	នាយ ការិយាល័យសុខាភិបាល ទីចាត់ការចលនូប្បត្តម្ភ
២៥៦-វរសេនីយ៍ទោ	**ញ៉ែម សាវ៉ាន**	អត្តលេខ ០៦៩៧២១	នាយករង សាលាបើកបរ ទីចាត់ការចលនូប្បត្តម្ភ
២៥៧-វរសេនីយ៍ទោ	**ច័ន្ទ សឌ្ឍីណា**	អត្តលេខ ០៤៤៩៦៦	នាយករង សាលាបើកបរ ទីចាត់ការចលនូប្បត្តម្ភ
២៥៨-វរសេនីយ៍ទោ	**ស៊ីម សុគន្ធ**	អត្តលេខ ០០៩១០៦	មេបញ្ជាការរង កងពលតូចដឹកជញ្ជូន៩០ ទីចាត់ការចលនូប្បត្តម្ភ
២៥៩-វរសេនីយ៍ទោ	**សួន ស៊ីថា**	អត្តលេខ ០១៤៣០០	មេបញ្ជាការរង កងពលតូចដឹកជញ្ជូន៩០ ទីចាត់ការចលនូប្បត្តម្ភ
២៦០-វរសេនីយ៍ទោ	**ពេជ្រ សុជាតិ**	អត្តលេខ ០៥៩៥១៣	ជំនួយការ ឯកឧត្តម នាយក ទីចាត់ការចលនូប្បត្តម្ភ
២៦១-វរសេនីយ៍ទោ	**ឌឹម សម្ស្ត្ត**	អត្តលេខ ១០៤១៦៨	នាយរង ការិយាល័យផ្ទៃការ ទីចាត់ការកលយុទ្ធ

២៦២-វរសេនីយ៍ទោ	**សែម ស៊ីថាច**	អត្តលេខ ០៦៥៣២៩	នាយសេនាធិការរង បញ្ជាការដ្ឋានកាំភ្លើងធំ កងទ័ពជើងគោក
២៦៣-វរសេនីយ៍ទោ	**អួន ហ្ជង**	អត្តលេខ ០៣៣២៤៧	នាយរង ការិយាល័យស្រាវជ្រាវភូមិសាស្ត្រ បច្ចេកទេស ទីចាត់ការការងារព្រំដែន
២៦៤-វរសេនីយ៍ទោ	**ភាន់ សុវណ្ណារិទ្ធ**	អត្តលេខ ០៣៩២២៧	នាយរង ការិយាល័យទំនាក់ទំនង សាធារណៈ ខុទ្ទកាល័យ អគ្គបញ្ជាការដ្ឋាន
២៦៥-វរសេនីយ៍ទោ	**ឆ្ម ឥណ្ណៈ**	អត្តលេខ ០២៥៣២៩	នាយរង ការិយាល័យមន្ទីរពិសោធន៍ ទីចាត់ការការពារគីមីសាស្ត្រ
២៦៦-វរសេនីយ៍ទោ	**រ៉ាំ ផល្លីន**	អត្តលេខ ១៥៧៩៩៣	នាយរង ការិយាល័យបណ្តុះបណ្តាល ទីចាត់ការបុគ្គលិក
២៦៧-វរសេនីយ៍ទោ	**ឃឹម ពៅ**	អត្តលេខ ០៥៩៤៩៩	នាយរង ការិយាល័យសន្តិសុខផ្ទៃក្នុង ទីចាត់ការបុគ្គលិក
២៦៨-វរសេនីយ៍ទោ	**ខ្ជូត សាឯម**	អត្តលេខ ០០៨៧៣៣	ជំនួយការ ឯកឧត្តម ប៉ុល ស៊ីនួន
២៦៩-វរសេនីយ៍ទោ	**ឆង់ ច័ន្ទធី**	អត្តលេខ ០៤៧៨៤៩	នាយរង អធិការកិច្ច កងទ័ពជើងគោក
២៧០-វរសេនីយ៍ទោ	**ឃឹម ញ៉ែម**	អត្តលេខ ០១៨០៣៦	នាយសេនាធិការរង កងពលធំអន្តរាគមន៍លេខ៣
២៧១-វរសេនីយ៍ទោ	**ឆែម សំណាង**	អត្តលេខ ០២៦៦៧២	នាយសេនាធិការរង កងពលធំអន្តរាគមន៍លេខ៣
២៧២-វរសេនីយ៍ទោ	**ហាស ឫទ្ធម**	អត្តលេខ ០៥៨១៤៨	នាយការិយាល័យទី៣ កងពលធំអន្តរាគមន៍លេខ៣
២៧៣-វរសេនីយ៍ទោ	**ឥន្ទ្រ ឆវី**	អត្តលេខ ០៥៨១៨៣	នាយការិយាល័យអភិវឌ្ឍន៍ កងពលធំអន្តរាគមន៍លេខ៣
២៧៤-វរសេនីយ៍ទោ	**ដុះ ឆុត**	អត្តលេខ ០១៨០៣៣	ជំនួយការ ឯកឧត្តម មេបញ្ជាការ កងពលធំអន្តរាគមន៍លេខ៣
២៧៥-វរសេនីយ៍ទោ	**សេត ស៊ីនណារ៉ា**	អត្តលេខ ០០៩៣០២	ជំនួយការ ឯកឧត្តម មេបញ្ជាការ កងពលធំអន្តរាគមន៍លេខ៣
២៧៦-វរសេនីយ៍ទោ	**ម៉ែ ជំនោរ**	អត្តលេខ ០៦៥៦៤១	ជំនួយការ ឯកឧត្តម មេបញ្ជាការ កងពលធំអន្តរាគមន៍លេខ៣
២៧៧-វរសេនីយ៍ទោ	**ជា ឈុន**	អត្តលេខ ០១២០៧៥	មេបញ្ជាការរង កងពលតូចអន្តរាគមន៍លេខ៨
២៧៨-វរសេនីយ៍ទោ	**យ៉ែម ឥណ្ណដេត**	អត្តលេខ ០២១៩១៦	មេបញ្ជាការរង កងពលតូចអន្តរាគមន៍លេខ៨
២៧៩-វរសេនីយ៍ទោ	**ស្វាយ សុតាត**	អត្តលេខ ០៧១៣២៧	មេបញ្ជាការរង កងពលតូចអន្តរាគមន៍លេខ៩

២៨០-វរសេនីយ៍ទោ	**ទូច ឌន់**	អត្តលេខ ០០៣៣៨៩	មេបញ្ជាការរង កងពលតូចអន្តរាគមន៍លេខ៩
២៨១-វរសេនីយ៍ទោ	**តាម ពៅ**	អត្តលេខ ១៣១៨១៣	មេបញ្ជាការរង កងពលតូចអន្តរាគមន៍លេខ៩
២៨២-វរសេនីយ៍ទោ	**ប្រាក់ រុន**	អត្តលេខ ២៣០៧៦៦	ជំនួយការ ឯកឧត្តម អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃអង្គារ ៧ រោច ខែបឋមាសាឍ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស ២៥៦២
ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៨

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៥៨០ អនក្រ.តត

អនុក្រឹត្យ
ស្តីពី
ការតែងតាំង និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការ
រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ៦៣ អនក្រ.បក ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តន៍ ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្ត និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

សម្រេច

មាត្រា ១.- តែងតាំង និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការចំនួន ០៦រូប នៅអគ្គលេខាធិការដ្ឋាន គណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បន្ថែមលើមុខងារបច្ចុប្បន្ន ដូចមានរាយនាមខាងក្រោម៖

១-លោក	**ទុត សោភ័ណ**	តែងតាំងជាអគ្គលេខាធិការរង មានឋានៈស្មើ **អគ្គនាយករង**
២-លោក	**តាំង សុភ័ក្ត្រ**	តែងតាំងជាអគ្គលេខាធិការរង មានឋានៈស្មើ **អគ្គនាយករង**
៣-លោក	**ឯម សោភ័ណ្ណារិទ្ធ**	តែងតាំងជាអគ្គលេខាធិការរង មានឋានៈស្មើ **អគ្គនាយករង**
៤-លោក	**ផន ស៊ីឫទ្ធា**	ប្រគល់ភារកិច្ចឱ្យបំពេញមុខងារជាអគ្គលេខាធិការរង មានឋានៈស្មើ **អគ្គនាយករង**

៥-លោក **កែ ឧត្តម** តែងតាំងជាអគ្គលេខាធិការរង មានឋានៈស្មើ **អគ្គនាយករង**

៦-លោកស្រី **ឃឿន ច័ន្ទមុនីកា** តែងតាំងជាអគ្គលេខាធិការរង មានឋានៈស្មើ **អគ្គនាយករង**។

មាត្រា ២.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ១០ កើត ខែបដ្ឋមាសឆ្នាំ ច សំរឹទ្ធិស័ក ព.ស. ២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ២០១៨

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

ករណ្ឌទទួល៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៣៦...ស.ណ.ន

សេចក្តីសម្រេច
ស្តីពី
ការបង្កើតគណៈកម្មការត្រួតពិនិត្យ និងវាយតម្លៃស្ថានភាពហិរញ្ញវត្ថុ និងទុនវិនិយោគ របស់ក្រុមហ៊ុនសម្បទានព្រលានយន្តហោះ (SCA)

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញកិច្ចព្រមព្រៀងសម្បទានរវាងរាជរដ្ឋាភិបាលកម្ពុជា និងក្រុមហ៊ុនសម្បទានព្រលានយន្តហោះ (SCA) ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ១៩៩៥
- បានឃើញកិច្ចព្រមព្រៀងសម្បទានបន្ថែមលើកទី១ រវាងរាជរដ្ឋាភិបាលកម្ពុជា និងក្រុមហ៊ុនសម្បទានព្រលានយន្តហោះ (SCA) ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ១៩៩៧
- បានឃើញកិច្ចព្រមព្រៀងសម្បទានបន្ថែមលើកទី២ រវាងរាជរដ្ឋាភិបាលកម្ពុជា និងក្រុមហ៊ុនសម្បទានព្រលានយន្តហោះ (SCA) ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ១៩៩៩
- បានឃើញកិច្ចព្រមព្រៀងសម្បទានបន្ថែមលើកទី៣ រវាងរាជរដ្ឋាភិបាលកម្ពុជា និងក្រុមហ៊ុនសម្បទានព្រលានយន្តហោះ (SCA) ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០០
- បានឃើញកិច្ចព្រមព្រៀងសម្បទានបន្ថែមលើកទី៤ រវាងរាជរដ្ឋាភិបាលកម្ពុជា និងក្រុមហ៊ុនសម្បទានព្រលានយន្តហោះ (SCA) ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០០១
- បានឃើញកិច្ចព្រមព្រៀងសម្បទានបន្ថែមលើកទី៥ រវាងរាជរដ្ឋាភិបាលកម្ពុជា និងក្រុមហ៊ុនសម្បទានព្រលានយន្តហោះ (SCA) ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០០៣
- បានឃើញកិច្ចព្រមព្រៀងសម្បទានបន្ថែមលើកទី៦ រវាងរាជរដ្ឋាភិបាលកម្ពុជា និងក្រុមហ៊ុនសម្បទានព្រលានយន្តហោះ (SCA) ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០០៦
- យោងតាមការចាំបាច់

សម្រេច

ប្រការ ១.-

ត្រូវបានបង្កើតគណៈកម្មការត្រួតពិនិត្យ និងវាយតម្លៃស្ថានភាពហិរញ្ញវត្ថុ និងទុនវិនិយោគរបស់ក្រុមហ៊ុនសម្បទានព្រលានយន្តហោះ (SCA) ដែលមានសមាសភាពដូចខាងក្រោម ៖

១.ឯកឧត្តម	**ចី តាយី**	រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	ប្រធាន
២.ឯកឧត្តម	**ជា ម៉ាន់ដេត**		អនុប្រធាន
៣.ឯកឧត្តម	**ហ៊ីង ថ្ងៃរ៉ាក់ស៊ី**	រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី	សមាជិក
៤.ឯកឧត្តម	**គង់ ឫទ្ធិ**	ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ	សមាជិក
៥.ឯកឧត្តម	**គង់ ច័ន្ទវាសនា**	ទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ	សមាជិក
៦.ឯកឧត្តម	**ហាក់ សុខហេង**	អគ្គលេខាធិការរងក្រុមប្រឹក្សាអ្នកច្បាប់	សមាជិក
៧.លោក	**តាន់ ឌីកលីន**	ទីប្រឹក្សាក្រុមប្រឹក្សាជាតិគណនេយ្យ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក
៨.លោក	**ដេន ផាត**	ប្រធាននាយកដ្ឋានអនុលោមភាព និងត្រួតពិនិត្យ នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគណនេយ្យ	សមាជិក
៩. លោក	**លី រស្មី**	មន្ត្រីនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់	សមាជិក
១០. លោក	**ចី ឌិទ្ធ**	មន្ត្រីអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគណនេយ្យ	សមាជិក។

ប្រការ ២.-

គណៈកម្មការត្រួតពិនិត្យ និងវាយតម្លៃស្ថានភាពហិរញ្ញវត្ថុ និងទុនវិនិយោគរបស់ក្រុមហ៊ុនសម្បទានព្រលានយន្តហោះ (SCA) មានភារកិច្ចដូចខាងក្រោម៖

- សិក្សាលំអិតលើកិច្ចព្រមព្រៀងសម្បទានទាំងអស់ ដែលរាជរដ្ឋាភិបាលបានចុះហត្ថលេខាជាមួយក្រុមហ៊ុនសម្បទានព្រលានយន្តហោះ (SCA) ដើម្បីផ្ទៀងផ្ទាត់ការអនុវត្តគម្រោងចាប់តាំងពីពេលចាប់ផ្តើមរហូតដល់ពេលបច្ចុប្បន្ន
- ត្រួតពិនិត្យ និងវាយតម្លៃការវិនិយោគរបស់ក្រុមហ៊ុនសម្បទានព្រលានយន្តហោះ (SCA) ទៅលើព្រលានយន្តហោះអន្តរជាតិទាំងបី រាជធានីភ្នំពេញ ខេត្តសៀមរាប និងខេត្តព្រះសីហនុ
- ត្រួតពិនិត្យបញ្ជីគណនេយ្យរបស់ក្រុមហ៊ុនសម្បទានព្រលានយន្តហោះ (SCA) ដើម្បីទទួលបានទិន្នន័យវិនិយោគ និងកំណត់ឱ្យបានត្រឹមត្រូវអំពីស្ថានភាពហិរញ្ញវត្ថុ រួមទាំងការគណនាអត្រាចំណូល (IRR) របស់ក្រុមហ៊ុន
- អនុវត្តភារកិច្ចផ្សេងទៀត ដែលរាជរដ្ឋាភិបាលប្រគល់ជូន។

ប្រការ ៣.-

គណៈកម្មការត្រួតពិនិត្យ និងវាយតម្លៃស្ថានភាពហិរញ្ញវត្ថុ និងការវិនិយោគរបស់ក្រុមហ៊ុនសម្បទានព្រលានយន្តហោះ (SCA) អាចអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ និងអ្នកជំនាញ ដើម្បីពិគ្រោះយោបល់ ឬចូលរួមក្នុងកិច្ចប្រជុំរបស់ខ្លួន ឬចូលរួមក្នុងការសិក្សាស្រាវជ្រាវ និងផ្តល់យោបល់តាមការចាំបាច់។

គណៈកម្មការត្រួតពិនិត្យ និងវាយតម្លៃស្ថានភាពហិរញ្ញវត្ថុ និងការវិនិយោគរបស់ក្រុមហ៊ុនសម្បទានព្រលានយន្តហោះ (SCA) មានសិទ្ធិបង្កើតអនុគណៈកម្មការ ឬក្រុមការងារ តាមការចាំបាច់។

ប្រការ ៤.-

សមាជិកគណៈកម្មការ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬអនុប្រធានតាមការប្រគល់សិទ្ធិរបស់ប្រធាន។

ប្រការ ៥.-

គណៈកម្មការត្រួតពិនិត្យ និងវាយតម្លៃស្ថានភាពហិរញ្ញវត្ថុ និងការវិនិយោគរបស់ក្រុមហ៊ុនសម្បទានព្រលានយន្តហោះ (SCA) ប្រើប្រាស់ត្រារបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់បំពេញការងារ។

ប្រការ ៦.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

ប្រការ ៧.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមការកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៧ កើត ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ២០១៨

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល ៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ០៤ សជ

សារាចរ
ស្តីពី
ការពង្រឹងបន្ថែមលើការងារគ្រប់គ្រងវិស័យសកម្មភាពមីន

សកម្មភាពបោសសម្អាតមីនត្រូវបានរាជរដ្ឋាភិបាលកម្ពុជាកំណត់យកធ្វើជាអាទិភាពចម្បង សំដៅរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ និងជំរុញការអភិវឌ្ឍ។ រាជរដ្ឋាភិបាលបានកំណត់នូវចក្ខុវិស័យយ៉ាងច្បាស់លាស់ គឺ **«ប្រទេសកម្ពុជាគឺជាប្រទេសដែលគ្មានមីន ការគំរាមកំហែងដោយសំណល់ជាតិផ្ទុះពីសង្គ្រាម ត្រូវបានកាត់បន្ថយឱ្យនៅកម្រិតអប្បបរមា ហើយការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងការអភិវឌ្ឍមនុស្សអាចប្រព្រឹត្តទៅដោយសុវត្ថិភាព»**។ តាមរយៈចក្ខុវិស័យនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវផែនការយុទ្ធសាស្ត្រជាក់លាក់ ដោយកំណត់យកឆ្នាំ២០២៥ ជាឆ្នាំដែលកម្ពុជាគ្មានគ្រាប់មីន។ ដើម្បីឈានទៅសម្រេចបានជោគជ័យតាមយុទ្ធសាស្ត្រនេះ រាជរដ្ឋាភិបាលធ្វើការណែនាំ ដូចខាងក្រោម៖

១. ប្រតិបត្តិករបោសសម្អាតមីនជាតិ អន្តរជាតិទាំងអស់ ត្រូវបន្តពង្រឹងគុណភាព សុវត្ថិភាព គណនេយ្យភាព និងប្រសិទ្ធភាពចំពោះការងាររបស់ខ្លួន ដើម្បីទទួលបាននូវការគាំទ្រ និងការជឿទុកចិត្តពីដៃគូពាក់ព័ន្ធ។

២. ប្រតិបត្តិករជាតិ អន្តរជាតិ និងភាគីពាក់ព័ន្ធត្រូវបន្តអនុវត្តឱ្យបានខ្ជាប់ខ្ជួនតាមផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន ២០១៨-២០២៥ ស្តង់ដាជាតិសកម្មភាពមីន ផែនការ គោលការណ៍ណែនាំ និងសេចក្តីណែនាំនានា ដែលចេញដោយអាជ្ញាធរមីន។

៣. ប្រតិបត្តិករជាតិ អន្តរជាតិទាំងអស់ ត្រូវបន្តពង្រឹង លើកកម្ពស់កិច្ចសហប្រតិបត្តិការ និងភាពជាដៃគូជាមួយអាជ្ញាធរមីន ជាពិសេសការផ្តល់ទិន្នន័យ និងព័ត៌មាន រួមមាន ព័ត៌មានស្តីពីហិរញ្ញវត្ថុ សម្ភារៈ កម្លាំងប្រតិបត្តិការ និងជំនួយបច្ចេកទេស ដើម្បីឱ្យអាជ្ញាធរមីនមានលទ្ធភាពបូកសរុប និងរាយការណ៍ជូនរាជរដ្ឋាភិបាល និងភាគីពាក់ព័ន្ធ។

៤. ប្រតិបត្តិករជាតិ អន្តរជាតិទាំងអស់ ត្រូវលើកកម្ពស់កិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរមីន និងអាជ្ញាធរថ្នាក់ក្រោមជាតិ ដើម្បីធានានូវការរៀបចំនិងការអនុវត្តផែនការបោសសម្អាតមីនប្រចាំឆ្នាំប្រកបដោយប្រសិទ្ធភាពខ្ពស់។

៥. អាជ្ញាធរមីនត្រូវផ្តល់ជាត្រីវិស័យដល់ប្រតិបត្តិករទាំងអស់ ដើម្បីគោរពឱ្យបាននូវគោលការណ៍ណែនាំសម្រាប់ការធ្វើផែនការបោសសម្អាត និងបន្តដឹកនាំតាមការអនុវត្តផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន ២០១៨-២០២៥ ឱ្យមានប្រសិទ្ធភាពខ្ពស់។

ទទួលបានសារាចរនេះ គ្រប់ក្រសួង ស្ថាប័ន អាជ្ញាធរមីន ប្រតិបត្តិករបោសសម្អាតមីន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃ ១ រោច ៨ កើត ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ ០៧ ឆ្នាំ ២០១៨

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ធកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ធកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- សាលារាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ...២០២... សហវ...

ប្រកាសអន្តរក្រសួង
ស្តីពី
ការបន្ថែមរដូវទេយ្យបុរេប្រទាន សម្រាប់ឆ្នាំ២០១៨
របស់សាលាភូមិន្ទរដ្ឋបាល

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

រដ្ឋមន្ត្រី
ក្រសួងមុខងារសាធារណៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/០៤១៦/៣៦៨ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៦/០១៩ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧
- បានឃើញព្រះរាជក្រមលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី០៣ ខែមិនា ឆ្នាំ២០១៥ ស្តីពីការកែឬសម្រួលមាត្រ៤៤ មាត្រា៤៥ មាត្រា៤៧ នៃអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ផ្ទះលេខ ៥២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92. Sangkat Wat Phnom . khan Daun Penh. Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៤៣០ ២២៥ ទូរសារ : ៨៥៥-២៣-៤៣០ ៧៩៩
Phone : 855-23-430 225 / Fax : 855-23-430 799

- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានឃើញប្រកាសលេខ ៣១១៩ មស.ប្រក ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃការិយាល័យចំណុះឲ្យនាយកដ្ឋាននានារបស់សាលាភូមិន្ទរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២១៤/១៩៥ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការកែសម្រួលព្រះរាជក្រឹត្យលេខ នស/រកត/០៤៩៥/៤០ ស្តីពីការបង្កើតសាលាភូមិន្ទរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិកា នៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានី ភ្នំពេញ និង អង្គការសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ៥២៣ សហវ.ម.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការដាក់អនុវត្ត ចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋាភិបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ១២១២ សហវ.ម.ប្រក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៧ស្តីពីការដាក់ឲ្យអនុវត្ត មាតិកាគណនី នៃប្លង់គណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ១៥៩៨ សហវ.ម.ប្រក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការបង្កើតបន្ថែមគណនី នៃប្លង់គណនេយ្យថវិការបស់រដ្ឋាភិបាលជាតិ និង រដ្ឋាភិបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ១៨៧៩ សហវ.ម.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការបង្កើតបន្ថែមគណនី នៃប្លង់គណនេយ្យថវិការបស់រដ្ឋាភិបាលថ្នាក់ជាតិ និង រដ្ឋាភិបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ១៩៣៧ សហវ.ម.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរដ្ឋទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- បានឃើញប្រកាសលេខ ៨២៩ សហវ.ម.ប្រក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលប្រការ៤ ប្រការ៥ ប្រការ១៤ ប្រការ១៦ ប្រការ ១៧ នៃប្រកាសលេខ: ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរដ្ឋទេយ្យបុរេប្រទានសម្រាប់ រដ្ឋបាលថ្នាក់ជាតិ
- បានឃើញប្រកាសលេខ ១២២០៦ សហវ.អថ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការកំណត់ស្ថានភាពគតិយុត្តរបស់សាលាភូមិន្ទរដ្ឋបាល គឺជាគ្រឹះស្ថានបណ្តុះបណ្តាលសាធារណៈ និងជាអង្គភាពថវិកាអាណាប័ត្តផ្ទៃសិទ្ធ ។
- យោងតាមតម្រូវការចាំបាច់នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង សាលាភូមិន្ទរដ្ឋបាល

សម្រេច

ប្រការ ១.

ត្រូវបានបង្កើតរដ្ឋទេយ្យបុរេប្រទានជំពូក៦៥(ឧបត្ថម្ភកធន) នៅសាលាភូមិន្ទរដ្ឋបាល សម្រាប់មុខសញ្ញ ចំណាយដូចមានចែងក្នុងប្រការ៥ថ្មី នៃប្រកាសលេខ៨២៩ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួល ប្រការ៤ ប្រការ៥ ប្រការ១៤ ប្រការ១៦ ប្រការ១៧ នៃប្រកាសលេខ:១៩៧៣ សហវ.ប្រកចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាម រដ្ឋទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ។ តារាងឧបសម្ព័ន្ធរដ្ឋទេយ្យបុរេប្រទានត្រូវបានកំណត់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

ប្រការ ២.

ចំនួនទឹកប្រាក់មួយជុំបង្វិលនៃផ្ទេរទេយ្យប្រទានត្រូវបានកំណត់ដូចក្នុងតារាងឧបសម្ព័ន្ធផ្ទេរទេយ្យបុរេប្រទាន។

ប្រការ ៣.

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះត្រូវទុកជានិរាករណ៍។

ប្រការ ៤.

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ និងក្រសួងមុខងារសាធារណៈព្រមទាំងសាលាកូមិន្ទរដ្ឋបាល ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះតាមការកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃ ១ រោចខែកត្តិក ខែនវម្មី ឆ្នាំកុរ នព្វស័ក ព.ស ២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ២០១៨

រដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

រដ្ឋមន្ត្រី
ក្រសួងមុខងារសាធារណៈ

បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

ពេជ្រ ប៊ុនធិន

អនុវត្ត១ច្បាប់ចម្លងៈ
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមុខងារសាធារណៈ
-អគ្គលេខាធិការដ្ឋានរដ្ឋសភាតិចាល
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
-ដូចប្រការ ៤
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
១១❖១១

ក្រសួងមុខងារសាធារណៈ
សាលាភូមិន្ទរដ្ឋបាល
១១❖១១

តារាងឧបសម្ព័ន្ធរដ្ឋទេយ្យបុរេប្រទានថវិកាកម្មវិធីឆ្នាំ២០១៨
របស់អង្គភាពថវិកាសាលាភូមិន្ទរដ្ឋបាល

ឯកតា:រៀល

ជំពូក	គណៈ	អនុគណៈ	បរិយាយ	ចម្លាប់ហិរញ្ញវត្ថុ ឆ្នាំ២០១៨	តំណាងដែលជ្រើសរើស	តំណាងរដ្ឋទេយ្យបុរេប្រទាន	តំណាងទូទាត់ធម្មតា	តំណាង១ជុំបង្វិលរដ្ឋទេយ្យបុរេប្រទាន	ភាគរយ
				១	២	៣	៤=២-៣	៥=៣/៤ជុំ	៦=៣/២
			សរុបរួម	**5,623,000,000**	**5,623,000,000**	**1,524,000,000**	**4,099,000,000**	**381,000,000**	**27.1%**
65			**ឧបត្ថម្ភធន**	**5,623,000,000**	**5,623,000,000**	**1,524,000,000**	**4,099,000,000**	**381,000,000**	**27.1%**
	6503		ឧបត្ថម្ភធនដល់គ្រឹះស្ថានមានលក្ខណៈរដ្ឋបាល	5,623,000,000	5,623,000,000	1,524,000,000	4,099,000,000	381,000,000	27.1%
		65031	ឧបត្ថម្ភធនជាហិរញ្ញវត្ថុដល់គ្រឹះស្ថានមានលក្ខណៈរដ្ឋបាល	5,623,000,000	5,623,000,000	1,524,000,000	4,099,000,០០០	381,000,000	27.1%

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃ[illegible] ខែ[illegible] ឆ្នាំកា នព្វស័ក ព.ស.២៥៦១
ថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ២០១៨
ជ.ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា
អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ
អគ្គនាយក

ហ៊ីញ ចានសុវណ្ណារ៉ានីចាស៊ីលា

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃ[illegible] ខែ[illegible] ឆ្នាំកា នព្វស័ក ព.ស.២៥៦១
ថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ២០១៨
ជ.អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា
ប្រធានក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ
អមក្រសួងមុខងារសាធារណៈ

[illegible]

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃ[illegible] ខែ[illegible] ឆ្នាំកា នព្វស័ក ព.ស.២៥៦១
ថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ២០១៨
ប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

[illegible]

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំកា នព្វស័ក ព.ស.២៥៦១
ថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ២០១៨
រដ្ឋទេយ្យករបុរេប្រទាន

[illegible]

បានឃើញ និងឯកភាព
ថ្ងៃ[illegible] ខែ[illegible] ឆ្នាំកា នព្វស័ក ព.ស.២៥៦១
រាជធានីភ្នំពេញថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ២០១៨
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ហ៊ីង ប៉ាណារ

បានឃើញ និងឯកភាព
ថ្ងៃ[illegible] ខែ[illegible] ឆ្នាំកា នព្វស័ក ព.ស.២៥៦១
រាជធានីភ្នំពេញថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ២០១៨
ប្រធានអង្គភាពថវិកា

ឃាត់ ប៊ុនណា

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំ[illegible] ១[illegible]
ថ្ងៃ[illegible] ១[illegible] ០[illegible] ១[illegible]
ថ្ងៃ[illegible] ១[illegible] ០[illegible] ១[illegible]

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.

ប្រកាសអន្តរក្រសួង
ស្តីពី
ការបង្កើតរដ្ឋទេយ្យបុរេប្រទាន សម្រាប់ឆ្នាំ២០១៨
ប្រចាំនៅធនាគារបញ្ជាក់ចំណាយសេវាសុខាភិបាល នៃក្រសួងសុខាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការ កែសម្រួល និងបំពេញបន្ថែម សមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែ មេសា ឆ្នាំ២០១៦ ស្តីពីការ កែសម្រួល និងបំពេញបន្ថែម សមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ន.ស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៣/០០៤ ចុះថ្ងៃទី២១ ខែមិនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធ្វើវិសោធនកម្ម មាត្រា៩ និងមាត្រា១០ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៧/០១៩ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី០៣ ខែមិនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៤៤ មាត្រា៤៥ មាត្រា ៤៦ និងមាត្រា៤៧ នៃអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តិនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ១៣៩ អនក្រ.បក ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងថវិកា និងទ្រព្យសម្បត្តិរដ្ឋនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ១៥២ អនក្រ.បក ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៧ ស្តីពីការបង្កើតទីភ្នាក់ងារបញ្ជាក់ចំណាយសេវាសុខាភិបាល ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញប្រកាសលេខ១៧១ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីនីតិវិធីអនុវត្តថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញប្រកាសលេខ១៧២ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការប្រគល់សិទ្ធិជាអភិបាលហិរញ្ញវត្ថុ ជូនមន្ត្រីហិរញ្ញវត្ថុ ប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិកា នៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃ គណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ១២១២ សហវ.ប្រក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ១១៣៩៦ សហវ.ប្រក ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៦ ស្តីពីនីតិវិធីចំណាយតាមរដ្ឋទេយ្យបុរេប្រទានសម្រាប់ គ្រឹះស្ថានសាធារណៈរដ្ឋបាល
- យោងតាមតម្រូវការចាំបាច់នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងទីភ្នាក់ងារបញ្ជាក់ចំណាយសេវាសុខាភិបាលនៃក្រសួងសុខាភិបាល

សម្រេច

ប្រការ១ ._

ត្រូវបានបង្កើតរដ្ឋទេយ្យបុរេប្រទាន ជំពូក៦០"ការទិញ" ជំពូក៦១"សេវាកម្ម" នៅទីភ្នាក់ងារបញ្ជាក់ចំណាយសេវាសុខាភិបាល សម្រាប់មុខសញ្ញាចំណាយដូចមានចែងក្នុងប្រការ៥ នៃប្រកាសលេខ១១៣៩៦ សហវ.ប្រក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីនីតិវិធីចំណាយតាមរដ្ឋទេយ្យបុរេប្រទាន សម្រាប់រដ្ឋបាលថ្នាក់ជាតិ ។

តារាងឧបសម្ព័ន្ធរដ្ឋទេយ្យបុរេប្រទានត្រូវបានកំណត់ជាឧបសម្ព័ន្ធនៃប្រកាសអន្តរក្រសួងនេះ ។

ប្រការ២ ._

ចំនួនទឹកប្រាក់មួយជុំបង្ហិលនៃរដ្ឋទេយ្យបុរេប្រទាន ត្រូវកំណត់ដូចក្នុងតារាងឧបសម្ព័ន្ធរដ្ឋទេយ្យបុរេប្រទាន ។

ប្រការ៣ ._

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

ប្រការ៤ ._

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងនាយកទីភ្នាក់ងារបញ្ជាក់ចំណាយសេវាសុខាភិបាល ប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមនិវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងសុខាភិបាល ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃ ២ កើត ខែ ចេត្រ ឆ្នាំរកា ឆស័ក ព.ស ២៥៦១
ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ២០១៨

រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ	រដ្ឋមន្ត្រី ក្រសួងសុខាភិបាល
បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន	យ៉ាម ប៊ុនហេង

កន្លែងទទួល
- ទីស្តីការ គណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- ក្រសួងសុខាភិបាល
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ទីភ្នាក់ងារបញ្ជាក់ចំណាយ
សេវាសុខាភិបាល

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តារាងឧបសម្ព័ន្ធរដ្ឋទេយ្យបុរេប្រទានថវិកាកម្មវិធីតាមចំណាត់ថ្នាក់សេដ្ឋកិច្ច ឆ្នាំ២០១៨

ជំពូក	ឆមាស	អនុឆមាស	ចំណាត់ថ្នាក់ចំណាយ	ច្បាប់ថវិកា២០១៨	ឥណទានដែលជ្រើសរើស	ឥណទានរដ្ឋ ទេយ្យបុរេប្រទាន	ឥណទានទូទាត់ធម្មតា	ឥណទាន១ដុំ បង្ខិលរដ្ឋទេយ្យ បុរេប្រទាន	ភាគរយ
				១	២	៣	៤=២-៣	៥=៣/៤ =១ដុំ	៦=៣/២
			សរុបរួម	2,723,000,000	1,317,000,000	1,062,000,000	255,000,000	265,500,000	80.64%
60			ការទិញ(១)	1,246,000,000	370,000,000	220,000,000	150,000,000	55,000,000	59.46%
	6001		សម្ភារផ្គត់ផ្គង់ថែទាំ	260,000,000	40,000,000	40,000,000	-	10,000,000	100.00%
		60011	សម្ភារផ្គត់ផ្គង់សំអាត និងអនាម័យ	40,000,000	20,000,000	20,000,000	-	5,000,000	100.00%
		60012	សំភារៈផ្គត់ផ្គង់សំរាប់ថែទាំអាគារ ប្រសាទ	20,000,000	20,000,000	20,000,000		5,000,000	100.00%
		60015	ប្រេងឥន្ធនៈ និងប្រេងរំអិល	200,000,000	-	-	-	-	
	6002		សម្ភារផ្គត់ផ្គង់ផ្នែករដ្ឋបាល	130,000,000	130,000,000	70,000,000	60,000,000	17,500,000	53.85%
		60021	សម្ភារការិយាល័យ	20,000,000	20,000,000	20,000,000	-	5,000,000	100.00%
		60022	សៀវភៅមើល និងឯកសារ	10,000,000	10,000,000	10,000,000		2,500,000	100.00%
		60023	ការបោះពុម្ព	100,000,000	100,000,000	40,000,000	60,000,000	10,000,000	40.00%
	6004		សំលៀកបំពាក់ និងការតុបតែង	21,000,000	-	-	-	-	
		60041	ឯកសណ្ឋាន	21,000,000	-	-	-	-	
	6005		សម្ភារតូចតាច សង្ហារឹម និងសម្ភារបរិក្ខារ	835,000,000	200,000,000	110,000,000	90,000,000	27,500,000	55.00%
		60051	សម្ភារ និងបរិក្ខារបច្ចេកទេស មិនមែនព័ត៌មានវិទ្យា	50,000,000	50,000,000	50,000,000	-	12,500,000	100.00%
		60052	សង្ហារឹម	120,000,000	120,000,000	30,000,000	90,000,000	7,500,000	25.00%
		60053	សម្ភារប្រើប្រាស់	30,000,000	30,000,000	30,000,000	-	7,500,000	100.00%
		60054	សម្ភារ និងឧបករណ៍ដឹកជញ្ជូន	335,000,000	-	-	-	-	
		60055	សម្ភារ និងបរិក្ខារបច្ចេកទេស ព័ត៌មានវិទ្យា	300,000,000	-	-	-	-	

ភ្នំពេញ ថ្ងៃទី ១៨ ខែ០៧ ឆ្នាំ ២០១៨
ក្រសួងសុខាភិបាល
ការកំណត់ទំព័រ ១ នៃ ១

ច្បាប់ស្តីពីរដ្ឋធានុ០ ១០ ១ ១ ១

ជំពូក	ផលិតផល	អនុផលិតផល	ចំណាត់ថ្នាក់ចំណាយ	ច្បាប់ថវិកា២០១៨	គណនីដែលជ្រើសរើស	គណនីរដ្ឋ ទេ ឯកជនបុរេប្រទាន	គណនីទូទាត់ធម្មតា	គណនី១ជុំ បង្វិលរដ្ឋទេ ឯកជនបុរេប្រទាន	ភាគរយ
				១	២	៣	៤=២-៣	៥=៣/៤ =១ជុំ	៦=៣/២
		61141	សោហ៊ីយប្រៃសណីយ៍	-	-	-	-	-	
		61142	សោហ៊ីយទូរគមនាគមន៍	48,000,000	48,000,000	48,000,000	-	12,000,000	100.00%

បានឃើញនិងពិនិត្យត្រឹមត្រូវ

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំ[illegible] នព្វស័ក ពស ២៥៦១

ថ្ងៃទី ០១ ខែ ២ ឆ្នាំ២០១៨

ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា

អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ

អគ្គនាយករង

ម៉ិញ ចានសុវណ្ណអានិច្ចាសីលា

បានឃើញនិងពិនិត្យត្រឹមត្រូវ

ថ្ងៃ[illegible]ខែ[illegible]ឆ្នាំ[illegible] នព្វស័ក ពស ២៥៦១

ធ្វើនៅភ្នំពេញថ្ងៃទី[illegible]ខែ[illegible] ឆ្នាំ២០១៨

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

បានឃើញនិងពិនិត្យត្រឹមត្រូវ

ថ្ងៃ[illegible]ខែ[illegible]ឆ្នាំ[illegible] នព្វស័ក ពស ២៥៦១

ថ្ងៃទី ២៨ ខែ ១ ឆ្នាំ២០១៨

គណនេយ្យករ

អ្នឿន សុធារី

បានឃើញនិងពិនិត្យត្រឹមត្រូវ

ថ្ងៃ[illegible]ខែ[illegible]ឆ្នាំ[illegible] នព្វស័ក ពស ២៥៦១

ថ្ងៃទី២៨ ខែ១ ឆ្នាំ២០១៨

រដ្ឋទេយ្យករបុរេប្រទាន

ណារ៉ា ភារ៉ា

បានឃើញនិងពិនិត្យត្រឹមត្រូវ

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំ[illegible] នព្វស័ក ពស ២៥៦១

ថ្ងៃទី២៨ ខែ១ ឆ្នាំ២០១៨

នាយក

ទីស្នាក់ការបញ្ជាក់ចំណាយសេវាសុខាភិបាល

បណ្ឌិត កើត ពេជ្រចិន្តា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម
លេខ ០១៣ ព.ណ.ជ.ណ.ប្រ.ក

ប្រកាស
ស្តីពី
ការកែសម្រួល និងបំពេញបន្ថែមការបែងចែកការកិច្ច
របស់ថ្នាក់ដឹកនាំក្រសួងពាណិជ្ជកម្ម

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៤ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងអនុរដ្ឋលេខាធិការ នៃក្រសួង និងរដ្ឋលេខាធិការដ្ឋាន នៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១២៧ អនក្រ.បក ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលមាត្រា២ មាត្រា៣ មាត្រា៤ និងបន្ថែមមាត្រា៨ ស្លួន នៃអនុក្រឹតលេខ ៥៩ អនក្រ.បក ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការដំឡើងនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហារ៉ណ អាហារ៉ណ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល) ឲ្យទៅជាអគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហារ៉ណ អាហារ៉ណ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល) ចំណុះក្រសួងពាណិជ្ជកម្ម
- យោងតាមការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

សម្រេច

ប្រការ១ៈ ត្រូវបានបែងចែកការកិច្ច ជូនថ្នាក់ដឹកនាំក្រសួងពាណិជ្ជកម្ម ដូចខាងក្រោម ៖

១- ឯកឧត្តម **ប៉ាន សូរស័ក្តិ** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ជាប្រធានស្ថាប័ន ទទួលខុសត្រូវរួមការងារក្នុងក្រសួង ជាពិសេសដឹកនាំត្រួតពិនិត្យ និងតាមដានការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល លើរាល់ចំណុចដែលមានការពាក់ព័ន្ធទៅនឹងសមត្ថកិច្ច របស់ក្រសួងពាណិជ្ជកម្ម និងដោយឡែកដឹកនាំគ្រប់គ្រង៖

- នាយកដ្ឋានបុគ្គលិក នាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋាននាំចេញ-នាំចូល នាយកដ្ឋានអភិវឌ្ឍន៍វិស័យឯកជន អគ្គាធិការដ្ឋាន អគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហារ័ណ អាហារ័ណ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល) ក្រុមហ៊ុនប្រ៊ីនត្រេដ និងតំណាងពាណិជ្ជកម្មក្រៅប្រទេស
- ពិនិត្យតាមដានរាល់ការងារពាក់ព័ន្ធជាមួយក្រសួងមហាផ្ទៃ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- ប្រធានក្រុមការងារផ្នែកផលិតកម្មកែច្នៃសម្រាប់នាំចេញ និងកិច្ចសម្រួលពាណិជ្ជកម្ម ។
  - ឯកឧត្តម **ស៊ុន ជារ៉ាវន្ត** អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម៖ ទទួលការកិច្ចជានាយកខុទ្ធកាល័យជួយការងាររដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងសម្របសម្រួលការងារក្នុងក្រសួងពាណិជ្ជកម្ម
  - ឯកឧត្តម **ប៉ាវ ហេងតារា** អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម៖ ទទួលការកិច្ចជួយការងាររដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មប្រគល់ជូន
  - ឯកឧត្តម **ម៉ក់ ឧសភា** អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម៖ ទទួលការកិច្ចជួយការងាររដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មប្រគល់ជូន និងសម្របសម្រួលការងារជាមួយ អគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហារ័ណ អាហារ័ណ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល)។

២- ឯកឧត្តម **ភីម ស៊ីថន** រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្មទទួលបន្ទុកសម្របសម្រួលការងារទូទៅក្នុងក្រសួង
  - ឯកឧត្តម **រាជ រ៉ា** ឯកឧត្តម **សុខ សុត្ថ**ា ឯកឧត្តម **ប៉ាវ ហេងតារា** អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម
- នាយកដ្ឋានអឺរ៉ុប មជ្ឈឹមបូព៌ា និងអាហ្វ្រិក នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម មន្ទីរពាណិជ្ជកម្មខេត្តកំពង់ស្ពឺ មន្ទីរពាណិជ្ជកម្មខេត្តព្រះសីហនុ មន្ទីរពាណិជ្ជកម្មខេត្តកោះកុង និងមន្ទីរពាណិជ្ជកម្មខេត្តកែប
- ពិនិត្យ និងសម្រេចចុះហត្ថលេខាលើវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ (C/O) នាំចេញទៅអឺរ៉ុប មជ្ឈឹមបូព៌ា និងអាហ្វ្រិក
- ពិនិត្យផ្តល់យោបល់រាល់ការងារពាក់ព័ន្ធជាមួយក្រសួងការពារជាតិ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងមុខងារសាធារណៈ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល និងគណៈកម្មាធិការជាតិកស្តុការកម្ម និងបង្កើតក្រុមការងារបង្គោលរបស់ក្រសួង ប្រធានក្រុមការងារបច្ចេកទេសវិមជ្ឈការ និងវិសហមជ្ឈការរបស់ក្រសួងពាណិជ្ជកម្ម
- ក្រុមការងារផ្នែកថាមពល-ហេដ្ឋារចនាសម្ព័ន្ធ និងដឹកជញ្ជូន។

៣- ឯកឧត្តម **ឱក ម៉ុង** រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ទទួលការកិច្ចដឹកនាំ៖
  - ឯកឧត្តម **ចាន់ រ៉ាស៊ី** ឯកឧត្តម **ម៉ក់ ឧសភា** អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម
- នាយកដ្ឋានអាមេរិក មន្ទីរពាណិជ្ជកម្មខេត្តកំពង់ចាម មន្ទីរពាណិជ្ជកម្មខេត្តត្បូងឃ្មុំ មន្ទីរពាណិជ្ជកម្មខេត្តក្រចេះ មន្ទីរពាណិជ្ជកម្មខេត្តស្ទឹងត្រែង និងមន្ទីរពាណិជ្ជកម្មខេត្តរតនគិរី
- ពិនិត្យ និងសម្រេចចុះហត្ថលេខាលើវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ (C/O) នាំចេញទៅអាមេរិក
- ពិនិត្យតាមដានផ្តល់យោបល់រាល់ការងារពាក់ព័ន្ធជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ធនាគារជាតិកម្ពុជា និងក្រុមការងារអន្តរក្រសួងទទួលបន្ទុកកិច្ចការ សរសេររបាយការណ៍ជាតិពាក់ព័ន្ធនឹងសិទ្ធិមនុស្ស ជូនអង្គការសហប្រជាជាតិ គណៈកម្មាធិការជាតិសុខភាព និងសុវត្ថិភាពការងារ គណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារ គណៈកម្មាធិការជាតិបណ្តុះបណ្តាល
- ក្រុមការងារផ្នែកទំនាក់ទំនងវិជ្ជាជីវៈ។

ទំព័រទី ២

៤- ឯកឧត្តម **ម៉ៅ ម៉ូរ៉ា** រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ទទួលការកិច្ចដឹកនាំ៖
- លោកជំទាវ **សូ ស្រីមុិច** ឯកឧត្តម **សុខ សុភ័ក្ត្រ** អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម

- នាយកដ្ឋានអាស៊ីប៉ាស៊ីហ្វិក នាយកដ្ឋាននីតិកម្ម នាយកដ្ឋានផ្តល់ព័ត៌មាន និងផ្ទៀងផ្ទាត់ច្បាប់ នាយកដ្ឋានអភិវឌ្ឍន៍វិស័យឯកជន នាយកដ្ឋានគោលនយោបាយពាណិជ្ជកម្ម មន្ទីរពាណិជ្ជកម្មខេត្តព្រៃវែង មន្ទីរពាណិជ្ជកម្មខេត្តស្វាយរៀង និងមន្ទីរពាណិជ្ជកម្មខេត្តមណ្ឌលគិរី
- ពិនិត្យ និងសម្រេចចុះហត្ថលេខាលើវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ (C/O) នាំចេញទៅអាស៊ីប៉ាស៊ីហ្វិក
- ពិនិត្យផ្តល់យោបល់រាល់ការងារពាក់ព័ន្ធជាមួយទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងធនធានទឹក និងឧតុនិយម ASEAN/ASEM/ACMECS/ESCAP ការងារសហប្រតិបត្តិការតំបន់ត្រីកោណកម្ពុជា-ឡាវ-ថៃ ការងារសហប្រតិបត្តិការតំបន់មេគងកកម្ពុជា-ឡាវ-ថៃ ក្រុមប្រឹក្សាកសិកម្ម និងអភិវឌ្ឍន៍ អង្គការពាណិជ្ជកម្មអន្តរជាតិ និងសភាពាណិជ្ជកម្មកម្ពុជា
- ក្រុមការងារផ្នែកកសិកម្ម កសិ-ឧស្សាហកម្ម សហព័ន្ធស្រូវអង្ករកម្ពុជា
- ក្រុមការងារផ្នែកស្រូវ-អង្ករ។

៥- ឯកឧត្តម **ឈួន ដារ៉ា** រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ទទួលការកិច្ចដឹកនាំ៖
- ឯកឧត្តម **សំ សិរីតន់** អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម

- នាយកដ្ឋានកិច្ចការពិពណ៌ នាយកដ្ឋានអភិវឌ្ឍន៍ទីផ្សារ តំណាងពាណិជ្ជកម្មប្រចាំតំបន់សេដ្ឋកិច្ចពិសេស មន្ទីរពាណិជ្ជកម្មខេត្តកណ្តាល មន្ទីរពាណិជ្ជកម្មខេត្តតាកែវ និងមន្ទីរពាណិជ្ជកម្មខេត្តកំពត
- ពិនិត្យផ្តល់យោបល់រាល់ការងារពាក់ព័ន្ធជាមួយក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងទេសចរណ៍ គណៈកម្មាធិការជាតិជំរុញចលនាភូមិមួយ ផលិតផលមួយ គណៈកម្មាធិការរៀបចំផែនការកិច្ចសហប្រតិបត្តិការទ្វេភាគី ក្នុងក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចផ្លូវសូត្រ និងផ្លូវសូត្រសមុទ្រសតវត្សទី២១ ក្រុមការងារសកម្មភាពជនពិការ
- ក្រុមការងារផ្នែកទេសចរណ៍។

៦- លោកជំទាវ **ឌីករ៉ែត ភ័ក្ត្រ** រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ទទួលការកិច្ចដឹកនាំ៖
- ឯកឧត្តម **ម៉ែន សុធី** ឯកឧត្តម **ឃឹម សិរីវុធ្យ** ឯកឧត្តម **សំហេង ម្ហ៊ា** អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម

- នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ មន្ទីរពាណិជ្ជកម្មខេត្តកំពង់ឆ្នាំង មន្ទីរពាណិជ្ជកម្មខេត្តពោធិសាត់ មន្ទីរពាណិជ្ជកម្មខេត្តបាត់ដំបង មន្ទីរពាណិជ្ជកម្មខេត្តប៉ៃលិន និងមន្ទីរពាណិជ្ជកម្មខេត្តបន្ទាយមានជ័យ
- ពិនិត្យផ្តល់យោបល់រាល់ការងារពាក់ព័ន្ធជាមួយ ក្រសួងកិច្ចការនារី ក្រសួងអប់រំ យុវជន និងកីឬា ក្រសួងរ៉ែ និងថាមពល ក្រសួងសុខាភិបាល និងក្រសួងធម្មការ និងសាសនា និងគណៈកម្មាធិការត្រួតពិនិត្យផលិតផលថ្នាំជក់ ក្រុមការងារអន្តរក្រសួងត្រួតពិនិត្យសារធាតុគីមីផ្សំគ្រឿងញៀន
- ក្រុមការងារផ្នែកសេវាធនាគារ និងហិរញ្ញវត្ថុ។

៧- ឯកឧត្តម **អ៊ុក ប្រជា** រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ទទួលការកិច្ចដឹកនាំ៖
- លោកជំទាវ **ចម ឌិម្ម** ឯកឧត្តម **ភីម សុខុន** ឯកឧត្តម **សំហេង ម្ហ៊ា** អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម

- នាយកដ្ឋានកម្មសិទ្ធិបញ្ញា នាយកដ្ឋានផែនការ ស្ថិតិ និងព័ត៌មានពាណិជ្ជកម្ម វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវ

ទំព័រទី ៣

- មន្ទីរពាណិជ្ជកម្មខេត្តកំពង់ធំ មន្ទីរពាណិជ្ជកម្មខេត្តព្រះវិហារ មន្ទីរពាណិជ្ជកម្មខេត្តសៀមរាប និងមន្ទីរពាណិជ្ជកម្មខេត្តឧត្តរមានជ័យ
- ពិនិត្យផ្តល់យោបល់រាល់ការងារពាក់ព័ន្ធជាមួយក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្រសួងផែនការ ក្រសួងបរិស្ថាន ក្រសួងយុត្តិធម៌ ក្រសួងព័ត៌មាន ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក្រសួងវប្ផធម៌ និងវិចិត្រសិល្ប: ក្រុមប្រឹក្សាជាតិកម្មសិទ្ធិបញ្ញា ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ និងក្រុមប្រឹក្សាជាតិស្ថិតិ
- ក្រុមការងារផ្នែកកម្មន្តសាល និងសហគ្រាសធុនតូចមធ្យម
- ក្រុមការងារផ្នែកនីតិកម្ម ពន្ធដារ និងអភិបាលកិច្ច។

ប្រការ២៖ អំពីការកិច្ច និងសិទ្ធអំណាច៖

១- រដ្ឋលេខាធិការទទួលដឹកនាំ គ្រប់គ្រង តាមចង្កោមការងារទទួលបន្ទុកដែលបានប្រគល់ជូន និងផ្តល់យោបល់ជូនរដ្ឋមន្ត្រីពិនិត្យ សម្រេចលើរាល់សំណើដែលមានការពាក់ព័ន្ធ។

២- រដ្ឋលេខាធិការអាចប្រគល់សិទ្ធិពិនិត្យ និងសម្រេចជូនអនុរដ្ឋលេខាធិការ នូវការងារដែលស្ថិតនៅក្នុងចង្កោមការងាររបស់ខ្លួន។

ប្រការ៣៖ អំពីរបបប្រជុំ៖

ក-ប្រជុំសប្តាហ៍៖ នៅរៀងរាល់ព្រឹកថ្ងៃពុធ នឹងមានការប្រជុំក្រោមការដឹកនាំរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ដែលមានការចូលរួមពីរដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយក អគ្គនាយករង អគ្គាធិការ អគ្គាធិការរង អគ្គនាយក អគ្គនាយករងកាំកុងត្រូល អគ្គនាយកក្រុមហ៊ុនហ្គ្រីនត្រេដ ប្រធាននាយកដ្ឋាន អនុប្រធាននាយកដ្ឋាន និងប្រធាន អនុប្រធានអង្គភាពចំណុះក្រសួង ប្រធានមន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ ប្រធានមន្ទីរពាណិជ្ជកម្មខេត្តកណ្តាល ដើម្បីស្តាប់របាយការណ៍ ពិភាក្សាដោះស្រាយការងាររួម និងកែលម្អចំណុចខ្វះខាត។

ខ-ប្រជុំខែ៖ នៅរៀងរាល់ព្រឹកថ្ងៃពុធ សប្តាហ៍ចុងក្រោយនៃខែ នឹងមានការប្រជុំក្រោមការដឹកនាំរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ដែលមានការចូលរួមពី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយក អគ្គនាយករង អគ្គាធិការ អគ្គាធិការរង អគ្គនាយក អគ្គនាយករង កាំកុងត្រូល អគ្គនាយកក្រុមហ៊ុនហ្គ្រីនត្រេដ ប្រធាន-អនុប្រធាននាយកដ្ឋាន និងប្រធាន-អនុប្រធានអង្គភាពចំណុះក្រសួង ប្រធានមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត ដើម្បីស្តាប់របាយការណ៍ ពិភាក្សា និងដោះស្រាយការងាររួម និងកែលម្អចំណុចខ្វះខាត។

គ-ប្រជុំថ្នាក់អគ្គនាយកដ្ឋាន៖ នៅរៀងរាល់ខែនីមួយៗ អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន អគ្គនាយកដ្ឋានកាំកុងត្រូល ក្រុមហ៊ុនហ្គ្រីនត្រេដ ត្រូវរៀបចំឲ្យមានការប្រជុំប្រចាំខែ ដើម្បីបូកសរុបអំពីសកម្មភាព និងលទ្ធផលការងារប្រចាំខែ លើកវិធានការដោះស្រាយ និងកំណត់ទិសដៅ ការងារដែលត្រូវធ្វើបន្ត។

ឃ-ប្រជុំថ្នាក់នាយកដ្ឋាន៖ នៅរៀងរាល់ពីរសប្តាហ៍ម្តង នាយកដ្ឋានត្រូវរៀបចំឲ្យមានការប្រជុំផ្ទៃក្នុងនាយកដ្ឋានរបស់ខ្លួននីមួយៗ ដើម្បីតាមដានការងាររបស់អង្គភាព។

ង-ប្រជុំថ្នាក់មន្ទីរពាណិជ្ជកម្ម៖ នៅរៀងរាល់ខែនីមួយៗ មន្ទីរត្រូវរៀបចំឲ្យមានការប្រជុំផ្ទៃក្នុងមន្ទីររបស់ខ្លួននីមួយៗ ដើម្បីតាមដានការងាររបស់មន្ទីរ។

អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន អគ្គនាយកដ្ឋានកាំកុងត្រូល នាយកដ្ឋាន និងមន្ទីរពាណិជ្ជកម្ម ត្រូវធ្វើរបាយការណ៍អំពីលទ្ធផលនៃការប្រជុំតាមការកំណត់ខាងលើជូនរដ្ឋមន្ត្រី និងថ្នាក់ដឹកនាំក្រសួងដែលមានការពាក់ព័ន្ធជ្រាប និងផ្តល់ការណែនាំ។

ទំព័រទី ៤

ប្រការ៤៖ បែងចែកការទទួលខុសត្រូវជំនួសនៅពេលអវត្តមានថ្នាក់ដឹកនាំណាម្នាក់ ដើម្បីធានាល្បឿនសេវារដ្ឋបាល និងធានាបន្តនិរន្តភាពគ្រប់គ្រង ដូចខាងក្រោម៖

១-	ការងាររបស់ ឯកឧត្តម	**ភីម ស៊ីថន**	ត្រូវជំនួសដោយ ឯកឧត្តម	**ឌិត ម៉ុង**
២-	ការងាររបស់ ឯកឧត្តម	**ឌិត ម៉ុង**	ត្រូវជំនួសដោយ ឯកឧត្តម	**ម៉ៅ ថូ**
៣-	ការងាររបស់ ឯកឧត្តម	**ម៉ៅ ថូ**	ត្រូវជំនួសដោយ ឯកឧត្តម	**ឈួន ដារ៉ា**
៤-	ការងាររបស់ ឯកឧត្តម	**ឈួន ដារ៉ា**	ត្រូវជំនួសដោយ លោកជំទាវ	**គឹមរ៉ែត កំរង**
៥-	ការងាររបស់ លោកជំទាវ	**គឹមរ៉ែត កំរង**	ត្រូវជំនួសដោយ ឯកឧត្តម	**អ៊ុក ប្រជា**
៦-	ការងាររបស់ ឯកឧត្តម	**អ៊ុក ប្រជា**	ត្រូវជំនួសដោយ ឯកឧត្តម	**ភីម ស៊ីថន**។

ប្រការ៥៖ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ត្រូវទទួលការកិច្ចបន្ថែមជាក់ស្តែង ក្រៅពីការកិច្ចដែលបានប្រគល់ជូនរួចតាមការប្រគល់របស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

ប្រការ៦៖ ប្រកាសទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

ប្រការ៧៖ នាយកខុទ្ទកាល័យ ឯកឧត្តម លោកជំទាវ ដែលមានឈ្មោះក្នុងប្រការ១ និងប្រការ៤ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន ប្រធានមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត និងប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងពាណិជ្ជកម្ម ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ០៦រោច ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី២២ ខែមករា ឆ្នាំ២០១៨

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ប៉ាន-សូរស័ក្តិ

ចម្លងជូន៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- អង្គភាពចំណុះក្រសួងពាណិជ្ជកម្ម
- រដ្ឋបាលរាជធានី-ខេត្ត
- មន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត
- ដូចប្រការ ៧ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

រក្សាសិទ្ធ និងបោះពុម្ពដោយ
អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
នៃ ទីស្តីការគណៈរដ្ឋមន្ត្រី